# ជំពូក ៨

## ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និង វិធានការកាត់បន្ថយ

## Potential Environmental Impacts and Mitigation Measures

## សំរាប់ប្រព័ន្ធខ្សែចម្លង ១១៥ គ.វ៉

Draft

# ជំពូកទី ៨

# ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និងវិធានការកាត់បន្ថយ សំរាប់ប្រព័ន្ធខ្សែចម្លង ១១៥ គ.វ

## ៨.១ មូលដ្ឋានសំរាប់ធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និង វិធានការកាត់បន្ថយ

ផ្អែកតាមកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន China Yunnan Corporation for International Techno-Economic Co-Operation ស្តីពីការអភិវឌ្ឍន៍គំរោង BOT លើគំរោងវារីអគ្គិសនីអាតៃចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ ។ ក្នុងគំរោងនេះ អនុស្ថានីយ៍អូរសោម ប្រព័ន្ធខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥គ.វ និង២៣០គ.វ គឺជាសមាសភាពនៃការអភិវឌ្ឍន៍នៃគំរោងផងដែរ ( មានបញ្ជាក់នៅចំណុចទី ៤.២ ទំព័រទី៦ និងទី៧ នៃ កិច្ចព្រមព្រៀងនេះ ) ។

ផ្អែកទៅលើមូលដ្ឋាននៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង (IESIA) ជាការអង្កេតសិក្សាស្រាវជ្រាវ និងការប្រជុំពិភាក្សាជាមួយសហគមន៍/ប្រជាជនមូលដ្ឋាន អង្គការនានា និងស្ថាប័នជាប់ទាក់ទងនឹងគំរោងគ្រប់ជាន់ថ្នាក់លើទីតាំងគំរោង សមាសភាពគំរោង ការងារសាងសង់គំរោង និងកិច្ចដំណើរការរបស់វា ដើម្បីស្វែងរក និងលទ្ធផលប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមក្នុងដំណាក់កាលរចនាគំរោង (Project Design) សាងសង់ (Project Construction) ប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance) ហើយនិងដំណាក់កាលបិទគំរោង (Project Closure) ។ ក៏ប៉ុន្តែនៅពេលដែលក្រុមការងារវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញបានចុះធ្វើការសិក្សាលំអិតទៅតាមហេដ្ឋារចនាសម្ព័ន្ធគំរោង រួមទាំងខ្សែ២៣០គ.វនេះរួចហើយ នៅពេលប្រជុំរាយការណ៍ពីលទ្ធផល និងប្រឹក្សាយោបល់ពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីរកដំណោះស្រាយនោះ តំណាងក្រុមហ៊ុនបាន បដិសេធថាក្រុមហ៊ុន CHD មិនទទួលខុសត្រូវលើគំរោងខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់២៣០គ.វ និងអនុស្ថានីយ៍អូរសោមទេ គឺគំរោងនេះទទួលខុសត្រូវដោយអគ្គិសនីកម្ពុជា និង ក្រុមហ៊ុន CPG ។

ដូចនេះការសិក្សា និងវាយតំលៃ ហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនេះ គឺធ្វើឡើងសំរាប់តែខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥ គ.វពីរខ្សែប៉ុណ្ណោះ គឺខ្សែទី១ចេញពី អគារថាមពលទី១ មកអនុស្ថានីយ៍អូរសោម មានប្រវែង៤.១២គ.ម មាន១១ ប៉មបង្គោលភ្លើង និងខ្សែទី២ចេញពីអគារថាមពលទី២ ដល់អនុស្ថានីយ៍អូរសោមមានប្រវែង១៣.៤៥គ.ម មាន៣៣ ប៉មបង្គោលភ្លើង ។

ផ្អែកទៅស្តង់ដារបស់ក្រសួងឧស្សាហកម្មដែលបានកំណត់ និងផ្អែកលើស្ថានភាពជាក់ស្តែងមួយចំនួន មូលដ្ឋាននៃការសិក្សាលើហេតុប៉ះពាល់លើការសាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥គ.វ មានដូចខាងក្រោម :

- ការរស់នៅ របស់ប្រជាពលរដ្ឋ និងដើមឈើកំពស់ខ្ពស់ជាង៣ម៉ែត្រស្ថិតនៅក្រោមខ្សែគន្លងគិតពីអ័ក្សនៃបង្គោលខ្សែចំលងអគ្គិសនី១៥ម៉ែត្រសងខាងចាត់ទុកថា ការរស់នៅរបស់ប្រជាពលរដ្ឋ និងដើមឈើនោះ នឹងត្រូវប៉ះពាល់អវិជ្ជមានជាមួយសំណង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ខាងលើនេះ ។
- ចំពោះ ដីធ្លី ដែលចាត់ទុកមានការប៉ះពាល់អវិជ្ជមាន នោះគឺជាប្រភេទដី ដែលស្ថិតនៅទីតាំងសាងសង់បង្គោលភ្លើងក្នុងទំហំ ១៥ម x១៥ ម =២២៥ម$^{២}$ ។
- ចំពោះព្រៃសហគមន៍ចាត់ទុកជាការប៉ះពាល់ ដល់ចំណូលរបស់សមាជិកសហគមន៍នៃការរកប្រយោជន៍ពីព្រៃនេះ គឺគិតទៅតាមគន្លងនៃខ្សែ១១៥ គ.វនេះ ជាហ.ត ។



Draft




Draft

**រូបភាព: ការប៉ះពាល់ដោយសារខ្សែបញ្ជូនតរង្គតង់ស្យុងខ្ពស់**

ផ្អែកទៅលើគោលការណ៍ណែនាំ វ.ហ.ប របស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការប្រើប្រាស់តារាង Checklistសំរាប់ដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះ ។

ផ្អែកទៅលើតារាង Checklist របស់ក្រសួងបរិស្ថាន ស្តីពីការកំណត់នូវទំហំផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថានរូបសាស្ត្រ ធនធានបរិស្ថាន និងសង្គម និងវិធានការកាត់បន្ថយ ។

ក្រុមការងារ SAWAC បានប្រើប្រាស់នូវតារាង Checklistខាងលើនេះសំរាប់ដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង លើគំរោងវារីអគ្គិសនីស្ទឹងអាតៃដូចខាងក្រោម:

**តារាង ៦១: តារាង Checklist សំរាប់កំណត់ការប៉ះពាល់ និងមិនប៉ះពាល់ដោយខ្សែបញ្ជូនចរន្តអគ្គិសនីតង់ស្យុងខ្ពស់**

| **ក. ទីតាំងគំរោង:**<br>*តើតំបន់គំរោងនៅក្នុងឬក្បែរតំបន់បរិស្ថានសំខាន់ៗដូចខាងក្រោមដែរ ឬទេ?* | **មាន** | **គ្មាន** | **កត់សំគាល់** |
|---|---|---|---|
| • ទីតាំងមរតកវប្បធម៌ | | ✓ | |
| • តំបន់ការពារ/អភិរក្ស អាចប៉ះពាល់ដោយសារខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គ.វ៉ពីអគារថាមពលទី១ និងអគារថាពលទី២ មកអនុស្ថានីយ៍អូរសោម | ✓ | | ការប៉ះពាល់តំបន់ការពារព្រៃឈើភ្នំក្រវាញ CI និង ព្រៃការពារដងទង់ Wildlife Alliance របស់ MAFF ដោយសារខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥គ.វ៉ ត្រូវការទំហំដី ៤៨.៤៤ ហ.ត ក្នុងនោះព្រៃស្រោង៤៣.០៣ហ.ត និងល្បាយឬស្សី៥.២៧ហ.ត ដីប្រជាជនដីអូរ និងដីផ្លូវ៣.១៤ហ.តដែលត្រូវគិតបញ្ចូលក្នុងទំហំប៉ះពាល់ ។ |
| • តំបន់ដីសើម | | ✓ | |
| • កោងកាង | | ✓ | |
| • មាត់ពាម (តំបន់ទឹកភ្លៀវ) | | ✓ | |
| • តំបន់ទ្រនាប់នៃតំបន់ការពារ/អភិរក្ស | | ✓ | |
| • តំបន់ពិសេសសំរាប់ការពារ/អភិរក្សជីវចំរុះ | | ✓ | |
| **ខ. ផលប៉ះពាល់បរិស្ថានសំខាន់ៗ**<br>*តើគំរោងនឹងបង្កឱ្យ......* | | | |
| • មានទីតាំងស្ថិតនៅតំបន់ប្រវត្តិសាស្ត្រ/វប្បធម៌និងធ្វើឱ្យបាត់បង់សោភណ្ឌភាព ទេសភាពហើយមានបញ្ចេញកាកសំណល់ច្រើនដែរឬទេ? | | ✓ | |
| • ការទន្ទ្រានចូលតំបន់ប្រពន្ធ័អេកូឡូស៊ីសំខាន់ៗ(ដូចជាតំបន់ការពារអភិរក្ស) ដែរឬទេ? | ✓ | | មានការចូលទន្ទ្រានតំបន់ប្រពន្ធ័អេកូឡូស៊ីសំខាន់ៗ ដោយ សារសកម្មភាពគំរោង ក្នុងតំបន់ការពារព្រៃឈើភ្នំក្រវាញ និងដងទង់របស់ MAFF សហការជាមួយ CI, Wildlife Alliance សហការជាមួយ MAFF ។ |
| • ការសាងសង់មានការប៉ះពាល់ផ្លូវទឹកសំខាន់ៗ ដែលធ្វើឱ្យប្រែប្រួលដល់ប្រពន្ធ័ជលសាស្ត្រ ដោយបង្កើនល្បាប់ ដោយសារការហូរច្រោះនៃកន្លែងសារសង់ដែរទេ? | ✓ | | បង្កឱ្យមានការហូរច្រោះនៅពេលធ្វើផ្លូវចូល និងការជីកដីធ្វើគ្រឹះបង្គោលភ្លើង ។ |
| • មានការខូចខាតដល់តំបន់ដែលងាយរងគ្រោះតាមតំបន់ឆ្នេរ/ដែនជំរកសត្វសមុទ្រដោយសារការសង់ខ្សែដាក់ក្នុងសមុទ្រដែរឬទេ? | | ✓ | |
| • មានការខូចខាតដល់គុណភាពទឹកលើដី ទឹកក្រោមដី ដោយសារកាកសំណល់រឹង រាវ ដែលបញ្ចេញពីកន្លែងការដ្ឋានសាងសង់ដែរទេ? | ✓ | | មានការប៉ះពាល់ដល់គុណភាពទឹកលើដីនិងក្រោមដីដោយសារការគ្រប់គ្រងកាកសំណល់រឹង រាវ មិនបានល្អ ជាពិសេសគ្មាន ឬខ្វះបង្គន់អនាម័យ ។ |
| • ការបង្កើនការបំពុលខ្យល់ដោយសារ ការងារយកថ្ម ការងារដី (ការកិនថ្ម ការជីកដី ការចាក់បំពេញដី) ដែរឬទេ? | ✓ | | អាចមានការប៉ះពាល់ដល់គុណភាពខ្យល់ក្នុងការសាងសង់គំរោង ដោយសារខ្វះបច្ចេកទេស ឬមិនគោរពតាមបទដ្ឋានបច្ចេកទេសនៃការងារទាំងនោះ ។ |
| • តើមានការបំពុលដោយ សារធាតុគីមី ដោយសារការប្រើសារធាតុ នេះសំរាប់ការសំអាតព្រៃឈើ ដើមឈើ និងរុក្ខជាតិក្នុងការសាងសង់នេះដែរឬទេ? | | ✓ | ក្រុមហ៊ុនមិនប្រើសារធាតុគីមីក្នុងការសំអាត ព្រៃឈើ ដើមឈើ និងដំណាំទេ ក្នុងការសាងសង់គំរោងនេះ ។ |

Draft

| | | | |
|---|---|---|---|
| • តើមានការបញ្ចេញសំលេង រំញ័រដោយសារការបំផ្ទុះ និងការងារស៊ីវិលផ្សេងៗទៀតដែរឬទេ? | ✓ | | មានការរំខានដោយសំលេង និងរំញ័រចេញមកពីការសាងសង់គំរោងនេះ (គ្រឿងចក្រ រថយន្ត កម្មករគំរោង) ។ |
| • តើមានការបំលាស់ប្តូរលំនៅដ្ឋានដោយមិនស្មគ្រ័ចិត្តរបស់ប្រជាពលរដ្ឋដែរឬទេ? | ✓ | | មានដីរបស់ប្រជាជនចំនួន២ គ្រួសារប៉ះពាល់ដោយសារសង់បង្គោលភ្លើង ។ |
| • តើមានការទំនាស់សង្គមដែលទាក់ទងទៅនឹងការីតជីវភាពរស់នៅធម្មតារបស់ប្រជាពលរដ្ឋ ដោយសារការរាំងស្ទះផ្លូវធ្លាប់ធ្វើចរាចរដែរឬទេ ? | | ✓ | |
| • តើអាចកើតមានគ្រោះថ្នាក់ចរាចរដោយសារ ការបើកបរដឹកជញ្ជូនសម្ភារក្នុងការសាងសង់ដែរឬទេ? | ✓ | | អាចនឹងកើតមានគ្រោះថ្នាក់ចរាចរដោយការធ្វេសប្រហែសក្នុងការបើកបរដឹកជញ្ជូន សម្ភារសំណង់ និងសម្ភាររបស់គំរោងផ្សេងៗ ។ |
| • តើមានការខ្វះអនាម័យ និងការខ្វះការគ្រប់គ្រងការសំណល់រឹង រាវនៅកន្លែងការដ្ឋានសាងសង់ ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពកម្មករ ហើយកើតមានការចំលងរោគទៅប្រជាជនមូលដ្ឋានឬទេ? | ✓ | | អាចនឹងមានការប៉ះពាល់ដល់សុខភាពកម្មករឬប្រជាពលរដ្ឋក្នុងតំបន់គំរោង ដោយសារការមិនយកចត្តទុកដាក់ ឬធ្វេសប្រហែសពីក្រុមហ៊ុនក្នុងការអប់រំអនាមយ័ ការត្រួតពិនិត្យសុខភាព និងការបំពាក់ឧបករណ៍ដែលជាមធ្យោបាយបំរើឱ្យសុខភាពសាធារណៈ ។ល។ |
| • តើមានការបង្ករលក្ខណៈងាយស្រួលដល់ជំរកមូសដែលជាប្រភពចំលងរោគដែរឬទេ? | ✓ | | អាចនឹងមានការប៉ះពាល់ដល់សុខភាពកម្មករឬប្រជាពលរដ្ឋក្នុងតំបន់គំរោង ដោយសារការមិនយកចិត្តទុកដាក់ ឬធ្វេសប្រហែសពីក្រុមហ៊ុនក្នុងការអប់រំអនាមយ័ធ្វើអោយមានកន្លែងដក់ទឹកនៅក្នុងការដ្ឋានសំណង់ ។ |
| • តើមានការជំលៀសប្រជាជនដោយខាងពុំបានចេញពីចំណីខ្សែភ្លើងនេះដែរឬទេ?(គិតពីអក្ស័បង្គោលភ្លើងចេញម្ខាង១៥ម សរុប៣០ម) | | ✓ | គ្មានផ្ទះប្រជាពលរដ្ឋរស់នៅតាមគន្លងនេះ ដែលចាំបាច់ត្រូវរុះរើ ឬ ដូរទីតាំងនេះទេ ។ |
| • តើមានការប៉ះពាល់ដីប្រើប្រាស់របស់ប្រជាពលរដ្ឋ ដោយសារការរស់នៅការដាំដំណាំយុទ្ធសាស្រ្ត នៅក្រោមគន្លងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥គ.វ៉ គិតពីអក្ស័បង្គោលភ្លើងចេញម្ខាងខាង១៥ម និងប៉ះដីប្រើប្រាស់ដោយសារការសាងសង់បង្គោលដែរឬទេ ? | ✓ | | មានដីប្រើប្រាស់របស់ប្រជាពលរដ្ឋ សំរាប់ការរស់នៅការដាំដំណាំយុទ្ធសាស្រ្តនៅក្រោមគន្លងខ្សែបញ្ជូនតង់ស្យុងខ្ពស់១១៥គ.វ៉គិតពីអក្ស័បង្គោលភ្លើងចេញម្ខាង១៥មលើទំហំដី៥២.៧១ហ.ត និងការប៉ះពាល់ដោយសារការសាងសង់បង្គោលចំនួន៦បង្គោលលើដីប្រើប្រាស់ទំហំ ១៣៥០ម² ហើយចំនួនប៉ះពាល់សរុប២ គ្រួសារ |
| • តើមានការប៉ះពាល់ផ្លូវ និងស្ទឹង ដោយសារខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥គ.វ៉ ឆ្លងកាត់ គិតពីអក្ស័បង្គោលភ្លើងម្ខាង១៥មដែរឬទេ? | ✓ | | មានការប៉ះពាល់ដល់ចរាចរតាមផ្លូវ និងអូរ ដោយសារខ្សែបញ្ជូនតង់ស្យុងខ្ពស់១១៥គ.វ៉ ឆ្លងកាត់គិតពីអក្ស័បង្គោលភ្លើង ម្ខាង១៥មលើទំហំផ្លូវ០.១៧ហ.ត និងប៉ះពាល់ស្ទឹង០.១១ហ.ត ។ |
| • តើមានការប៉ះពាល់ដល់បរិស្ថាន ដែលទាក់ទងទៅនឹងការថែទាំបណ្តាញខ្សែនេះដែរឬទេ? | ✓ | | អាចមានការប៉ះពាល់ដល់បរិស្ថានធម្មជាតិ និងសង្គម ដោយសារការធ្វេសប្រហែសក្នុងការគ្រប់គ្រងសំណល់ រឹង-រាវ ដែលចេញពីអគាររដ្ឋបាល លំនៅដ្ឋានរបស់បុគ្គលិក-កម្មករគំរោង។ ការធ្វេសប្រហែស ឱ្យដើម ឈើដុះខ្ពស់ ជាងកំពស់ដែលត្រូវកាប់មែក ឬចុងសំអាតនាំឱ្យ មានគ្រោះថ្នាក់ដល់មនុស្ស និងសត្វ ។ |
| • តើមានបំពាក់ឧបករណ៍ការពារដែរឬទេ? ក្នុងករណីខ្សែនេះកាត់តាមតំបន់អភិរក្ស ។ | ✓ | | នៅក្នុងតំបន់គំរោងមានដីព្រៃការពារហើយនៅគ្រប់អគារថាមពលមានប្រពន្ធ័ផ្តាច់ភ្លើងដោយស្វ័យប្រវត្តិ ។ |
| • តើគ្រប់មធ្យោបាយ និងឧបករណ៍ក្នុងការថែទាំគំរោងនេះមានគ្រោះថ្នាក់ | ✓ | | អាចមានគ្រោះថ្នាក់ក្នុងការថែទាំគំរោង ដូចជា ការជូសជុល |

Draft

| | | | |
|---|---|---|---|
| ដែរឬទេ? | | | ខ្សែត្រង់ស្វូរ ទូរបញ្ជារ ប្រពន្ធ័អេឡិចត្រូនិកជាដើម ។ល ។ |
| • តើមានគ្រោះថ្នាក់ដល់សុខភាពប្រជាពលរដ្ឋ ដោយសារដែនអេឡិច ត្រូម៉ាញ៉េទិក អេឡិចត្រូស្តាទិក ដែលស្ថិតនៅតំបន់ក្រោមខ្សែ និងបង្គោលភ្លើង ដែរឬទេ? | ✓ | | អាចមានគ្រោះថ្នាក់ដល់អ្នករស់នៅក្រោមចំណីខ្សែនេះ (១៥ ម សងខាងអក្សបង្គោលភ្លើង) នៅពេលអាកាសធាតុសើម និងពេលមានភ្លៀងធ្លាក់ដោយសារដែនអគ្គិសនីទាំងនេះ ។ |
| • តើមានការបំពុលដោយ សារធាតុគីមីដែលប្រើប្រាស់សំរាប់បង្ហាក់កុំឱ្យព្រៃឈើ ឬដំណាំរុក្ខជាតិលូតបានខ្ពស់ដែរឬទេ? | | ✓ | ក្រុមហ៊ុនមិនប្រើសារធាតុគីមីក្នុងការបង្ហាក់ការលូតលាស់ របស់ដើមឈើ និងរុក្ខជាតិនានានោះទេ ។ |

## ៨.២ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

Negative Environmental Impacts and Mitigation Measures

គន្លងប្រព័ន្ធខ្សែចម្លងតង់ស្យុងខ្ពស់១១៥គ.វ៉ ទាំងពីរខ្សែមានផ្ទៃសរុប ៥២,៧១ ហ.ត ក្នុងនោះស្ថិតនៅក្នុងតំបន់១ និង តំបន់២ ចំនួន ៤,២៧ ហ.ត និងក្រៅតំបន់ទាំងពីនេះ ចំនួន ៤៨,៤៤ ហ.ត មានតួនាទីសំរាប់នាំចរន្តអគ្គិសនីពីអគារថាមពល នៃទំនប់ទី១ និងទី២ មកផ្គត់ផ្គង់ឱ្យអនុស្ថានីយ៍អូរសោម ។ ប្រព័ន្ធខ្សែចម្លង នៃគំរោងវារីអគ្គិសនីស្ទឹងអាតៃនេះ ត្រូវឆ្លងកាត់តំបន់ អភិរក្សព្រៃឈើ ភ្នំក្រវាញ និងព្រៃការពារដងទង់របស់រដ្ឋបាលព្រៃឈើសហការជាមួយអង្គការ CI និង Wildlife Alliance ព្រមទាំងឆ្លងកាត់ដីបុស្សរបស់ប្រជាពលរដ្ឋចំណុចស្ទឹងតាចាន់ ភូមិឆាយលូក ឃុំអូរសោមទៀតផង ។

ចំពោះផលប៉ះពាល់អវិជ្ជមាន ដែលកកើតចេញពីសកម្មភាពរបស់គំរោងនេះតាមដំណាក់កាលនិមួយៗមានពណ៌នាតាមលំដាប់លំដោយខាងក្រោមនេះ:

### ៨.២.១ ដំណាក់កាលរចនា-មុនសាងសង់គំរោង (Project Design-Before Construction)

ក្នុងដំណាក់កាលនេះគំរោងពុំមានសកម្មភាព ដែលបង្កឱ្យមានផលប៉ះពាល់ធំដុំឡើយ ។ ដំណាក់កាលរចនាគំរោងគឺមានអ្នកជំនាញការតាមផ្នែកបច្ចេកទេសធ្វើការសិក្សាស្រាវជ្រាវទៅតាមជំនាញបច្ចេកទេសរៀងៗខ្លួនដើម្បីរចនាប្លង់គំរោងតាមសមាសភាពនីមួយៗ។ ការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ ដល់ធនធានបរិស្ថាន និងសង្គមរួមមានដូចតទៅ :

**ក.ធនធានរូបសាស្ត្រ**

សកម្មភាពការងារក្នុងដំណាក់កាលនេះ គឺជាការសិក្សាលើស្ថានភាពជាក់ស្តែង ដើម្បីកំណត់ឱ្យបាននូវគន្លងខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥ គ.វ៉ ទីតាំងបង្គោលភ្លើង ទីតាំងដាក់ត្រង់ស្វូរ ក្នុងអនុស្ថានីយ៍អូរសោម និងសណ្ឋានដី នៅតាមទីតាំងគន្លងខ្សែ ពីអគារថាមពលទី១ និងពីអគារថាមពលទី២ ដល់អនុស្ថានីយ៍អូរសោម ត្រង់ចំណុចស្ទឹងតាចាន់ ភូមិឆាយលូក ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ហើយការវិភាគ និងគំនូសប្លង់ភាគច្រើន គឺធ្វើនៅប្រទេសចិន។ ដូចនេះការប៉ះពាល់ដល់ធនធានបរិស្ថានធនធានធម្មជាតិគឺមានតិចតួចណាស់ តែការសិក្សានេះនឹងអាចប៉ះពាល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋផងដែរ ក្នុងការខ្លាចបាត់បង់ដីធ្លី និងខ្លាចរលំបង្គោលភ្លើងឆក់ផងដែរក្នុងដំណាក់កាលនេះ ។

Draft

## ៩.មជ្ឈដ្ឋានជីវសាស្ត្រ

### ៩.១ ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ

នៅក្នុងដំណាក់កាលរចនានេះមិនមានប៉ះពាល់ដល់មច្ឆជាតិដែលនៅក្នុងអូរ ឬស្ទឹងទេ ។

### ៩.២ ព្រៃឈើការពារ /តំបន់ការពារ /ឧទ្យានជាតិ

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលរចនាសម្ព័ន្ធគំរោងនេះ អាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោងដែលស្ថិតនៅក្នុងតំបន់ព្រៃការពារភ្នំក្រវាញ និងព្រៃការពារដងទង់បន្តិចបន្តួចដែរ ដោយសារសកម្មភាពសិក្សា ដូចជាមានសំឡេងអ៊ូអរក្នុងការត្រួសត្រាយព្រៃធ្វើដំណើរក្នុងការសិក្សា ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃដើម្បីមិនឱ្យរំខានសត្វព្រៃតែ ។ ម្យ៉ាងទៀតក្រុមសិក្សាបានបោះទីតាំងតែមួយកន្លែងដើម្បីបន្ថយការកាប់ព្រៃ និងរំខានសត្វព្រៃ ។

ក្រុមហ៊ុនបានធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធដើម្បីធ្វើការសិក្សាដោយមិនឱ្យរំខានជំរក និងការរស់នៅរបស់សត្វព្រៃ ក្នុងតំបន់ការពារ-អភិរក្សភ្នំក្រវាញ និងព្រៃការពារដងទង់ឡើយ ។

ក្រុមហ៊ុនបានត្រាយតែមែកឈើតូចៗ ដើម្បីធ្វើដំណើរចូលកន្លែងសិក្សាតែប៉ុណ្ណោះ ដើម្បីទុកឱ្យព្រៃនោះអាចលូតលាស់ឡើងវិញ (តាមលក្ខណៈបច្ចេកក្នុងការថែរក្សា ព្រៃការត្រាយមែកឈើអាចធ្វើឱ្យដើមលូតលាស់កាន់តែប្រសើរជាងមុន) ។

### ៩.៣ ធនធានព្រៃឈើ និងជំរកសត្វព្រៃ

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់គ្រោងរចនានេះ អាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោងដោយសារការត្រួសត្រាយព្រៃ និងសំឡេងអ៊ូអររបស់បុគ្គលិក-កម្មករក្នុងការធ្វើដំណើរសិក្សានៅចំណុចអនុស្សាវរីយ៍អូរសោម និងនៅតាមទីតាំងមួយចំនួនតាមគន្លងខ្សែបញ្ជូនតង់ស្យុងខ្ពស់១១៥គ.វ៉ ពីអគារថាមពលមកអនុស្សាវរីយ៍អូរសោម ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃទេ ។

ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធដើម្បីធ្វើការសិក្សាដោយមិនឱ្យរំខានជំរក និងការរស់នៅរបស់សត្វព្រៃនៅក្នុងតំបន់គំរោងឡើយ ។

ក្រុមហ៊ុនបានត្រាយតែបែកឈើតូចៗដើម្បីធ្វើដំណើរចូលកន្លែងសិក្សាប៉ុណ្ណោះ ដើម្បីទុកឱ្យព្រៃនោះអាចលូតលាស់ឡើងវិញបាន ។

### ៩.៤ ជីវសាស្ត្រសត្វព្រៃ

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលរចនាគំរោងនេះមានការប៉ះពាល់តិចតួចដល់ជីវសាស្ត្រសត្វព្រៃខ្លះដែរ ដោយសារសកម្មភាពសិក្សាគំរោងនេះគឺអាចផ្អើលសត្វពេលដែលដើរសិក្សាតំរង់ទិសរកទីតាំងគំរោង ។

Draft

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនបានធ្វើការសិក្សាតែពេលថ្ងៃដើម្បីមិនឱ្យរំខានសត្វព្រៃទេ ពីព្រោះសត្វព្រៃភាគច្រើនរកស៊ីពេលយប់ ហើយការបោះជំរុំតែមួយកន្លែងតែមួយកន្លែងតែប៉ុណោះក្នុងពេលសិក្សានេះ ។

## គ.ធនធានសេដ្ឋកិច្ច-សង្គម

### គ.១ ការប្រើប្រាស់ដី និង ការតាំងលំនៅដ្ឋានឡើងវិញ

➢ ហេតុប៉ះពាល់អវិជ្ជមាន

ដំណាក់កាលគ្រោងរចនានេះ មានការប៉ះពាល់តិចតួចដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋដោយសារខ្លាចបាត់បង់ដីស្រែចំការ និង លំនៅដ្ឋាន និងដីបុស្ស ធ្វើឱ្យពូកគេងាយចាញ់បោកជនឆ្លៀតឱកាស កេងយកដីរបស់ពូកគាត់ រួចរំលោភយកដីព្រៃកាពារទាំងនេះជាកម្មសិទ្ធិ ។

ក្នុងដំណាក់កាលរចនាគំរោងនេះមានជនឆ្លៀតឱកាសដើរបំផុសប្រជាពលរដ្ឋ ក្នុងគោលបំណងចង់បានដីធ្វើចំការកៅស៊ូ ឬចំការផ្សេងៗព្រោះដីតំបន់នេះមានអំណោយផលដល់ដំណាំកៅស៊ូ ដូចជាគេបំផុសថាដីឃុំអូរសោមត្រូវលិច ឬប្រយ័ត្នរលំបង្គោលដាច់ខ្សែ និងឆក់ ដូចនេះត្រូវគេចចេញពីតំបន់ពីភូមិនេះដោយទាមទាឱ្យរដ្ឋាភិបាល និងក្រុមហ៊ុនរកដីថ្មីដែលជាហេតុធ្វើឱ្យគំរោង មានការរាំងស្ទះយឺតយាវក្នុងការអនុវត្តន៏ឱ្យបានសំរេចទៅតាមពេលវេលាដែលបានគ្រោងទុក ។

បន្ថែមពីលើនេះទៀតមានការប្រមូលទិញដីពីប្រជាពលរដ្ឋក្នុងតំបន់ដើម្បីធ្វើកសិកម្ម ព្រោះដីមានជីជាតិល្អ រួចហើយអាចមិនសុខចិត្តពីម្ចាស់ដីដែលជាមន្ត្រីថ្នាក់ខ្ពស់ ឬថ្នាក់ឧកញ៉ា មិនអនុញ្ញាតិឱ្យសង់បង្គោល និងខ្សែភ្លើងនេះកាត់ដីរបស់ខ្លួន ។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការទប់ស្កាត់រាល់ការបំផុសចលនាប្រជាពលរដ្ឋ របស់ជនឆ្លៀតឱកាស កេញចំណេញ ដើម្បីទាមទារដីថ្មី និងសំណងផ្សេងៗ ឱ្យបានទាន់ពេលវេលា ។

ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងក្រសួងពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវអង្កេតដីកម្មសិទ្ធិជាក់ស្តែងក្នុងភូមិ-ឃុំនៅក្នុងតំបន់គំរោង ។

ក្រុមហ៊ុនបានធ្វើការផ្សព្វផ្សាយដល់សាធារណៈជនស្ថាប័នពាក់ពន្ធ័អំពីគំរោង និងអំពីសំណងនៃការប៉ះពាល់ដោយសារគំរោងនេះ ។

ក្រុមហ៊ុនបានរៀបចំធ្វើផែនការការតាំងលំនៅដ្ឋានថ្មីឡើងវិញរបស់គ្រួសារដែលប៉ះពាល់ដោយសារគំរោង ។

ក្រុមហ៊ុនបានធ្វើការដោះស្រាយជាមួយថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ដើម្បីរកដំណោះស្រាយល្អក្នុងការអនុវត្តន៏គំរោងនេះ ។

### គ.២ ការរស់នៅ និងមុខរបររបស់ សហគមន៍មូលដ្ឋាន

➢ ហេតុប៉ះពាល់អវិជ្ជមាន

ប្រជាជននៅក្នុងតំបន់មានការភយ័ខ្លាចមានគ្រោះថ្នាក់ដោយចរន្តអគ្គិសនី និងខ្លាចរលំបង្គោលភ្លើង ឬដាច់ខ្សែភ្លើងនាំឱ្យពូកគេ ងាយចាញ់បោកជនឱកាសនិយម ធ្វើឱ្យគាត់មិនគិតប្រកបរធ្វើស្រែ ចំការនាំឱ្យបាត់ចំណូលរបស់គាត់ ។

ក្នុងដំនាក់កាលមុនសាងសង់គំរោងនេះ ប្រជាជនមួយចំនួនមានការភ័យខ្លាចរដ្ឋាភិបាលរឹបអូសដីរបស់ពូកគេយកឱ្យក្រុមហ៊ុនធ្វើការអភិវឌ្ឍន៏គំរោងនេះ ។

Draft

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនបានសិក្សារៀបចំធ្វើផែនការតាំងលំនៅថ្មីជូនប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារគំរោងរួចហើយ ។

ក្រុមហ៊ុនបានធ្វើការផ្សព្វផ្សាយតាមរយៈក្រុមការងារសិក្សា វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមៈដោយជូនដំណឹងដល់សាធារណៈជន ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋជាមុនអំពីគោលបំណង ជាក់ស្តែងរបស់រាជរដ្ឋាភិបាលសំរាប់ការអភិវឌ្ឍន៍គំរោងនេះនៅពេលអនាគត និងការដោះស្រាយផលប៉ះពាល់ជូនគ្រួសារដែលនឹងត្រូវរងផលប៉ះពាល់ដោយសារគំរោងនេះឱ្យបានសមស្របទៅតាមទីផ្សារទៀតផង ។

ក្រុមហ៊ុនបានព្យាយាមគ្រោងប្លង់គេចចេញពីតំបន់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋចំណុចស្ទឹងតាចាន់ ភូមិឆាយលូក ។ ចំពោះគុណភាពបង្គោល និងខ្សែក្រុមហ៊ុនបានគ្រោងគុណភាពស្តង់ដាអន្តរជាតិមិនងាយរលំ និងដាច់ងាយៗក្នុងលក្ខខណ្ឌព្យុះភ្លៀងធម្មតាទេ ។

**គ.៣ ប្រពៃណី វប្បធម៌ និងសាសនា**

នៅក្នុងដំណាក់កាលនេះមិនមានប៉ះពាល់ដល់ប្រពៃណី វប្បធម៌ និងសាសនានៅឡើយទេ ដោយសារតែស្ថិតនៅក្នុងការសិក្សា និងរចនា ។

**គ.៤ ការផ្គត់ផ្គង់ទឹកស្អាត**

នៅក្នុងការដំណាក់កាលរចនានេះ មិនមានប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងមូលដ្ឋាននោះទេ ។

**គ.៥ តំបន់ទេសចរណ៍ /រមណីយដ្ឋាន /ទីកន្លែងកំសាន្ត**

នៅតំបន់គំរោងជាតំបន់ដាច់ស្រយាលពុំទាន់មានរមណីយដ្ឋាន និងទីកន្លែងកំសាន្តនៅឡើយទេ ។

**គ.៦ ផ្លូវគមនាគមន៍**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលនេះមានគ្រោះថ្នាក់ដល់អ្នកសិក្សាឬធ្វើឱ្យស្ទះការងារសិក្សាប្លង់រចនាគំរោងជាមធ្យម ដោយសារស្ថានភាពផ្លូវធ្វើចរាចរទ្រុឌទ្រោម តូចចង្អៀត ខូចខាត ផ្លូវចំណោត ហើយកន្លែងគ្មានផ្លូវចូលទៀតផង ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានរកអ្នកនាំផ្លូវដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ក្នុងមូលដ្ឋានតំបន់គំរោង ។

ក្រុមហ៊ុនបានជួលរថយន្តដែលមានសុវត្ថិភាពល្អក្នុងការសិក្សាគំរោងនេះ ។

**គ.៧ សុខភាពសាធារណៈ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលរចនាគំរោងនេះបង្កឱ្យមានការប៉ះពាល់ជាមធ្យមដល់សុខមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុនដោយសារតំបន់ខ្លះរបស់គំរោងជាតំបន់កើតជំងឺគ្រុនចាញ់គ្រុនសន្និបាត ។ល។ បន្ថែមពីនេះទៀតមានតំបន់គ្រាប់មីនមួយចំនួននៅក្នុងតំបន់គំរោងដែលអាចធ្វើឱ្យគ្រោះថ្នាក់ដល់ក្រុមសិក្សាគំរោង ។

ម្យ៉ាងទៀតប្រជាពលរដ្ឋអាចឆ្លងជំងឺកាមរោគពីបុគ្គលិក-កម្មករ ដែលមកពីកន្លែងផ្សេងៗ និងជំងឺអេដស៍ជាដើម ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ។

ក្រុមហ៊ុនបានត្រៀមថ្នាំបង្ការដើម្បីការពារ និងព្យាបាលជំងឺទាំងនោះ ដល់បុគ្គលិក-កម្មករ ។

ក្រុមហ៊ុនបានសហការជាមួយកងយុទ្ធពលខេមរៈភូមិន្ទ ធ្វើការរាវរកគ្រាប់មិននៅតាមផ្លូវដែលនឹងត្រូវដើរសិក្សា ហើយក្រុមនេះបានបោះទីតាំងជាប្រចាំនៅការដ្ឋានក្នុងតំបន់គំរោងទៀតផង ។

### ត.៨ សោភ័ណ្ឌភាព /ទេសភាព

សោភ័ណ្ឌភាព /ទេសភាពនៅក្នុងតំបន់គំរោងក្នុងដំណាក់កាលរចនានេះ ស្ថិតនៅបែបធម្មជាតិនៅឡើយពុំទាន់ប៉ះពាល់ទេ ។

### ត.៩ ហានិភ័យ (Risk)

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់កាលនៃការសិក្សានេះ អាចមានគ្រោះថ្នាក់ ដោយសារតំបន់នោះមិនដែលស្គាល់ភូមិសាស្ត្រ ដូចជាមានគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបង្កប់ក្នុងដីនៃតំបន់គំរោង ។

អាចគ្រោះថ្នាក់ដោយសារសត្វសាហាវដូចជា ខ្លាឃ្មុំ ពស់ពីស ខ្លា ដែលមាននៅក្នុងតំបន់អូរសោម ស្រុកវាលវែងនេះ ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានធ្វើការទាក់ទងយ៉ាងជិតស្និតជាមួយអាជ្ញាធរមានសមត្ថកិច្ច ប្រជាពលរដ្ឋមូលដ្ឋាន និងកងយុទ្ធពលខេមរៈភូមិន្ទក្នុងការដោះស្រាយអំពីគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះទាំងនេះហើយក្រុមនេះបានបោះទីតាំងជាប្រចាំនៅការដ្ឋានក្នុងតំបន់គំរោងទៀតផង ។

ចំពោះបញ្ហាការពារសត្វសាហាវ ដូចជា ខ្លាឃ្មុំ ពស់ ខ្លា នោះក្រុមហ៊ុនបានធ្វើដំណើររួមគ្នា និងសហការជាមួយអង្គភាពប្រដាប់អាវុធ ដើម្បីការពារនៅពេលជួបប្រទះហេតុការណ៍ដែលបង្កឡើងដោយសត្វសាហាវខាងលើនេះ ។

### ៨.២.២ ដំណាក់កាលសាងសង់គំរោង (Project Construction)

ក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលមួយមានរយៈពេលរហូតដល់ ២៤ខែ (យោងតាមរបាយការណ៍របស់ក្រុមហ៊ុន) ហើយនឹងមានសកម្មភាពសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងជាច្រើន ដូចជា ការឈូសឆាយដី ការសាងសង់ផ្លូវចូលក្នុងការដ្ឋាន អគារ ឬសំណង់អគ្គិសនី អគារការិយាល័យ ផ្ទះ បុគ្គលិក-កម្មករ ។ ព្រមទាំងមានការសាងសង់បង្គោល និងខ្សែចរន្តនាំភ្លើងពីអគារផលិតថាមពលទាំងពីរទៅអនុស្ថានីយ៍អូរសោម ។ សកម្មភាពការងារទាំងនេះនឹងអាចបង្កឱ្យមានការប៉ះពាល់អវិជ្ជមានសំខាន់ៗ មួយចំនួនមានដូចតទៅ :

**ក.ធនធានរូបសាស្ត្រ**

**ក.១ សណ្ឋានដី និងឋានលេខា** ( Morphology and Topography)

➢ ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់នៃការសាងសង់គំរោងនេះអាចនឹងបណ្តាលឱ្យប្រែប្រួលសណ្ឋានដី និងឋានលេខាក្នុងទីតាំងគំរោង ដោយសារសកម្មភាពឈូសឆាយ និងពង្រាបដីស្រទាប់លើដែលអាចនាំឱ្យមានការហូរច្រោះទៀតផង ។

➢ **វិធានការកាត់បន្ថយ**

ខ្សាច់ ថ្ម ក្រុមហ៊ុនបានទិញពីក្រុមហ៊ុនសំណង់ក្នុងតំបន់ ដែលមានច្បាប់ត្រឹមត្រូវ ។

ក្រុមហ៊ុនបានធ្វើការសាងសង់ជាទ្រង់ទ្រាយធំ តែរដូវប្រាំងដើម្បីទប់ស្កាត់ការហូរច្រោះដែលនាំឱ្យខូចសណ្ឋានដីនៅរដូវវស្សា ក្រុមហ៊ុនក៏បានពង្រាបដីនៅស្មើដូចសណ្ឋានដើមវិញនៅពេលដែលសាងសង់ហើយ ។

Draft

### ក.២ ប្រព័ន្ធជលសាស្ត្រ (ប្រឡាយ- អូរ-ស្ទឹង) (Hydrologycal System)

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះប៉ះពាល់ជាមធ្យមដល់គុណភាពទឹកដោយសារសកម្មភាពសាងសង់ដែលបណ្តាលមកពីការហូរច្រោះដីស្អុយតាមបង្គោលភ្លើង និងការងារដីនៅអនុស្សាវរីយ៍អូរសោមចូលទៅក្នុងអូរស្ទឹងដែលស្ថិតក្បែរកន្លែងសាងសង់នេះ ។

ព្រមទាំងប៉ះពាល់ដល់គុណភាពទឹកដោយសារការបោះបង់កាកសំណល់រឹង និងការបង្ហូរកាកសំណល់រាវពីកន្លែងរស់នៅរបស់បុគ្គលិក-កម្មករនៃគំរោង បង្កន់ ការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ និងការមុជទឹកសំអាតខ្លួនប្រាណ ការបោកគក់ របស់បុគ្គលិក-កម្មករដែលនៅក្បែរប្រភពទឹកនឹងធ្វើឱ្យខូចគុណភាពទឹកអូរ និងស្ទឹងទាំងនោះ ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ខ្លាំងដោយយកដីស្អុយដែលនៅក្បែរប្រភពទឹកចេញ និងកិនបង្ហាប់ ដាំស្មៅនៅលើដីនៅកន្លែងដែលបានសាងសង់បង្គោលរួចហើយឱ្យបានមុនពេលរដូវភ្លៀងធ្លាក់ ។

ក្រុមហ៊ុនត្រូវសាងសង់នៅរដូវប្រាំង ដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋានដីផ្សេងៗដែលអាចហូរចូលស្ទឹង ។

ក្រុមហ៊ុនបានអប់រំដល់បុគ្គលិកកម្មករអំពីការបោះបង់កាកសំណល់រឹង-រាវ ជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិល នៅលើដីដែលបណ្តាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គំរោង ។

ក្រុមហ៊ុនបានគ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទមិនឱ្យបោះចោល និងបង្ហូរចូលទៅក្នុង ឬក្បែរទឹកស្ទឹង ឬអូរឡើយដូចជាសង់បន្ទប់ទឹកនិងបង្កន់អនាម័យឆ្ងាយពីស្ទឹងមានអាងសិបទិកត្រឹមត្រូវមានកន្លែងទុកដាក់សំណល់រឹងល្អតាមបច្ចេកទេស ។

### ក.៣ ការហូររច្រោះដី និងគុណភាពដី

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលសាងសង់មានផលប៉ះពាល់ជាមធ្យម ដែលបណ្តាលមកពីការហូរច្រោះដី ដោយសារការឈូសឆាយដីស្រទាប់លើដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង(បង្គោលភ្លើង និងអនុស្សាវរីយ៍ដោយសារការធ្វេសប្រហែស មិនគោរពតាមបទដ្ឋានការងារដីដែលធ្វើឱ្យមានការហូរច្រោះដី ជាពិសេសនៅរដូវវស្សា ។

ម្យ៉ាងទៀតបានបង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញតំបន់បង្គោលភ្លើងដោយចោលដីស្អុយ (ដីដែលជីកពីស្រទាប់ក្រោមគ្មានជីវជាតិ)ដែលធ្វើឱ្យបាត់បង់ជីវជាតិរបស់ដីស្រទាប់លើនៅតំបន់នោះ ហើយអាចបណ្តាលឱ្យមានការហូរច្រោះដីស្អុយនេះ ទៅគ្របពីលើសណ្ឋានដីតំបន់ជុំវិញនោះ ឬហូរចូលប្រភពទឹកប្រើប្រាស់ទៀតផង ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារបច្ចេកទេស ។

ក្រុមហ៊ុនបានពង្រាបដីឬថ្មដែលចាក់ចោល ដោយយកដីមានជីវជាតិលប់ពីលើ និងធ្វើការសហការណ៍ជាមួយរដ្ឋអំណាចមូលដ្ឋាន និងប្រជាពលរដ្ឋឱ្យបានល្អដែលពួកគាត់អាចទទួលយកបាន ។

Draft

### ក.៤ ការរញ្ជួយដី

នៅការសាងសង់ខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥គ.វ៉ នេះ មិនមានការបំផ្ទុះផ្លូវដែលបង្កឱ្យមានការរញ្ជួយ និងគ្រោះដល់ប្រជាពលរដ្ឋនៅជុំវិញតំបន់គំរោងនោះទេ ។

### ក.៥ ការបំពុលទឹក (ទឹកលើដី /ទឹកក្រោមដី)

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះប៉ះពាល់ជាមធ្យមដល់គុណភាពទឹកអូរ ស្ទឹងដោយសារការសាងសង់បង្គោលខ្សែ និងការងារសាងសង់ដទៃទៀតបណ្តាលមកពីការខួង ឬការងារដី ការងារបេតុង និងការងារគ្រឹះដោយសារការដ្ឋានសាងសង់នេះស្ថិតនៅជិតប្រភពទឹកទាំងនោះ ។

ម្យ៉ាងទៀត ប៉ះពាល់ដល់គុណភាពទឹកស្ទឹងដោយសារកាកសំណល់រឹង-រាវមកពីការបោះចោលកាកសំណល់ផ្ទះបាយ បង្គន់ដែលសង់គ្មានបច្ចេកទេស និងការខ្វះខាតបង្គន់អនាម័យគ្រប់គ្រាន់សំរាប់បុគ្គលិកកម្មករគំរោង និងការបោះកាកសំណល់សម្ភារសំណង់ដោយបុគ្គលិក-កម្មករក្រុមហ៊ុន (ការហៀរឬលេចជាតិប្រេងពីគ្រឿងចក្រ រថយន្ត បាវស៊ីម៉ងត៍ បាវ ឬស្បោងច្រកសារធាតុគីមីផ្សេងទៀត ។ល ។) ចំពោះទឹកក្រោមដីប៉ះពាល់តិចតួចទេ តាមរយៈទឹកភ្លៀងនាំយកនូវសារធាតុគីមីនៅក្នុងបេតុង និងប្រេងម៉ាស៊ីនដែលកំពប់នៅលើដីទៅដល់ស្រទាប់ទឹកក្រោមដី ។

បន្ថែមពីលើនេះទៀតមានការហូរច្រោះដី ដោយសារការកាប់ឆ្ការនូវគំរបរុក្ខជាតិ ដូចជាការកាប់ព្រៃ ៣០ម. តាមគន្លងខ្សែ ការងារដីដែលមិនបានពង្រាបដីស្អុយ និងមិនបានគ្រប់គ្រងការងារដីទាំងនេះ ឱ្យបានល្អនៅតាមបទដ្ឋានបច្ចេកទេស ដែលហេតុនាំឱ្យមានការហូរច្រោះដីដោយសារទឹកភ្លៀង ហូរអូរ ឬស្ទឹង ដែលនៅក្បែរៗនោះ ។

➢ **វិធានការកាត់បន្ថយ**

ការឈូសឆាយទ្រង់ទ្រាយធំក្រុមហ៊ុនមិនធ្វើនៅរដូវវស្សាទេ ។

ក្រុមហ៊ុនបានធ្វើការអប់រំបុគ្គលិក-កម្មករគំរោងឱ្យយល់ដឹងអំពីអនាម័យ ស្គាល់នូវកន្លែងទុកដាក់សំរាម ដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់គំរោង ។

ក្រុមហ៊ុនបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យបន្ទប់ទឹកឱ្យបានឆ្ងាយពីមាត់អូរស្ទឹងព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពល្អមិនឱ្យប៉ះពាល់បរិស្ថានជុំវិញ ។

ក្រុមហ៊ុនបានបោះផ្លាកសញ្ញាតំបន់គំរោង ដោយមានអក្សរខ្មែរ និង ចិនអំពីការបំពុលទឹក ។

ក្រុមហ៊ុនបានសាងសង់អាងសិបទិកតាមបច្ចេកទេសសំរាប់ទឹកកខ្វក់ចេញពីការិយាល័យ បន្ទប់ទឹក បង្គន់ ផ្ទះបុគ្គលិកដែលស្នាក់នៅបណ្តោះអាសន្នក្នុងពេលសាងសង់គំរោង ។

ក្រុមហ៊ុនបានសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។

ក្រុមហ៊ុនបានប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានគុណភាពល្អមិនលេចហូរជាតិប្រេង ឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គំរោង ។

Draft

ក្រុមហ៊ុនត្រូវដាំស្មៅតាមកន្លែងដែលសាងសង់បង្គោលរួចហើយ និងដាំស្មៅនៅកន្លែងដែលកាប់សំអាតគន្លង ដែលគ្មានស្មៅឬឈើដុះដើម្បីការពារការហូរច្រោះ និងគុណភាពទឹក ។

ក្រុមហ៊ុនមិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាត ឬបង្អាក់ការលូតលាស់របស់ដើមឈើនោះទេ ។

### ក.៦ ការបំពុលខ្យល់

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះ បានបំពុលខ្យល់ដោយសារការដុតព្រៃឈើ ដើមឈើ កំទេចឈើដើម្បីសំអាតការដ្ឋាន និងនៅតាមគន្លងខ្សែ ហើយផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសម្ភារសំរាប់ការងារសាងសង់ និងការហុយធូលីដីពីមធ្យោបាយដឹកជញ្ជូនទាំងនេះរបស់គំរោង ។

ម្យ៉ាងទៀត អាចបំពុលខ្យល់ដោយសារភ្លើងឆេះព្រៃបណ្តាលមកពីការធ្វេសប្រហែសពីបុគ្គលិក-កម្មករគំរោង ។

បន្ថែមពីលើនេះទៀត អាចនឹងបំពុលខ្យល់ដោយសារការប្រើប្រាស់សារធាតុគីមីដើម្បីសំលាប់ព្រៃឈើ ឬបង្អាក់ការលូតលាស់របស់ដើមឈើ ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនមិនដុតព្រៃឈើទាំងអស់នៃតំបន់ដែលសំអាតតាមគន្លងខ្សែ ៣០ម.នេះទេ ក្រុមហ៊ុនធ្វើការសហការណ៍ជាមួយរដ្ឋបាលព្រៃឈើ និងម្ចាស់សហគមន៍ព្រៃឈើដើម្បីធ្វើការដោះស្រាយដោយប្រើឱ្យអស់លទ្ធភាពក្នុងការកែច្នៃឈើទាំងនេះ ដែលអាចធ្វើទៅបានហើយអាចបានចំណូលរដ្ឋថែមទៀតផង ។

ក្រុមហ៊ុនបានប្រើប្រាស់ម៉ាស៊ីន គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានការបញ្ចេញផ្សែងតិចដើម្បីកាត់បន្ថយការបំពុលខ្យល់ក្នុងតំបន់នោះ ។

ក្រុមហ៊ុនបានត្រៀបឧបករណ៍ពន្លត់អគ្គិភ័យ និងមានកន្លែងបូមទឹកគ្រប់គ្រាន់នៅពេលមានអគ្គិភ័យ ។

ក្រុមហ៊ុនមិនប្រើប្រាស់សារធាតុគីមីផ្សេងៗក្នុងការសំអាតព្រៃឈើ ដើមឈើនៅតាមគន្លងខ្សែនេះទេ ។

### ក.៧ ការបំពុលដី

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធខ្សែចម្លង មានការបំពុលដី ដោយសារការកំពប់នៃប្រេងឥន្ធនៈ ការកំពប់នៃសារធាតុគីមី និងសំណល់រឹង-រាវគ្រប់ប្រភេទទៅលើដីដូចជាៈកាកសំណល់ចេញពីឬលេចធ្លាយពីគ្រឿងចក្រនិងរថយន្តគ្រប់ប្រភេទក្នុងដំណើរការគំរោងនេះ ព្រមទាំងកាកសំណល់ចេញពីផ្ទះបាយផងដែរ ។

បង្កឱ្យមានផលប៉ះពាល់ដល់ស្រទាប់ដីខាងលើផងដែរ ដោយសារការចាក់ដីស្អុយដែលមិនបានដឹកចេញពីតំបន់សាងសង់បង្គោលភ្លើងនាំឱ្យដីនេះហូរទៅលើដីប្រជាពលរដ្ឋរស់នៅក្បែរកន្លែងនោះ ដែលធ្វើឱ្យដីនោះគ្មានជីជាតិ ។

ជាងនេះទៅទៀត បង្កឱ្យមានការបំពុលដីដោយសារការប្រើប្រាស់សារធាតុគីមីផ្សេងៗក្នុងការសំអាត ឬបង្អាក់ការលូតលាស់របស់ឈើធ្វើឱ្យធ្លាក់ទៅលើដី ។ ការឈូសកាប់ព្រៃស្រទាប់លើនៅតាមតំបន់ទីជំរាលជាដើម ធ្វើឱ្យមានការហូរច្រោះដីនៅរដូវវស្សា និងមានសំណឹកដោយសារខ្យល់នៅរដូវប្រាំងដែលជាហេតុបណ្តាលឱ្យមានការបាត់បង់គុណភាពដីផងដែរ ។

Draft

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនបានសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវមិនឱ្យកំពប់ ឬជ្រាបចូលដីទេ។

ក្រុមហ៊ុនត្រូវពង្រាបដីឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើ រួចដាំស្មៅឡើងវិញ ក្នុងតំបន់សាងសង់បង្គោលភ្លើងនេះ (១៥ម x ១៥ម) ដោយធ្វើការសហការណ៍ជាមួយរដ្ឋអំណាច និងប្រជាពលរដ្ឋមូលដ្ឋាន និងស្ថាប័នជំនាញពាក់ព័ន្ធឱ្យបានល្អ។

ក្រុមហ៊ុនបានគ្រប់គ្រងកាកសំណល់រឹង-រាវគ្រប់ប្រភេទឱ្យបានត្រឹមត្រូវដូចជា: ចាត់វិធានការយ៉ាងតឹងរឹងមិនឱ្យចាក់ប្រេងម៉ាស៊ីនចាស់ៗ (ប្រេងបាត) ចោលទៅលើដី។

ក្រុមហ៊ុនត្រូវធ្វើការដាក់ទណ្ឌកម្មដល់អ្នកដែលប្រព្រឹត្តដូចជា ស្តីបន្ទោស ពិន័យ ឬការបណ្តេញពីការងារជាដើម ។

ក្រុមហ៊ុនមិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាតឬ បង្អាក់ការលូតលាស់របស់ឈើនោះទេ។

ក្រុមហ៊ុនត្រូវដាំស្មៅនៅតាមគន្លងខ្សែដែលមិនមានស្មៅ ឬឈើដុះក្នុងតំបន់ដីសាធារណៈឯកជនរបស់រដ្ឋដោយសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលព្រៃឈើក្នុងតំបន់។

**ក.៨ សំលេង និងរំញ័រ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់គំរោងនេះមានការរំខានដោយសំលេង និងរំញ័រខ្លាំងដោយសារសកម្មភាព សិក្សាគំរោង ដូចជាការខួងដីសម្រាប់ធ្វើគ្រឹះបង្គោលភ្លើង ដែលប្រើម៉ាស៊ីនខួង, ការដឹកជញ្ជូនបុគ្គលិក-កម្មករ និងសម្ភារដោយយានយន្ត និងសំលេងអ៊ូអរនៃបុគ្គលិក-កម្មករសាងសង់ទាំងនោះ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានប្រើម៉ាស៊ីនខួងដីដែលមានកំរិតរញ្ជួយនិងសំឡេងតិច ដើម្បីកាត់បន្ថយសំឡេងនិងរំញ័រដែលរំខានដល់សត្វព្រៃ។

ក្រុមហ៊ុនបានអប់រំកម្មកររបស់គំរោងមិនឱ្យមានការស្រែក ឬជជែកគ្នាខ្លាំងៗរំខានដល់សត្វព្រៃ ។

**ខ.ធនធានជីវសាស្ត្រ**

**ខ.១ ជីវសាស្ត្រ ដែលរស់នៅក្នុងទឹក/មច្ឆជាតិ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់ហេដ្ឋារចនាសម្ព័ន្ធនេះ ប៉ះពាល់ជាមធ្យមដល់គុណភាពទឹក អូរ ស្ទឹង នៅក្បែរការដ្ឋានសាងសាង់បង្គោលភ្លើង របស់គំរោង ដោយសារការងារដី ការងារបេតុង ដែលមានដីស្អុយ(ដីដែលជីកពីស្រទាប់ក្រោមគ្មានជីវជាតិ) ហូរច្រោះដោយសារភ្លៀង និងការកំពប់នូវសម្ភារសំណង់ ធ្វើឱ្យល្អក់ទឹកបណ្តាលឱ្យពុលដល់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹក នៃអូរ ស្ទឹងទាំងនេះ ។

ម្យ៉ាងទៀត ប៉ះពាល់ដល់ជីវសាស្ត្ររស់នៅក្នុងទឹកដែលបណ្តាលមកពីសកម្មភាពសាងសង់គំរោង និងការបំពុលទឹក ដោយសារកាកសំណល់រឹង-រាវចេញពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនត្រូវដាំស្មៅតាមកន្លែងដែលសាងសង់បង្គោល និងដាំស្មៅនៅកន្លែងដែលកាប់សំអាតគន្លងដែលគ្មានស្មៅ ឬឈើដុះ ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក។

Draft

ក្រុមហ៊ុនបានអប់រំដល់បុគ្គលិក-កម្មករអំពីការបោះបង់កាកសំណល់រឹង-រាវ ជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិលនៅលើដី និងក្នុងទឹកនៅក្នុងតំបន់គំរោង ។

ក្រុមហ៊ុនបានគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទនៅទីតាំងដែលមានសុវត្ថិភាព ។

**៦.២ ព្រៃឈើការពារ /តំបន់ការពារ /ឧទ្យានជាតិ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ដំណាក់កាលសាងសង់គំរោងនេះ អាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ដែលស្ថិតនៅក្នុងតំបន់ព្រៃការពារភ្នំក្រវាញ និងព្រៃកាពារដងទង់បន្តិចបន្តួចដែរ ដោយសារសកម្មភាពសាងសង់ដូចជាមានសំឡេងអ៊ូអរក្នុងការកាប់ឈើតាមគន្លងខ្សែ ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃដើម្បីមិនឱ្យរំខានសត្វព្រៃតែ ។ ម្យ៉ាងទៀតក្រុមសិក្សាបានបោះទីតាំងតែមួយកន្លែង ដើម្បី បន្ថយការកាប់ព្រៃ និងរំខាន សត្វព្រៃ។

ក្រុមហ៊ុនបានធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធដើម្បីធ្វើការសិក្សាដោយមិនឱ្យរំខានជំរក និងការរស់នៅរបស់សត្វព្រៃ ក្នុងតំបន់ការពារ-អភិរក្សភ្នំក្រវាញ និងព្រៃការពារដងទង់ឡើយ ។

ក្រុមហ៊ុនបានត្រាយតែមែកឈើតូចៗ ដើម្បីធ្វើដំណើរចូលកន្លែងសាងសង់ និងកាប់ឈើណាដែលនៅតាមគន្លងតែ ៣០ម ប៉ុណ្ណោះ ដើម្បីទុកឱ្យព្រៃនោះ អាចដុះលូតលាស់ឡើងវិញ ។

**៦.៣ ធនធានព្រៃឈើ និងជំរកសត្វព្រៃ**

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះ ប៉ះពាល់ខ្លាំងទៅលើផ្ទៃដីសរុប ៤៨.៤៤ ហ.ត ក្នុងនោះ ប៉ះពាល់ដីព្រៃសរុប ៤៥.៣០ ហ.ត ដែលមានព្រៃស្រោងចំនួន ៤០.០៣ហ.ត និងព្រៃល្បាយឫស្សីចំនួន ៥.២៧ ហ.ត សល់ពីនោះគឺដីប្រជាជន ដីអូរ និងដីផ្លូវចំនួន៣.១៤ ហ.ត ដោយសារការសាងសង់ បង្គោលភ្លើង និងខ្សែបញ្ជូនតង់ស្យុងខ្ពស់១១៥ គ.វ ពីអគារថាមពលទី១ និងទី២ មកអនុស្ថានីយ៍អូរសោម ។

ម្យ៉ាងទៀត មានការប៉ះពាល់ដល់ព្រៃឈើ ក៏ដូចជាជំរកសត្វព្រៃ ដោយសារការប្រើប្រាស់ថ្នាំគីមីដើម្បីសំអាត ឬបង្អាក់ការលូតលាស់របស់ឈើក្នុងការសាងសង់គំរោងនេះ ។

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងបានធ្វើឱ្យរំខានដល់ការរស់នៅរបស់ពពួកសត្វព្រៃដែលមាននៅក្នុងនិងជុំវិញទីតាំងគំរោងដោយសារមានសំលេង និងរំញ័រចេញពីគ្រឿងចក្រ រថយន្តម៉ាស៊ីនគ្រប់ប្រភេទ ពេលកំពុងធ្វើការងារការសាងសង់គំរោង

មានការប៉ះពាល់ដោយសាររំញ័រដោយសារការដឹកជញ្ជូន សម្ភារគំរោងធ្ងន់ៗ ដូចជា ដឹកគ្រង់ស្វរ ជាដើម ។ល ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានបង្ហាញនៅក្នុងប្លង់រចនាគំរោងលំអិតឡើយ ។

ក្រុមហ៊ុនបានធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថានដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែលនឹងកើតមានឡើងជាយថាហេតុ លើព្រៃឈើដែលនៅជាប់នឹងតំបន់គំរោងក្នុងដំណាក់កាលនៃការសាងសង់ប្រព័ន្ធខ្សែចម្លងនេះ ។

ក្រុមហ៊ុនបានធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីធ្វើការសំអាតព្រៃក្នុងតំបន់តាមគន្លងខ្សែ ១១៥គ.វ៉ ទទឹង៣០ម ( ១៥ម សងខាងអក្សបង្គោលមើលរូបទី ៤) ។

ក្រុមហ៊ុនបានសហការជាមួយស្ថាប័នជំនាញ ឬអង្គភាពជំនាញមូលដ្ឋានក្នុងការថែរក្សាការពារព្រៃឈើ និងជំរកសត្វព្រៃនៅជុំវិញអនុស្ឋានីយ៍អគ្គិសនីអូសោម និងនៅក្នុងនិងក្បែរតំបន់គំរោងទៅតាមផែនការគ្រប់គ្រងធនធានបរិស្ថានដោយបង្កើតក្រុមល្បាតដើម្បីត្រួតពិនិត្យ និងការពារធនធានបរិស្ថានទាំងនោះឱ្យមានប្រសិទ្ធភាព។

ក្រុមហ៊ុនមិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាតឬ បង្អាក់ការលូតលាស់របស់ឈើនោះទេ។

ក្រុមហ៊ុនបានប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនដែលមានសំលេងតិច ។

ក្រុមហ៊ុនបានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះ ដើម្បីកាត់បន្ថយការរំខានដល់សត្វព្រៃក្នុងតំបន់គំរោងនេះ។

ក្រុមហ៊ុនបានធ្វើការអប់រំដល់បុគ្គលិក-កម្មករគំរោងឱ្យចេះស្ងៀមស្ងាត់នៅពេលម៉ោងសំរាក និងនៅពេលយប់ ។

ក្រុមហ៊ុនបានធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការដឹកជញ្ជូនត្រង់ស្វូរ និងប្រើរថយន្តពិសេសដែលមានកង់ច្រើនក្នុងការបន្ថយទំងន់ និងរំញ័រ។

### ៦.៤ ជីវសាស្ត្រ សត្វព្រៃ

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

តំបន់គំរោងនេះមានសត្វព្រៃជាច្រើនប្រភេទដែលរស់នៅហើយ ប្រភេទសត្វមួយចំនួនកំពុងត្រូវបានធ្វើការអភិរក្ស។ តាមការសិក្សាដោយក្រុមការងារ SAWAC បានបង្ហាញថា មានថនិកសត្វចំនួន ៥០ ហើយក្នុងពេលសិក្សា ESIA នេះ មិនឃើញមាន ដំរី, ខ្លាធំ, ខ្លាលឿងមាស, ក្ដាន់, ភេរោមច្រមុះ ភេក្បាលសំប៉ែត និងកេះ ពីព្រោះព្រៃឈើក្នុងតំបន់ទាំងពីរ ត្រូវបានកាប់សំអាតបាតអាង និង កំពុងសាងសង់រចនាសម្ព័ន្ធគំរោង ជាពិសេសមានមនុស្សចូលព្រៃក្បែរ តំបន់គំរោងច្រើន ធ្វើឱ្យពួកវា ភ័យខ្លាច មានហ៊ានចូលមកតំបន់នេះទេ។ ចំណែកឯ បក្សីមាន ១៣០ប្រភេទ ឧរង្គសត្វ ៣៦ប្រភេទ ក្នុងពេលសិក្សា ESIAមានល្មូន២ប្រភេទមិនឃើញមានដូចជាអណ្តើកមាស និងអណ្តើកក្របីក្បាលលឿង , ហើយនិងមច្ឆជាតិមាន២១ប្រភេទដូចមានចែងក្នុងជំពូក៥ ចំណុច ៥.១.២.២

កាប់ឆ្ការព្រៃឈើសំរាប់គន្លងខ្សែភ្លើង ៣០ម ការដឹកជញ្ជូនសម្ភារសាងសង់ បានធ្វើឱ្យមានការភ័យខ្លាចដល់សត្វព្រៃទាំងនោះ ដោយសារមានសំលេងរំខានខ្លាំងៗ ចេញពីម៉ាស៊ីនគ្រឿងយន្ត និងសំឡេងរបស់បុគ្គលិក-កម្មករគំរោង។

មានសកម្មភាពបរបាញ់ឬចាប់សត្វ ឬចូលព្រៃពីសំណាក់បុគ្គលិក-កម្មករគំរោងទាំងនោះធ្វើឱ្យផ្អើលនិងបាត់បង់សត្វព្រៃការជួញដូរសត្វព្រៃនៅតំបន់គំរោងអាចមានការកើនឡើងដូចជា ការយកធ្វើម្ហូប ការធ្វើថ្នាំបុរាណជាដើម។ល។ ធ្វើឱ្យហិនហោចបាត់បង់សត្វព្រៃពីតំបន់ទាំងនេះ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រដើម្បីកុំឱ្យមានការរំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គំរោង និងតំបន់ជិតគំរោង ។

ក្រុមហ៊ុនបានកំណត់កំរិតរញ្ជួយក្នុងការដឹកជញ្ជូនសម្ភារសំណង់ឱ្យតិច និងប្រើប្រាស់ម៉ាស៊ីនដែលមានសំលេងនិងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃទាំងនេះ ។

ក្រុមហ៊ុនបានអប់រំ និងដាក់វិន័យដល់បុគ្គលិកកម្មករគំរោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃនិងធ្វើចរាចរលក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ ។

ក្រុមហ៊ុនត្រូវដាក់ផ្លាកសញ្ញាព្រៃការពារ និងហាមបរបាញ់ជាអក្សរខ្មែរ និងចិនឱ្យបានច្រើនដើម្បីឱ្យប្រជាពលរដ្ឋ និងចិនងាយមើលឃើញនៅតំបន់ព្រៃសហគមន៍។

ក្រុមហ៊ុនបានចូលរួមសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថានដើម្បីទប់ស្កាត់បទល្មើសសត្វព្រៃ និងព្រៃឈើ ។

## គ.ធនធានសង្គម/សេដ្ឋកិច្ច

### គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋានឡើងវិញ

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការសាងសង់បង្គោលភ្លើងតង់ស្យុងខ្ពស់ ១១៥ គ.វ៉ មានពីរខ្សែគឺ ខ្សែទី១ពីអគារថាមពលទី១ មកអនុស្ថានីយ៍អូរសោម មានចំនួន ១១បង្គោល និងខ្សែទី២ពីអគារថាមពលទី២ មកអនុស្ថានីយ៍អូរសោមចំនួន ៣៣បង្គោល ដែលក្នុងនោះ ប៉ះពាល់ចំនួន ៦ បង្គោល (ខ្សែទី១បង្គោល A9,A10,JA4 និង ខ្សែទី២បង្គោល B54, B55, JB9) លើដីប្រើប្រាស់ទំហំ ១៣៥០ម$^{២}$ ជាកម្មសិទ្ធរបស់ប្រជាពលរដ្ឋ២គ្រួសារ ដោយសារមិនអនុញ្ញាតឱ្យមានការរស់នៅ និងមានដើមឈើកំពស់មិនលើសពី៣ម និងនៅពីក្រោមគន្លងខ្សែចម្លងម្ខាង ១៥ម ពីអក្ស័បង្គោលភ្លើងដែលជាដីចំណីខ្សែចម្លងនេះ សរុប ៣០ម ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានរៀបចំផែនការការតាំងទីលំនៅឡើងវិញរបស់ប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារគំរោង រួមទាំងមានសំណងត្រឹមត្រូវ និងយុត្តិធម៌ ។

ក្រុមហ៊ុនមិនបានទន្ទ្រានយកដីរបស់ប្រជាពលរដ្ឋដែលបានកាន់កាប់ដោយសន្តិវិធី (យោងតាមច្បាប់ភូមិបាលមាត្រាលេខ ៣, ៥, ៨, ២៣, ២៥ និង ៣០) ឡើយដូចជាៈ ដីភូមិ ដីស្រែចំការ និងដីសហគមន៍។

ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធក្នុងការផ្សព្វផ្សាយជាសាធារណៈនូវការអនុវត្តន៍គំរោងនេះ ដោយមានការដោះស្រាយផលប៉ះពាល់សំណងជាសាច់ប្រាក់ (សំណូមពរអ្នកប៉ះពាល់ភាគច្រើនចង់បានជាសាច់ប្រាក់) លើដីស្រែចំការ បុស្សដំណាំ និងការរុះរើលំនៅដ្ឋាន។

ក្រុមហ៊ុនបានសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ និងអាជ្ញាធរមូលដ្ឋានដើម្បីអនុវត្តទៅតាមការសំរេចចិត្តរបស់រាជរដ្ឋាភិបាល និងសម្របសម្រួលនូវទំនាស់ដីធ្លីទាំងឡាយណាដែលកើតមានដោយសារសកម្មភាពសាងសង់គំរោងនេះ។

ក្រុមហ៊ុនបានផ្តល់អាទិភាពក្នុងការជ្រើសយកកំលាំងពលកម្មពីប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារគំរោង ដើម្បីធ្វើជាបុគ្គលិក-កម្មករគំរោង។

Draft

## គ.២ ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន

➢ ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលសាងសង់នេះ ការប៉ះពាល់តិចតួចដល់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋចំនួន២គ្រួសារ ដោយសារប្រជាពលរដ្ឋទាំងនោះមានដីស្ថិតនៅក្រោមខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥គ.វ៉ នៃគំរោងវារីអគ្គិសនីអាតៃនេះ។

ប្រជាពលរដ្ឋនៅតាមគន្លងខ្សែចម្លងមានការភយ័ខ្លាចពីសុវត្ថិភាព ដោយខ្លាចឆក់ និងមានគ្រោះថ្នាក់ដោយសារចរន្តអគ្គិសនី និងរលំបង្គោលភ្លើង ។

ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ មានការភ័យខ្លាចអំពីសុវត្ថិភាពរបស់ខ្លួន នៅពេលមានការតវ៉ាអំពីសិទ្ធិរស់នៅ និងកិច្ចសន្យាដែលបានចែងក្នុងផែនការនៃការតាំងលំនៅដ្ឋានឡើងវិញ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានសហការជាមួយអង្គការពាក់ព័ន្ធនានា អាជ្ញាធរមូលដ្ឋាន ស្ថាប័នក្រសួងពាក់ព័ន្ធដែលតំណាងឱ្យរាជរដ្ឋាភិបាលធ្វើការដោះស្រាយតាមការធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋាន ដោយមានសំណងដី ផ្ទះ ដំណាំ ការបាត់បង់ជីវភាពប្រចាំថ្ងៃ ហើយនិងគោរពតាមផែនការតាំងទីលំនៅដ្ឋានថ្មីឡើងវិញនេះឱ្យបានត្រឹមត្រូវបំផុត។

ក្រុមហ៊ុនបានជ្រើសរើសបុគ្គលិក-កម្មករសរុប ៥២នាក់ក្នុងនោះប្រជាពលរដ្ឋមូលដ្ឋានជាពិសេសអ្នកដែលប៉ះពាល់ដោយសារគំរោង ចំនួន៤០នាក់ និងបុគ្គលិក-កម្មករចិន ១២នាក់។

ក្រុមហ៊ុនបានតំឡើងបង្គោលភ្លើងឱ្យមាំតាមបច្ចេកទេស ដោយធានាមិនឱ្យរលំនៅពេលមានព្យុះភ្លៀងធម្មតា។ម្យ៉ាងទៀតកំពស់កន្លែងដក់របស់ខ្សែតង់ស្យុងខ្ពស់ពីដីមិនតិចជាង ៨ម (បទដ្ឋានរបស់អាជ្ញាធរអគ្គិសនីកម្ពុជាមិនតិចជាង ៧ម) ។

ក្រុមហ៊ុនបានសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដីផ្សព្វផ្សាយអំពីគោលបំណង និងគោលការណ៍ផ្តល់សំណងនៃការប៉ះពាល់ដោយសារគំរោងនេះ។




**រូបទី ២ : កំរិតកំពស់ភាពបត់នៃខ្សែតង់ស្យុងខ្ពស់**

| តង់ស្យុង | កំពស់ |
|---|---|
| 115 | 7.0 ឬច្រើនជាង |

Draft

### គ.៣ ប្រពៃណី វប្បធម៌ និង សាសនា

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះ ប៉ះពាល់ដល់ជំនឿ ប្រពៃណី របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ ដោយសារក្រុមហ៊ុនយកបុគ្គលិក-កម្មកររបស់ខ្លួនដែលមកពីតំបន់ឆ្ងាយខុសៗគ្នា និងមានសញ្ជាតិខុសៗគ្នា ។

ប៉ះពាល់ដល់កន្លែងសក្ការៈបូជាទាំងឡាយដូចជា ព្រៃអ្នកតាឬទីទួល ព្រៃកប់ខ្មោចសំណាក់ម្ចាស់ទឹកដីក្នុងតំបន់ ។ល។ ដោយសារគំរោងធ្វើការកាប់ឆ្ការដីព្រៃឈើ ដើម្បីសាងសង់ ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានសិក្សាស្វែងយល់អំពី ទំនៀមទំលាប់ ប្រពៃណី និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង ហើយផ្សព្វផ្សាយ និងគោរពទៅតាមប្រពៃណីទំនៀមទំលាប់នេះដោយមិនធ្វើការបំពាន និងល្មើសឡើយ ។

ក្រុមហ៊ុនបានធ្វើការអប់រំ ណែនាំដល់បុគ្គលិក-កម្មកររបស់ខ្លួនអំពីទំនៀមទំលាប់ប្រពៃណីប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់

ក្រុមហ៊ុនបានសហការជាមួយរដ្ឋអំណាចមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើត និងអភិរក្សកន្លែងសក្ការៈបូជាទាំងឡាយដែលបាត់បង់នោះឡើងវិញដូចដែលមានកន្លងមកនៅភូមិរបស់គាត់ ។

### គ.៤ ការផ្គត់ផ្គង់ទឹកស្អាត

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះ មានការប៉ះពាល់ដល់ការប្រើប្រាស់ទឹកអូរ ស្ទឹង ដោយសារសកម្មភាពសាងសង់ ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង និងការគ្រប់គ្រងកាកសំណល់រឹង-រាវមិនបានល្អធ្វើឱ្យបំពុលដល់ប្រភពទឹកលើដី និងក្រោមដីដែលជាប្រភពដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទឹកប្រជាពលរដ្ឋក្នុងតំបន់ ។

ម្យ៉ាងទៀតកាកសំណល់រឹង-រាវចេញពីកន្លែងរស់នៅផ្ទះបាយ និងបង្គន់អនាម័យរបស់បុគ្គលិក-កម្មករនៃគំរោងការលេចធ្លាយប្រេងឥន្ធនៈ និងប្រេងរំអិលពីឧបករណ៍ ឬគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់អាចបង្កឱ្យទឹកអូរ ស្ទឹងបាត់បង់គុណភាពដែរ ។ ហើយការសំអាតខ្លួនប្រាណរបស់បុគ្គលិក-កម្មកររាប់រយនាក់នៅក្នុង ឬក្បែរអូរ ស្ទឹងនឹងធ្វើឱ្យគុណភាពទឹកទាំងនេះមានការថយចុះនឹងឈានទៅដល់ការបំពុលទឹក ។

➢ **វិធានការកាត់បន្ថយ**

ការឈូសឆាយទ្រង់ទ្រាយធំ ក្រុមហ៊ុនបានធ្វើនៅរដូវវស្សាទេ ។

ក្រុមហ៊ុនត្រូវធ្វើរបាំងការពារកករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ហើយសាងសង់បង្គន់អនាម័យ និងបន្ទប់ទឹកឱ្យបានគ្រប់គ្រាន់ទៅតាមចំនួនបុគ្គលិក-កម្មករគំរោង ។

ក្រុមហ៊ុនបានធ្វើការអប់រំណែនាំបុគ្គលិក-កម្មករគំរោងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សំរាមដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅហើយដាក់ពិន័យដល់បុគ្គលិក-កម្មករណាដែលមិនព្រមធ្វើតាមការណែនាំ ។

ក្រុមហ៊ុនបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវដោយសាងសង់បង្គន់អនាម័យព្រមទាំងរៀបចំប្រមូលសំណល់រឹងនិងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព ។

Draft

ក្រុមហ៊ុនបានសាងសង់អាងសិបទិកទំនើបដែលអាចសំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិកដែលស្នាក់នៅ ក្នុងពេលដំណើរការ និងថែទាំគំរោង ។

ក្រុមហ៊ុនបានសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។

ក្រុមហ៊ុនបានប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិប្រេងឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គំរោង ។

ក្រុមហ៊ុនត្រូវពង្រាបដី និងដាំស្មៅតាមកន្លែងដែលសង់គ្រឹះបង្គោលភ្លើង( ព្រោះមានដីស្អុយគ្មានជីវជាតិស្មៅមិនដុះនាំឱ្យមានការហូរច្រោះបំពុលគុណភាពទឹក) ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក ។

### គ.៥ តំបន់ទេសចរណ៍ /រមណីយដ្ឋាន /ទីកន្លែងកំសាន្ត

នៅតំបន់គំរោងជាតំបន់ដាច់ស្រយាល ពុំទាន់មានរមណីយដ្ឋាន និងទីកន្លែងកំសាន្តនៅឡើយទេ ។

### គ.៦ ផ្លូវគមនាគមន៍

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះ ប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ក្នុងតំបន់ដោយសារសកម្មភាព សាងសង់គំរោង និងការដឹកជញ្ជូនសំភារៈបរិក្ខាអគ្គិសនី ជាពិសេស ការដឹកជញ្ជូនត្រង់ស្វូរ និងគ្រឿងចក្រចូលទៅទីតាំងគំរោង បណ្តាលឱ្យមានការស្រុត ឬ ខូចផ្លូវ ការបាក់ស្ពាន ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរ លើខ្សែផ្លូវ ដែលមានចំណោទឡើងទួល និងផ្លូវកោង ។ ល ។

<u>**សំគាល់:**</u>- ត្រង់ស្វូរនិមួយៗ ដែលត្រូវតំលើងនៅអនុស្ថានីយ៍អូសោមមានទំងន់ ពី៤៥ តោន - ៥០ តោន ។

- អាចមានគ្រោះថ្នាក់ចរាចរនៅពេលដែលតំលើងខ្សែភ្លើងកាត់ផ្លូវ និងស្ទឹងដោយសារកំពស់ខ្សែមិនទាន់ទាញបានដល់ចំណុចកំពស់ដែលបានគ្រោង ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានធ្វើការកែលំអផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវថ្មីនៅតំបន់ផ្លូវចូលមុខអនុស្ថានីយ៍ ដែលអាចធានាដល់ការប្រើប្រាស់របស់គំរោង ហើយធ្វើការពិភាក្សាជាមួយស្ថាប័នជំនាញក្នុងការដឹកជញ្ជូនសម្ភារធ្ងន់ៗ ដូចជា ត្រង់ស្វូរដែលមានទំងន់ ដល់ទៅ ៥០ តោន ។

ក្រុមហ៊ុនបានប្រើប្រាស់រថយន្តដែលមានកង់ច្រើនដើម្បីបន្ថយទំងន់សម្ពាធ និងរំញ័រនាំឱ្យខូចផ្លូវស្ពាន និងរំខានដល់ប្រជាពលរដ្ឋ ។

ក្រុមហ៊ុនបានធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជាគ្រឿងចក្រ និងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូនល្បឿនបើកបរមិនឱ្យលើសពី ៣០គ.មក្នុង១ម៉ោងនៅក្នុងតំបន់ភូមិ និងទីប្រជុំជនមិនឱ្យលើស១០គ.ម ក្នុង ១ម៉ោង ទេ) និងដើម្បីបញ្ចៀសគ្រោះថ្នាក់ចរាចរនានា ។

ក្រុមហ៊ុនត្រូវធ្វើការជួសជុលស្ពានដែលមានស្រាប់ដើម្បីធានាលើការដឹកជញ្ជូន និងប្រើប្រាស់ប្រភេទយានយន្តដែលមិនបង្កឱ្យបាក់ស្ពានដែលមានស្រាប់ទាំងនោះ ។

Draft

ក្រុមហ៊ុនបានសហការជាមួយមន្ទីរពាក់ព័ន្ធធ្វើការដោះស្រាយសំរួលចរាចរក្នុងតំបន់មានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន និង សំរួលចរាចរនៅពេលដឹកជញ្ជូនគ្រឿងស្ទូរ ។

ក្រុមហ៊ុនបានធ្វើការជួសជុលផ្លូវក្នុងតំបន់គំរោងឱ្យបានល្អ និងធ្វើការថែរក្សាផ្លូវដែលខ្លួនបានប្រើប្រាស់ជាប្រចាំ ។

នៅគ្រប់ចំណុចដែលខ្សែនេះឆ្លងកាត់ផ្លូវថ្នល់ក្រុមហ៊ុនបានគ្រោងតំលើងកំពស់ខ្សែទាបបំផុតពីដី១៥ម (ស្តង់ដាអគ្គិសនី១៤.២ម) ហើយនឹងអនុវត្តការតំឡើងខ្សែចម្លងនេះភ្លាមៗ គឺមិនបន្ទាយខ្សែឆ្លងកាត់ផ្លូវចោលនោះទេ ។ ទន្ទឹមនឹងនេះដែរក្រុមហ៊ុនបានធ្វើសេចក្តីជូនដំណឹងទៅអាជ្ញាធរ និងដាក់ស្លាកប្រកាសអំពីការដ្ឋានកំពុងសាងសង់ ចំងាយពីការដ្ឋាន១០០ម និង ស្នើសុំឱ្យមាន សមត្ថកិច្ចផ្នែកចរាចរមកជួយធ្វើអន្តរាគមន៍ នៅពេលតំឡើងខ្សែចម្លងនេះ ។




**គម្លាតនៃខ្សែនៅពេលដែលមានផ្លូវ និង ខ្សែភ្លើងបណ្តាញទៀតឆ្លងកាត់**

## គ.៦ សុខភាពសាធារណៈ

### ➢ ហេតុប៉ះពាល់អវិជ្ជមាន

ការងារសាងសង់គ្រឹះបង្គោល និងអនុស្ថានីយ៍អូរសោម បង្កឱ្យមានការប៉ះពាល់ជាមធ្យមដល់សុខភាពបុគ្គលិក-កម្មករ របស់ក្រុមហ៊ុន និងប្រជាពលរដ្ឋ ក្នុងតំបន់ ដោយសារធូលីដី ធូលីស៊ីម៉ងត៍ ចំហាយ ចេញពីការប្រើប្រាស់សារធាតុគីមីជាដើម ។

បង្កឱ្យមានផលប៉ះពាល់ដល់សុខភាពបុគ្គលិក-កម្មកររបស់គំរោង ដោយសារតំបន់ខ្លះនៃគំរោងនេះជាតំបន់ដែលកើត ជំងឺគ្រុនចាញ់ និងគ្រុនសន្ធំ ។ ម្យ៉ាងទៀតប្រជាពលរដ្ឋនៅតំបន់គំរោងអាចឆ្លងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេងៗពីបុគ្គលិក-កម្មករគំរោង ដែលជ្រើសរើសមកពីឆ្ងាយដោយក្រុមហ៊ុនផងដែរ ។

អាចប៉ះពាល់ដល់សុខភាពសាធារណៈ (ប្រជាជនក្នុងតំបន់ និងបុគ្គលិក-កម្មករគំរោង) ដោយសារការប្រើប្រាស់ ឬចរាចរគ្រឿងញៀន ។

ប៉ះពាល់ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មករគំរោង ដោយសារមិនចាប់អារម្មណ៍អំពីសុវត្ថិភាពការងារ ។

ក្នុងតំបន់គំរោងនៅកន្លែងខ្លះគ្មានប្រភពទឹកស្អាតសំរាប់បរិភោគទេ ។

បន្ថែមពីលើនេះទៀត បង្កឱ្យមានគ្រោះថ្នាក់ដល់កម្មករតំលើងខ្សែ និងបង្គោលដោយសារការឆក់ (ទោះបីជាមិនទាន់ភ្ជាប់ចរន្តក៏ដោយ) ដោយសាររន្ទះបើមានអាកាសធាតុមិនល្អចរន្តអគ្គិសនីនឹងស្រូបចូលតាមខ្សែឬបង្គោលធ្វើឆក់អ្នកដែលប៉ះខ្សែផ្ទាល់ ឬបង្គោលដែកនេះ ។

អាចមានប្រជាពលរដ្ឋ ឬជនណាម្នាក់ឡើងបង្គោលភ្លើងអាចបណ្តាលឱ្យមានគ្រោះថ្នាក់ធ្លាក់ ឬមានការឆក់ (ទោះបីជាមិនទាន់ភ្ជាប់ចរន្តក៏ដោយ) ។

អាចមានការផ្ទុះសេខ្សែភ្លើងនៅពេលខ្សែនៅគ្រប់ចណោចដែលខ្សែតង់ស្យុងខ្ពស់ និងខ្សែតង់ស្យុងមធ្យមដទៃទៀតឆ្លងកាត់ពីលើគ្នា ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានប្រកាន់យកការរក្សាសុវត្ថិភាពការងារជាចំបង ក្នុងសកម្មភាពការងារប្រចាំថ្ងៃ ។

ក្រុមហ៊ុនបានផ្តល់ម៉ាស់ការពារធូលីដីដល់បុគ្គលិកកម្មករគំរោង និងធ្វើការស្រោចទឹកលើផ្លូវថ្នល់ដែលខ្លួនប្រើប្រាស់ក្នុងការសាងសង់គំរោងនេះ ។

ក្រុមហ៊ុនបានសាងសង់ជំរុំស្នាក់នៅរបស់បុគ្គលិក-កម្មករគំរោងឱ្យបានសមរម្យ ដោយមានការផ្គត់ផ្គង់ទឹកស្អាតមានបង្គន់អនាម័យ បន្ទប់ទឹកគ្រប់គ្រាន់ និងមានកម្មវិធីអប់រំសុវត្ថិភាពការងារដល់បុគ្គលិក-កម្មកររបស់គំរោង ។

មានគ្រូពេទ្យដែលមានសមត្ថភាពនៅប្រចាំការក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់កម្មករ និងត្រៀមថ្នាំពេទ្យ និងបរិក្ខាគ្រប់គ្រាន់ជាប្រចាំសំរាប់ការពិនិត្យ និងព្យាបាលជូនបុគ្គលិក-កម្មកររបស់គំរោងហើយមានរថយន្តសង្គ្រោះបន្ទាន់នៅពេលដែលមានករណីគ្រោះថ្នាក់កើតឡើងជាយថាហេតុ ។

បន្ថែមពីលើនេះទៀតក្រុមហ៊ុនបានរៀបចំប្រព័ន្ធសុវត្ថិភាពខ្ពស់ ការពារមិនឱ្យមានគ្រោះថ្នាក់ដល់កម្មករតំលើងខ្សែ និងបង្គោលដោយសារការឆក់ (ទោះបីជាមិនទាន់ ភ្ជាប់ចរន្តក៏ដោយ) ដោយសាររន្ទះធ្វើឆក់អ្នកដែលប៉ះខ្សែផ្ទាល់ ឬបង្គោលដែកនេះ ។

ក្រុមហ៊ុនបានធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មកររបស់ខ្លួនក្នុងការទប់ស្កាត់ជំងឺទាំងនោះកុំឱ្យឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ ។

ក្រុមហ៊ុនបានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ពិសេសទប់ស្កាត់ការជួញដូរ ចរាចរគ្រឿងញៀន និងមនុស្ស ។

ក្នុងពេលសាងសង់ក្រុមហ៊ុនបានតំលើងខ្សែការពាររន្ទះ និងប្រពន្ធ័សុវត្ថិភាពការពារឆក់ នៅពេលដែលកើតមានចរន្តអគ្គិសនីដោយចៃដន្យដែលបណ្តាលមកពីអាកាសធាតុ ។

ក្រុមហ៊ុនបានសហការជាមួយស្ថាប័នសុខាភិបាលនៅក្នុងតំបន់នេះដើម្បីការពារទប់ស្កាត់ជំងឺឆ្លងផ្សេងៗដែលកើតមានឡើងជាយថាហេតុ ។

ក្រុមហ៊ុនបានសាងសង់ថាសដែកការពារសត្វ-មនុស្សភ្ជាប់នឹងបង្គោលអគ្គិសនីទាំងបួនកុំឱ្យសត្វ-មនុស្សឡើងបាន និងមានដាក់ស្លាកសញ្ញាហាមឃាត់ទៀតផង ។




៖ វិធានការគំរូ ការពារមិនឱ្យឡើងហេដ្ឋារចនាអគ្គិសនី



ការមើលពីលើហេដ្ឋាល




ការរះពីក្បាល ចំងាយខ្នាតរវាង ...

Draft

ក្រុមហ៊ុនត្រូវតំលើងខ្សែនៅគ្រប់ចំណុចដែលខ្សែតង់ស្យុងខ្ពស់ និងខ្សែតង់ស្យុងមធ្យមដែលនៅខ្សែឆ្លងកាត់ពីលើគ្នាដោយធានាសុវត្ថិភាពកុំឱ្យមានការឆ្លងចរន្តធ្វើឱ្យផ្ទុះដាច់ខ្សែដោយឱ្យចំណុចនេះមានគំលាតខ្សែពីគ្នាមិនតិចជាង៣.៥ម៉ែត្រនោះទេ( មើលរូបខាងលើ) ។

## ៣.៨ សោភ័ណ្ឌភាព /ទេសភាព

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការសាងសង់បង្គោល និងខ្សែបញ្ជូនចរន្តអគ្គិសនីតង់ស្យុងខ្ពស់មានការប៉ះពាល់តិចតួចដល់សោភ័ណ្ឌភាពទេសភាពក្នុងតំបន់ ដោយសារការតំឡើងបង្គោលមិនមានការរត់ត្រង់គ្នា ឬកំពស់មិនស្មើគ្នាជាដើម ។ល ។

ម្យ៉ាងទៀត បង្កផលប៉ះពាល់ដល់សោភ័ណ្ឌភាពដល់តំបន់ការពារ និងអភិរក្សទាំងនោះដែរ ដោយសារការរៀបចំបង្គោលខ្សែបណ្តាញ ភ្លើងមិនរត់តាមជួរល្អនិងកាប់ឆ្ការព្រៃឈើក្នុងតំបន់នេះ ។

ការហុយធូលីដោយសារការដុតព្រៃសំរាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏ធ្វើឱ្យប៉ះពាល់ដល់សោភ័ណ្ឌភាព និងទេសភាពកន្លែងនោះដែរ ។

➢ **វិធានការកាត់បន្ថយ**

ការសាងសង់បង្គោល និងខ្សែនាំភ្លើងនេះក្រុមហ៊ុនបានជ្រើសយកការតំរង់ទិស និងកំពស់ទៅតាមស្ថានភាពដី( កំពស់ចាប់ពី ៣៥-៦៥ម) ឱ្យបានសមស្របដើម្បីបន្ថយការរំខានដល់ការមើលឃើញទេសភាពតាមដងផ្លូវពីសំណាក់អ្នកធ្វើដំណើរឆ្លងកាត់តំបន់នេះ ។

ក្រុមហ៊ុនត្រូវធ្វើគន្លងខ្សែនាំអគ្គិសនីឱ្យបានត្រង់ល្អដើម្បីមើលទៅរត់ត្រង់ជួរគ្នា ។

ក្រុមហ៊ុនបានធ្វើការស្រោចទឹកជាប្រចាំទៅលើផ្លូវថ្នល់ដែលខ្លួនកំពុងប្រើប្រាស់សាងសង់គំរោង ។

### ត.៩ ហានិភ័យ

- **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលសាងសង់នេះ អាចមានហានិភ័យ ដោយសារគ្រោះធម្មជាតិ ការកើតមានការរញ្ជួយដី បន្ទុះភ្នំភ្លើង នៅក្នុងតំបន់គំរោង ការទទួលរងឥទ្ធិពលពីព្យុះទីហ្វុង ឬព្យុះផ្សេងទៀត ដែលជាហេតុបង្កឱ្យមានមហន្តរាយធំៗ រលំបាក់ ឬ ដាច់ខ្សែភ្លើង និងការខូចហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ដែលកំពុងសាងសង់ ការបាត់បង់ ឬខូចខាតសំភារៈ និងគ្រឿងចក្រសាងសង់ ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិកកម្មករព្រមទាំងប្រជាពលរដ្ឋនៅក្នុង/ក្បែរខាងតំបន់គំរោង ។

កើតមានការផ្ទុះសំភារៈគ្រឿងផ្ទុះ ឆេះប្រេងឥន្ធនៈ នៅកន្លែង ឬឃ្លាំងស្តុករបស់គំរោង និងការឆេះព្រៃក្នុងតំបន់គំរោង ដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភាវកម្មក៏អាចបង្កឱ្យមានមហន្តរាយដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង និងធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។

អាចកើតមានសង្គ្រាមឈ្លានពានលើបូរណៈភាពទឹកដីនៃប្រទេសកម្ពុជា ក៏ជាឧបសគ្គដល់ការងារសាងសង់គំរោង ឬសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងក៏សឹងមាន ។

- **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានធ្វើការសិក្សារចនាប្លង់វិស្វកម្ម និងគុណភាពការសាងសង់ ដែលអាចធានាមិនឱ្យមានការបាក់រលំបង្គោល ឬដាច់ខ្សែរនៅពេលមានព្យុះភ្លៀងធម្មតា ។

ក្រុមហ៊ុនបានប្រុងប្រយ័ត្នគ្រប់វិនាទី ក្នុងការការពារសុវត្ថិភាពចំពោះគ្រឿងផ្ទុះ ការឆេះព្រៃ និងឆេះប្រេងឥន្ធនៈដោយធ្វើការសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គំរោងឱ្យទាន់ពេលវេលា ។

ក្រុមហ៊ុនត្រូវធ្វើការជូនដំណឹងរាល់ហេតុការណ៍ ដោយសារគ្រោះធម្មជាតិទាំងនោះ ជាបន្ទាន់ដល់អនុស្ថានីយអូរសោម ដើម្បីផ្តាច់ចរន្តឱ្យទាន់ពេលវេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិភ័យកើតឡើងដែលអាចបង្កដល់ការបាក់រលំ ឬដាច់ខ្សែបណ្តាលឱ្យគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋក្នុងតំបន់គំរោង ។

ក្រុមហ៊ុនបានរៀបចំបំរុងទុកនូវយានយន្តសង្គ្រោះសម្ភារ និងថវិកាដើម្បីធានាការសង្គ្រោះជាបន្ទាន់នូវហេតុការខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាពខ្ពស់ ។

### ៨.២.៣ ដំណាក់កាលប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance)

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះគឺជាដំណាក់កាលមួយមានរយៈពេលវែងជាងគេរហូតដល់៣០ឆ្នាំ យោងតាមកិច្ចសន្យាស្នើសុំរបស់ក្រុមហ៊ុនដាក់ជូនទៅរាជរដ្ឋាភិបាល ។ សកម្មភាពគំរោងក្នុងដំណាក់កាលនេះអាចនឹងបង្កឱ្យមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ ដូចតទៅ :

#### ក.ធនធានរូបសាស្ត្រ

នៅក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះធនធានរូបសាស្ត្រ គឺមានប៉ះពាល់ទៅលើការបំពុលទឹក (លើដី និងក្រោមដី) តែប៉ុណ្ណោះ ។

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង ប៉ះពាល់តិចតួចទៅលើគុណភាពទឹកលើដី និងក្រោមដី ដោយសារការប្រើប្រាស់សារធាតុគីមីដើម្បី បង្អាក់កាលូតរបស់ដើមឈើ ក្នុងពេលដំណើរការគម្រោងនេះ ។

មានការបំពុលទឹកដោយសារការលេចធ្លាយ ឬកំពប់ប្រេងគ្រប់ប្រភេទ ដែលក្រុមហ៊ុនយកមកដំណើរការថែទាំ គម្រោងនេះ រួចហូរចូលទៅក្នុងប្រភពទឹកទាំងនោះ ។

- **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនមិនប្រើប្រាស់សារធាតុគីមីដើម្បីសំអាត ឬបង្អាក់ការលូតលាស់ របស់ដើមឈើនោះទេ។

ក្រុមហ៊ុនបានសាងសង់សំណង់រណ្តៅបេតុងពីក្រោមត្រង់ស្តូរ ការពារការលេចធ្លាយ ឬកំពប់ប្រេងដែលប្រើសំរាប់ត្រង់ស្តូរទាំងនោះ ។ ចំពោះប្រេងដែលចាស់ ដែលដូរ ឬប្រេងដែលមាននៅក្នុងរណ្តៅ និងយកទៅប្រើជាគ្រឿងចំហេះផ្សេងៗ។

ក្រុមហ៊ុនត្រូវធ្វើការគ្រប់គ្រងយានយន្តគ្រប់ប្រភេទមិនឱ្យលេចធ្លាយប្រេងដែលជាហេតុនាំឱ្យមានការបំពុលទឹកនេះទេ។

## <u>៩.ធនធានជីវសាស្រ្ត</u>

### ៩.១ ជីវសាស្រ្តដែលរស់នៅក្នុងទឹក /មច្ឆជាតិ

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំងនេះប៉ះពាល់តិចតួចដោយសារការបង្ហូរកាកសំណល់រាវចេញពីអនុស្ថានីយ៍អគ្គិសនីអូរសោម ធ្វើឱ្យប៉ះពាល់ដល់កត្តាជីវសាស្រ្តដែលរស់នៅក្នុងទឹក ឬមច្ឆជាតិដែលរស់នៅក្នុងប្រភពទឹកក្បែរនោះ ។

- **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនមិនបង្ហូរសំណល់រាវដែលចេញពីការិយាល័យ រោងជាង កន្លែងត្រង់ស្វូរ ឃ្លាំង នៃអនុស្ថានីយ៍អគ្គិសនីអូរសោម ដោយផ្ទាល់ចូលទៅក្នុងប្រព័ន្ធប្រឡាយទឹកធម្មជាតិនេះទេ ។

ក្រុមហ៊ុនបានសាងសង់អាងសិបទិកទំនើបសំរាប់កាកសំណល់រាវ ឬទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករដែលស្នាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំគម្រោង។

### ៩.២ ព្រៃឈើការពារ /តំបន់ការពារ /ឧទ្យានជាតិ

នៅក្នុងតំណាក់កាលប្រតិបត្តិ និងថែទាំនេះមិនមានប៉ះពាល់ទៅលើដីតំបន់ការពារតទៅទៀតនោះទេ ព្រោះមានប៉ះពាល់ខ្លាំងតែនៅក្នុងដំណាក់កាលសាងសង់ប៉ុណ្ណោះ ។

### ៩.៣ ធនធានព្រៃឈើ និងជំរកសត្វព្រៃ

- ហេតុប៉ះពាល់អវិជ្ជមាន

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំនេះប៉ះពាល់ជាមធ្យមដល់ធនធានព្រៃឈើដែលជាជំរកសត្វព្រៃ ច្រើនប្រភេទដូចមានចែងក្នុងជំពូក ៥ចំណុច ៥.១.២.១ ដោយសកម្មភាពកាប់សំអាតមែក ឬដើមឈើតាមគន្លងខ្សែនេះ ដោយមិនឱ្យខ្ពស់ជាងពាមដែលជាការរំខានផ្ញើលសត្វផងដែរ ។

ម្យ៉ាងទៀតអាចកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់គំរោង ដោយសារការផ្ទុះសេខ្សែភ្លើង( មែកឈើដុះលូតទៅប៉ះដែនរបស់ខ្សែភ្លើងនេះនារដូវប្រាំងស្ងួតធ្វើឱ្យមានការឆេះព្រៃ ។

➢ **វិធានការកាត់បន្ថយ**

ការថែទាំគន្លងខ្សែភ្លើងនេះធ្វើតែពេលថ្ងៃតែប៉ុណ្ណោះ ពីព្រោះនៅពេលយប់សត្វព្រៃភាគច្រើនរកស៊ី និង មួយចំនួនទៀត ដេកនៅព្រៃក្បែរៗតំបន់ខ្លះនៃគំរោងនេះ ។

ក្រុមហ៊ុនបានធ្វើការអប់រំ និងហាមឃាត់ដល់បុគ្គលិក-កម្មកររបស់គំរោងមិនឱ្យទន្រ្ទានចូលព្រៃធ្វើការបរបាញ់ ឬដាក់អន្ទាក់ ឬជួញដូរសត្វព្រៃ។

ក្រុមហ៊ុនត្រូវដាក់ពិន័យដល់បុគ្គលិកកម្មករណាដែលប្រព្រឹត្តិល្មើស នឹងការហាមឃាត់ខាងលើ ។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងរដ្ឋអំណាចមូលដ្ឋានដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដែលកើតឡើងជាយថាហេតុនៅក្នុងតំបន់គំរោង ។

ក្រុមហ៊ុនត្រូវបំពាក់នូវឧបករណ៍សម្ភារសំរាប់ពន្លត់អគ្គីភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៍ស្វ័យប្រវត្តិនៅតំបន់ព្រៃការពារ និងអភិរក្សទាំងនេះសំរាប់ផ្តល់សញ្ញាដល់អនុស្ថានីយ៍អូរសោមនៅពេលមានអគ្គិភ័យកើតឡើង។

### ខ.៤ ជីវសាស្រ្តសត្វព្រៃ

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការទន្រ្ទានចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ និងចាប់សត្វពីសំណាក់បុគ្គលិក-កម្មករដែលធ្វើប្រតិបត្តិការ និងថែទាំគំរោងក៏បណ្តាលឱ្យមានផលប៉ះពាល់ដល់សត្វព្រៃក្នុងតំបន់នេះផងដែរ ។

អាចមានគ្រោះថ្នាក់ដល់សត្វស្វា ដោយសារសត្វនេះឡើងបង្គោលភ្លើងហើយបណ្តាលឱ្យធក់ ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនហាមឃាត់ដាច់ខាតដល់បុគ្គលិក-កម្មកររបស់ខ្លួនក្នុងការប្រមាញ់ឬជួញដូរសត្វព្រៃនៅក្នុងនិងក្បែរខាងតំបន់គំរោង ។

ក្រុមហ៊ុនអប់រំនិងដាក់វិន័យដល់បុគ្គលិក-កម្មករគំរោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃ និងធ្វើចរាចរលក់ដូរសត្វព្រៃនៅក្នុងតំបន់នេះឡើយ ។

ក្រុមហ៊ុនត្រូវសាងសង់ថាសសុវត្ថិដែកការពារជើងទាំង ៤ របស់បង្គោលកុំឱ្យមនុស្ស-សត្វឡើង។

## គ. ធនធានសេដ្ឋកិច្ច-សង្គម

### គ.១ ការប្រើប្រាស់ដី និងការតាំងលំនៅឡើងវិញ

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំ គំរោងនេះ មិនមានផលប៉ះពាល់ទៅលើការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋទៀតទេ ព្រោះផលប៉ះពាល់បានកើតឡើង និងដោះស្រាយរួចទៅហើយនៅក្នុងដំណាក់កាលសាងសង់។ ប៉ុន្តែអាចមានការ ចូលទន្រ្ទានកាន់កាប់ដី ព្រៃ ចាប់យកដីធ្វើជាកម្មសិទ្ធពីសំណាក់ជនឱកាសនិយម ឬការប្រមូលទិញដីដើម្បីធ្វើកសិកម្មពីប្រជាពលរដ្ឋ ដែលធ្វើឱ្យពួកគាត់ខ្វះដីបង្កបង្កើនផល រួចគេក៏កាប់រានដីព្រៃធ្វើកសិកម្ម នាំឱ្យវិនាស ហិនហោច ដីព្រៃការពារទាំងនោះទៀតផង។

Draft

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃ និងត្រូវដាក់ផ្លាកប៉ាន់ល្អធំៗ ដូច នៅតាមផ្លូវទៅខេត្តកោះកុង ជាដើម ។ ជាងនេះទៅទៀតក្រុមហ៊ុន មានថវិកាសំរាប់អ្នកល្បាត ៩ នាក់ សំរាប់រយៈពេល៦ឆ្នាំ ចំនួន ១២៤.២០០ ដុល្លារអាមេរិក និង ថវិកាចំនួន ៥០.០០០ ដុល្លារអាមេរិកការអប់រំបរិស្ថាន និងលើកប៉ាន់ល្អក្នុងតំបន់ទាំងនេះ ។

## គ.២ ការរស់នៅ និងមុខរបររបស់សហគមណ៍មូលដ្ឋាន

នៅដំណាក់កាលនេះ មិនមានប៉ះពាល់ទៅដល់មុខរបររស់នៅរបស់ប្រជាពលរដ្ឋនោះទេ ផ្ទុយទៅវិញបានបង្កើតការងារធ្វើទៅដល់ប្រជាពលរដ្ឋនៅមូលដ្ឋាននោះវិញ។

## គ.៣ ប្រពៃណីវប្បធម៌ និងសាសនា

**➢ ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះ អាចប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ក្រុមហ៊ុននាំយកបុគ្គលិក-កម្មករគំរោងមកពីតំបន់ផ្សេងទៀត ឬជនបរទេស។

**➢ វិធានការកាត់បន្ថយ**

ក្រុមហ៊ុនត្រូវធ្វើការណែនាំអប់រំដល់បុគ្គលិក-កម្មកររបស់គំរោងឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋរស់នៅជុំវិញក្នុងតំបន់ទីតាំងគំរោង ។

ក្រុមហ៊ុនត្រូវដាក់វិន័យដល់បុគ្គលិក-កម្មករគំរោងដែលបំពានលើទំនៀមទំលាប់ប្រពៃណីវប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់ ។

## គ.៤ ការផ្គត់ផ្គង់ទឹកស្អាត

**➢ ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះអាចមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់បុគ្គលិក-កម្មករគំរោងដោយសារបរិវេណការងារនេះពុំទាន់មានប្រពន្ធ័ផ្គត់ផ្គង់ទឹកស្អាតទេ ។

ការគ្រប់គ្រងកាកសំណល់រឹង-រាវដែលចេញពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករ ឃ្លាំងស្តុកសំភារៈ រោងជាងជាដើមដែលធ្វើឱ្យខូចដល់ប្រភពទឹកសំរាប់ផ្គត់ផ្គង់ក្នុងតំបន់។

➢ វិធានការកាត់បន្ថយ

ក្រុមហ៊ុនបានសាងសង់អាងសិបទិកទំនើបសំរាប់កាកសំណល់រាវឬ ទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករដែលស្នាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំគំរោង។

ក្រុមហ៊ុនត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវ ដោយសាងសង់បង្គន់អនាម័យព្រមទាំងរៀបចំប្រមូលសំណល់រឹង និង សំរាម យកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីកែប្រែតំបន់នោះឱ្យមានអនាម័យ និងបរិស្ថានល្អ

Draft

### គ.៥ តំបន់ទេសចរណ៍ /រមណីយដ្ឋាន /ទីកន្លែងកំសាន្ត

ក្នុងផ្នែកខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់១១៥គ.វ នេះ មិនមានការប៉ះពាល់ដល់តំបន់ទេសចរណ៍/រមណីយដ្ឋាន/ទីកន្លែងកំសាន្តទេ ក្នុងដំណាក់កាលនេះ ។

### គ.៦ ផ្លូវគមនាគមន៍

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ការកកស្ទះចង្អៀតលើដងផ្លូវ និងបង្កឱ្យមានគ្រោះថ្នាក់ ដោយសារសកម្មភាពថែទាំគំរោង ការធ្វេសប្រហែសក្នុងការបើកបររបស់បុគ្គលិក-កម្មករគំរោង ។

មានការខូចខាតផ្លូវ ដោយសារការថែទាំគន្លងខ្សែភ្លើងនេះ ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បី សំរួលចរាចរនៅពេលដែលមានការថែទាំគន្លងខ្សែម្តងៗ ។

ក្រុមហ៊ុនត្រូវធ្វើការថែទាំជួសជុលផ្លូវឬពង្រីកផ្លូវដើម្បីធានាសុវត្ថិភាព និងសំរួលចរាចរក្នុងតំបន់គំរោងឱ្យបានល្អប្រសើរ ។

ក្រុមហ៊ុនបានជ្រើសរើសអ្នកបើកបរដែលមានបទពិសោធន៍ និងមានស្មារតីល្អ ។

### គ.៧ សុខភាពសាធារណៈ

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោង អាចបង្កឱ្យមានការប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះ ដោយសារបុគ្គលិក-កម្មកររបស់ក្រុមហ៊ុនអាចចម្លងជំងឺផ្សេងៗដល់អ្នកភូមិ ដូចជាជំងឺអេដស៍ ជំងឺកាមរោគ ។ល។

ម្យ៉ាងទៀតមានការប៉ះពាល់ដល់សុខភាពសាធារណៈ ដោយសារការគ្រប់គ្រងសំណល់រឹង-រាវមិនបានល្អ ។

បន្ថែមពីលើនេះទៀត អាចមានគ្រោះថ្នាក់ដល់អាយុជីវិតប្រជាពលរដ្ឋរស់នៅពីក្រោម ពីព្រោះមានប្រជាពលរដ្ឋចំនួន២គ្រួសារដែលមានដីនៅតាមគន្លងនេះ ឬធ្វើដំណើរកាត់តាមគន្លងខ្សែបញ្ជូនចរន្ត១១៥គ.វនេះ ដោយសារការរងនូវឥទ្ធិពលដែនអគ្គិសនី ភ្លួចអាំងឌុចស្យុងអេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិក ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនត្រូវធ្វើការពិនិត្យតាមដានគុណភាពទឹកដែលបញ្ចេញពីកន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករឱ្យបានទៀងទាត់ជាប្រចាំ ប្រសិនបើគុណភាពទឹកដែលបញ្ចេញទៅក្រៅនេះមានការបំពុល ក្រុមហ៊ុននឹងរិះរកមធ្យោបាយដើម្បីធ្វើការកាត់បន្ថយ ដោយសហការជាមួយស្ថាប័នពាក់ពន្ធ័ ។

ក្រុមហ៊ុនត្រូវធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំឱ្យកើតមាន និងឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ ។

ក្រុមហ៊ុនត្រូវធ្វើការសហការជាមួយស្ថាប័នសុខាភិបាលដើម្បីទប់ស្កាត់ជំងឺឆ្លងដែលកើតឡើងជាយថាហេតុ ។

ក្រុមហ៊ុនត្រូវគ្រប់គ្រងកាកសំណល់រឹង-រាវឱ្យបានល្អតាមបទដ្ឋានបច្ចេកទេស ។

ក្រុមហ៊ុនត្រូវធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋានអ្នកដែលប៉ះពាល់ទាំងនោះឱ្យចេញផុតពីតំបន់គ្រោះថ្នាក់ដោយសារដែនអគ្គិសនីនេះឱ្យបានយុត្តិធម៌ ដែលអាចប្រជាពលរដ្ឋទាំងនោះទទួលយកបានដោយធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ពន្ធ័មុននឹងភ្ជាប់ចរន្ត ។



Draft

ក្រុមហ៊ុនបានសាងសង់បង្គោលឱ្យខ្ពស់ដែលធ្វើយ៉ាងណាឱ្យគម្លាតខ្សែដក់មកដីមានកំពស់ ៨មយ៉ាងតិច និងកន្លែងខ្សែឆ្លងកាត់ផ្លូវកំពស់ ១០ មយ៉ាងតិច ។

ក្រុមហ៊ុនត្រូវធ្វើការផ្សព្វផ្សាយជាប្រចាំអំពីគ្រោះថ្នាក់ក្នុងន័យអប់រំមិនឱ្យពួកគាត់មករស់នៅក្រោមឬលើកបង្គោលលោហៈក្នុងចំណីខ្សែ ឬឡើងបង្គោលភ្លើង ឬឡើង ដើមឈើដែលដុះក្នុងតំបន់ដែនអគ្គិសនីនេះ ។ ជាងនេះទៅទៀតត្រូវដាក់ផ្លាកសេចក្តីជូនដំណឹងអំពីដីចំណីគន្លងខ្សែភ្លើងនេះ ដូចដីចំណីផ្លូវរបស់ក្រសួងគមនាគមន៍ សាធារណៈការ និងដឹកជញ្ជូនមើលរូបថតខាងក្រោម






## គ.៨ សោភ័ណ្ឌភាព /ទេសភាព

សោភ័ណ្ឌភាព/ទេសភាពនៅក្នុងតំបន់គំរោងក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំនេះមិនមានផលប៉ះពាល់ទេ ប៉ុន្តែរងផលប៉ះពាល់ខ្លាំងនៅក្នុងដំណាក់កាលសាងសង់ ហើយក៏ត្រូវបានក្រុមហ៊ុនសំអាត និងរៀបចំឡើងវិញរួចរាល់ដែរ ។

## គ.៩ ហានិភ័យ

➢ **ហេតុប៉ះពាល់អវិជ្ជមាន**

នៅក្នុងដំណាក់កាលនេះអាចមានហានិភ័យដោយសារគ្រោះធម្មជាតិ ការធ្វេសប្រហែសផ្នែកសន្តិសុខ និងអំពើភាវរកម្ម ឬសង្គ្រាម ។

ការកើតមានការរញ្ជួយដី ឬបន្ទុះភ្នំភ្លើង នៅក្នុងតំបន់គំរោងការទទួលរងឥទ្ធិពលពីព្យុះភ្លៀងទីហ្វុង ឬព្យុះផ្សេងទៀត អាចបង្កឱ្យមានមហន្តរាយធំៗដូចជាការបាក់ រលំបង្គោល ដាច់ខ្សែ និងការខូចហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិក-កម្មករ និងប្រជាពលរដ្ឋនៅក្នុង និងក្បែរខាងតំបន់គំរោង ។

ការឆេះព្រៃក្នុងតំបន់គំរោងដែលបណ្តាលមកពីការធ្វេសប្រហែសបច្ចេកទេស ឬផ្ទុះសេខ្សែភ្លើង ឬអំពើភាវរកម្ម ក៏អាចបង្កឱ្យមានមហន្តរាយ/គ្រោះថ្នាក់ធំដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។

ការកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដីនៃប្រទេសកម្ពុជា និងសង្គ្រាមផ្ទៃក្នុងក៏ជាឧបសគ្គដល់កិច្ចដំណើរការ និងថែទាំគំរោងជូនកាលសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងទៀតផង ។

➢ **វិធានការកាត់បន្ថយ**

ក្រុមហ៊ុនបានបំពាក់ប្រព័ន្ធផ្តាច់ភ្លើងដោយស្វ័យប្រវត្តិ ដើម្បីផ្តាច់ចរន្តអគ្គិសនីឱ្យទាន់ពេលវេលាការពារ អាយុជីវិតមនុស្ស សត្វ ។

Draft

ក្រុមហ៊ុនបានប្រុងប្រយ័ត្នគ្រប់ទិនាទីក្នុងការការពារសន្តិសុខចំពោះគ្រឿងអាចផ្ទុះនានា អគ្គីភ័យនានា និងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បីទប់ស្កាត់រាល់អំពើភេវរកម្មក្នុងតំបន់គំរោង ។

ក្រុមហ៊ុនត្រូវធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់រលំបង្គោលភ្លើង ការដាច់ខ្សែ ដោយសារគ្រោះធម្មជាតិដល់ប្រជាពលរដ្ឋដែលរស់ក្នុង និងក្បែរខាងគំរោងនេះទាំងអស់ ឱ្យបានជ្រាបហេតុការណ៍ខាងលើបានទាន់ពេលវេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិភ័យបែបនេះកើតឡើង ។

ក្រុមហ៊ុនបានរៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះសម្ភារ និងថវិកាដើម្បីធានាការដោះស្រាយផលប៉ះពាល់ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះទាន់សភាពការណ៍និងមានប្រសិទ្ធិភាព ។

### ៨.២.៤ ដំណាក់កាលបិទគំរោង (Project Closure)

ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុនរបស់ប្រទេសចិន នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបន្ទុកធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគំរោងអាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាអ្នកសំរេចខ្លួនឯង ហើយសង្ឃឹមថាក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុនចិននេះ ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ដែលគួរឱ្យកត់សំគាល់ឡើយ ។ (ចំពោះបទដ្ឋានបច្ចេកទេស និងគុណភាពរបស់ហេដ្ឋារចនាសម្ព័ន្ធគំរោងនេះ ដែលនឹងត្រូវប្រគល់ជូនរាជរដ្ឋាភិបាលវិញមានចែងលំអិតក្នុងកិច្ចសន្យារួចអស់ហើយ)

ការប៉ាន់ប្រមាណ និងកំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ ត្រូវបានដកស្រង់ចេញពីតារាង ៦២ ដូចខាងក្រោម :

Draft

## ៨.៣ ការសង្ខេបទំហំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ ដោយសារហេដ្ឋារចនាសម្ព័ន្ធខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥គ.វ

**តារាង ៦២: សង្ខេបទំហំនៃហេតុប៉ះពាល់អវិជ្ជមាន និងវិធានការណ៍កាត់បន្ថយ**

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| **១. ហេតុប៉ះពាល់បរិស្ថានក្នុងដំណាក់កាលមុនប្រតិបត្តិគំរោង** | | | | | | |
| **១.១ ចំណាក់កាលមុនសាងសង់គំរោង** | | | | | | |
| **ក.ធនធានរូបសាស្ត្រ** | | | | | | |
| ការប៉ះពាល់ដល់ធនធាន បរិស្ថានធនធានធម្មជាតិ គឺមានតិចតួចណាស់ តែការសិក្សានេះនឹងអាចប៉ះពាល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋផងដែរ ក្នុងការខ្លាចបាត់បង់ដីធ្លី និងខ្លាចរលំបង្គោលភ្លើងធក់ផងដែរក្នុងដំណាក់កាលនេះ។ ដូចនេះនៅក្នុងដំណាក់កាលនេះ មិនមានផលប៉ះពាល់គួរអោយកត់សម្គាល់ទេ។ | | | | | | |
| **ខ.ធនធានជីវសាស្ត្រ** | | | | | | |
| **ជីវសាស្ត្រដែលរស់នៅក្នុងទឹក / មច្ឆជាតិ** | -នៅក្នុងដំណាក់កាលរចនានេះមិនមានប៉ះពាល់ដល់ មច្ឆជាតិដែលនៅក្នុងអូរ ឬស្ទឹងទេ។ | | | | | |
| **ព្រៃឈើការពារ /តំបន់ការពារ /ឧទ្យានជាតិ** | -អាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ដែលស្ថិតនៅក្នុងតំបន់ព្រៃការពារភ្នំក្រវាញ និងព្រៃការពារដងទង់បន្តិចបន្តួចដែរ ដោយសារសកម្មភាពសិក្សា ដូចជាមានសំឡេងអ៊ូអរក្នុងការត្រួសត្រាយព្រៃធ្វើដំណើរក្នុងការសិក្សា។ | ✓ | | | -បានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃតែ។ ម្យ៉ាងទៀតក្រុមសិក្សាបានបោះទីតាំងតែមួយកន្លែងដើម្បីបន្ថយការកាប់ព្រៃ និងរំខានសត្វព្រៃ<br>-បានធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធដើម្បីធ្វើការសិក្សាដោយមិនឱ្យរំខានជំរកនិងការរស់នៅរបស់សត្វព្រៃក្នុងតំបន់ការពារ-អភិរក្ស ភ្នំក្រវាញ និងព្រៃការពារដងទង់ឡើយ។<br>-បានត្រាយតែមែកឈើតូចៗ ដើម្បីធ្វើដំណើរចូលកន្លែងសិក្សាតែប៉ុណ្ណោះ ដើម្បីទុក ឱ្យព្រៃនោះអាចលូតលាស់ឡើងវិញ (តាមលក្ខណៈ បច្ចេកក្នុង ការថែរក្សាព្រៃការ ក្រោយមែកឈើអាចធ្វើឱ្យដើមលូតលាស់ កាន់តែប្រសើរជាងមុន)។ | |
| **ធនធានព្រៃឈើ /ជំរកសត្វព្រៃ** | -អាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោងដោយសារការត្រួសត្រាយព្រៃ និងសំឡេងអ៊ូអររបស់បុគ្គលិក-កម្មករក្នុងការធ្វើដំណើរសិក្សា | | ✓ | | -បានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យរំខានសត្វព្រៃទេ។<br>-បានសហការជាមួយអាជ្ញាធរមូលដ្ឋាន<br>និងជំនាញពាក់ព័ន្ធដើម្បីធ្វើការសិក្សាដោយ | |

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | មិនឱ្យរំខានជំរកនិងការរស់នៅរបស់សត្វព្រៃនៅក្នុងតំបន់គំរោងឡើយ ។<br>-បានព្រាយតែមែកឈើតូចៗ ដើម្បីធ្វើដំណើរចូលកន្លែងសិក្សាប៉ុណ្ណោះ ដើម្បីទុកឱ្យ ព្រៃនោះអាចលូតលាស់ល្អឡើងវិញបាន ។ | |
| ជីវសាស្ត្រសត្វព្រៃ | -ប៉ះពាល់តិចតួចដល់ជីវសាស្ត្រសត្វព្រៃខ្លះដែរ ដោយសារសកម្មភាពសិក្សាគំរោងនេះគឺអាចធ្វើឱ្យសត្វពេលដែលដើរសិក្សាតំរង់ទិសរកទីតាំងគំរោង ។ | ✓ | | | -បានធ្វើការសិក្សាតែពេលថ្ងៃដើម្បីមិនឱ្យរំខានសត្វព្រៃទេពីព្រោះសត្វព្រៃភាគច្រើន រកស៊ីពេលយប់ ហើយការបោះជំរុំ តែមួយកន្លែងតែមួយកន្លែង តែប៉ុណ្ណោះក្នុងពេល សិក្សានេះ ។ | |
| **គ. ធនធានសេដ្ឋកិច្ចសង្គម** | | | | | | |
| **ការប្រើប្រាស់ដី និង ការតាំងលំនៅដ្ឋាន ឡើងវិញ** | -ប៉ះពាល់តិចតួចដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ ដោយសារខ្លាចបាត់បង់ដីស្រែ ចំការ និងលំនៅដ្ឋាន និងដីបុស្ស ធ្វើឱ្យពួកគេងាយចាញ់បោកជនឆ្លៀតឱកាស កេងយកដីរបស់ពួកគាត់ រួចរំលោភយកដីព្រៃកាពារទាំងនេះធ្វើជាកម្មសិទ្ធិ ។<br>-មានជនឆ្លៀតឱកាសដើរបំផុសប្រជាពលរដ្ឋ ក្នុងគោលបំណងចង់បានដីធ្វើចំការកៅស៊ូឬចំការផ្សេងៗព្រោះដីតំបន់នេះមានអំណោយផលដល់ដំណាំកៅស៊ូ ដូចជាគេបំផុសថា ដីយុំអូរសោមត្រូវលិច ឬប្រយ័ត្នរលំបង្គោល ដាច់ខ្សែ និងឆក់ ដូចនេះត្រូវតែចេញពីតំបន់ ពីភូមិនេះ ដោយទាមទាឱ្យរដ្ឋាភិបាល និងក្រុមហ៊ុនរកដីថ្មីដែលជាហេតុធ្វើឱ្យគំរោងមានការរាំងស្ទះឃើតយាវក្នុងការអនុវត្តន៍ឱ្យបានសំរេចទៅតាមពេលវេលាដែលបានគ្រោងទុក ។<br>-មានការប្រមូលទិញដីពីប្រជាពលរដ្ឋក្នុងតំបន់ដើម្បីធ្វើកសិកម្ម ព្រោះដីមានជីជាតិល្អ រួចហើយអាចមិនសុខចិត្តពីម្ចាស់ដីដែលជាមន្ត្រីថ្នាក់ខ្ពស់ ឬថ្នាក់ឧកញ៉ាមិនអនុញ្ញាតិឱ្យសង់បង្គោលនិងខ្សែភ្លើងនេះកាត់ដីរបស់ខ្លួន | ✓ | | | -បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការទប់ស្កាត់រាល់ការបំផុសចលនា<br>ប្រជាពលរដ្ឋរបស់ជនឆ្លៀតឱកាសកេងចំណេញដើម្បីទាមទារដីធ្លីនិងសំណងផ្សេងៗ ឱ្យបានទាន់ពេលវេលា ។<br>-បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងក្រសួងពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវអង្កេតដីកម្មសិទ្ធិជាក់ស្តែង ក្នុងភូមិ-ឃុំ នៅក្នុងតំបន់គំរោង ។<br>-បានធ្វើការផ្សព្វផ្សាយដល់សាធារណៈជនស្ថាប័នពាក់ពន្ធ័អំពីគំរោង និងអំពីសំណង នៃការប៉ះពាល់ដោយសារគំរោងនេះ ។<br>-បានរៀបចំធ្វើផែនការការតាំងលំនៅដ្ឋានថ្មីឡើងវិញរបស់គ្រួសារដែលប៉ះពាល់ដោយសារគំរោង ។<br>-បានធ្វើការដោះស្រាយជាមួយថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដើម្បីរកដំណោះស្រាយល្អ ក្នុងការអនុវត្តន៍គំរោងនេះ ។ | |
| **ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន** | -ប្រជាជននៅក្នុងតំបន់មានការភយ័ខ្លាច មានគ្រោះថ្នាក់ដោយចរន្តអគ្គិសនី និងខ្លាចរលំបង្គោលភ្លើង ឬដាច់ខ្សែភ្លើង នាំឱ្យពួកគេ ងាយចាញ់ | ✓ | | | -បានសិក្សារៀបចំធ្វើផែនការតាំងលំនៅថ្មីជូនប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារគំរោងរួចហើយ ។ | |

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | បោកជនឱកាសនិយម ធ្វើឱ្យគាត់មិនគិតប្រកបរបរធ្វើស្រែ ចំការ នាំឱ្យបាត់ចំណូលរបស់គាត់ ។<br>- ប្រជាជនមួយចំនួនមានការភ័យខ្លាចរដ្ឋាភិបាលរឹបអូសដីរបស់ពួកគេយកឱ្យក្រុមហ៊ុនធ្វើការអភិវឌ្ឍន៍តំរោងនេះ ។ | | | | - បានធ្វើការផ្សព្វផ្សាយតាមរយៈក្រុមការងារសិក្សា វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដោយជូនដំណឹងដល់សាធារណៈជន ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋជា មុនអំពីគោលបំណង ជាក់ស្តែងរបស់រាជរដ្ឋា ភិបាលសំរាប់ការអភិវឌ្ឍន៍តំរោងនេះនៅពេលអនាគត និងការដោះស្រាយផលប៉ះពាល់ជូន គ្រួសារដែល នឹងត្រូវរងផលប៉ះពាល់ ដោយសារតំរោងនេះ ឱ្យបានសមស្របទៅ តាមទីផ្សារទៀតផង ។<br>- បានព្យាយាមគ្រោងបួងគេចចេញពីតំបន់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋចំណុចស្ទឹងតាចាន់ ភូមិឆាយលូក ។ ចំពោះគុណភាពបង្គោល និងខ្សែក្រុមហ៊ុន បានគ្រោងគុណភាពស្តង់ដាអន្តរជាតិ មិនងាយរលំ និងដាច់ងាយៗក្នុងលក្ខខណ្ឌព្យុះភ្លៀងធម្មតា ទេ ។ | |
| **ប្រពៃណី វប្បធម៌ និង សាសនា** | - នៅក្នុងដំណាក់កាលនេះ មិនមានប៉ះពាល់ដល់ប្រពៃណី វប្បធម៌ និងសាសនានៅឡើយទេ ដោយសារតែស្ថិតនៅក្នុងការសិក្សា និងរចនា ។ | | | | | |
| **ការផ្គត់ផ្គង់ទឹកស្អាត** | - នៅក្នុងការដំណាក់កាលរចនានេះ មិនមានប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងមូលដ្ឋាននោះទេ ។ | | | | | |
| **តំបន់ទេសចរណ៍ /រមណីយដ្ឋាន /ទីកន្លែងកំសាន្ត** | - នៅតំបន់តំរោងជាតំបន់ដាច់ស្រយាល ពុំទាន់មានរមណីយដ្ឋាន និងទីកន្លែងកំសាន្តនៅឡើយទេ ។ | | | | | |
| **ផ្លូវគមនាគមន៍** | - មានគ្រោះថ្នាក់ដល់អ្នកសិក្សាឬធ្វើឱ្យរាំងស្ទះការងារសិក្សាប្លង់រចនាតំរោងជាមធ្យម ដោយសារស្ថានភាពផ្លូវ ធ្វើចរាចរទ្រុឌទ្រោម តូចចង្អៀត ខូចខាត ផ្លូវចំណោត ហើយកន្លែងគ្មានផ្លូវចូលទៀតផង ។ | | ✓ | | - បានរកអ្នកនាំផ្លូវដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ក្នុងមូលដ្ឋានតំបន់តំរោង ។<br>- បានជួលរថយន្តដែលមានសុវត្ថិភាពល្អក្នុងការសិក្សាតំរោងនេះ ។ | |
| **សុខភាពសាធារណៈ** | - ប៉ះពាល់ជាមធ្យមដល់សុខមាលភាពបុគ្គលិកកម្មកររបស់ក្រុមហ៊ុនដោយសារ តំបន់ខ្លះរបស់តំរោងជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្និបាត ។<br>- មានតំបន់គ្រាប់មីនមួយចំនួននៅក្នុងតំបន់តំរោង ដែលអាចធ្វើឱ្យគ្រោះថ្នាក់ដល់ក្រុមសិក្សាតំរោង ។<br>- អាចឆ្លងជំងឺកាមរោគពីបុគ្គលិក-កម្មករដែលមកពីកន្លែងផ្សេងៗ និងជំងឺអេដស៍ជាដើម ។ | | ✓ | | - បានធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ។<br>- បានផ្គត់ផ្គង់ថ្នាំបង្ការដើម្បីការពារ និងព្យាបាលជំងឺទាំងនោះ ដល់បុគ្គលិក-កម្មករ ។<br>- បានសហការជាមួយកងយុទ្ធពលខេមរៈភូមិន្ទធ្វើការរាវរកគ្រាប់មីននៅតាមផ្លូវដែលនឹងត្រូវដើរសិក្សាហើយក្រុមនេះបានបោះទីតាំងជាប្រចាំនៅការដ្ឋានក្នុងតំបន់តំរោងទៀតផង ។ | |

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| **សោភ័ណ្ឌភាព /ទេសភាព** | - សោភ័ណ្ឌភាព /ទេសភាពនៅក្នុងតំបន់គំរោងក្នុងដំណាក់កាលរចនានេះ ស្ថិតនៅបែបធម្មជាតិនៅឡើយពុំទាន់ប៉ះពាល់ទេ ។ | | | | | |
| **ហានិភ័យ** (Risk) | - អាចមានគ្រោះថ្នាក់ ដោយសារតំបន់នោះមិនដែលស្គាល់ភូមិសាស្ត្រ ដូចជាមានគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបង្កប់ក្នុងដីក្នុងតំបន់គំរោង<br>- អាចគ្រោះថ្នាក់ដោយសារសត្វសាហាវដូចជា ខ្លាឃ្មុំ ពស់ពិស ខ្លា ដែលមាននៅក្នុងតំបន់អូរសោម ស្រុកវាលវែងនេះ ។ | | | ✓ | - បានធ្វើការទាក់ទងយ៉ាងជិតស្និតជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រជាពលរដ្ឋមូលដ្ឋាន និងកងយុទ្ធពលខេមរៈភូមិន្ទក្នុងការដោះស្រាយអំពីគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះទាំងនេះហើយក្រុមនេះបានបោះទីតាំងជាប្រចាំនៅការដ្ឋាន ក្នុងតំបន់គំរោងទៀតផង ។<br>- បានធ្វើដំណើររួមគ្នានិងសហការជាមួយអង្គភាពប្រដាប់អាវុធដើម្បីការពារនៅពេល ជួបប្រទះហេតុការណ៍ ដែលបង្កឡើងដោយសត្វសាហាវខាងលើនេះ ។ | |
| **១.២ ដំណាក់កាលសាងសង់** | | | | | | |
| **ក.ធនធានរូបសាស្ត្រ** | | | | | | |
| **សណ្ឋានដី និងជំរាលទេខា** (Morphology and Topography) | - អាចនឹងបណ្ដាលឱ្យប្រែប្រួលសណ្ឋានដី និងជំរាលទេខាក្នុងទីតាំងគំរោង ដោយ សារសកម្មភាពឈូសឆាយ និងពង្រាបដីស្រទាប់លើ ។ ដែលអាចនាំឱ្យមានការហូរច្រោះទៀតផង ។ | | ✓ | | - បានធ្វើការសាងសង់ជាទ្រង់ទ្រាយធំតែរដូវប្រាំងដើម្បីទប់ស្កាត់ ការហូរច្រោះដែលនាំឱ្យខូចសណ្ឋានដី នៅរដូវវស្សា។ ក្រុមហ៊ុនក៏បានពង្រាប ដីនៅស្មើរដូចសណ្ឋានដើមវិញ នៅពេលដែលសាងសង់ហើយ ។ | |
| **ប្រព័ន្ធជលសាស្ត្រ ទឹកលើដី** (ប្រឡាយ- អូរ-ស្ទឹង) (Hydrologycal System) | - ប៉ះពាល់ជាមធ្យម ដល់គុណភាពទឹកដោយសារសកម្មភាពសាងសង់ដែលបណ្ដាលមកពីការហូរ ច្រោះដីល្បាយតាមបង្ហូរភ្លៀង និងការងារជីនៅអនុស្ថានីយ៍អូរសោម ចូលទៅក្នុងអូរស្ទឹងដែលស្ថិតក្បែរកន្លែងសាងសង់នេះ ។<br>- ប៉ះពាល់ដល់គុណភាពទឹកដោយសារការបោះបង់កាកសំណល់រឹង និងការបង្ហូរកាកសំណល់រាវពីកន្លែងរស់នៅរបស់ បុគ្គលិក-កម្មករនៃគំរោងបង្គន់ ការលេចធ្លាយប្រេងឥន្ទនៈ និងប្រេងរំអិលពីគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ និងការមុជទឹកសំអាតខ្លួនប្រាណ ការបោកគក់របស់បុគ្គលិក-កម្មករ ដែលនៅក្បែរប្រភពទឹក នឹងធ្វើឱ្យខូចគុណភាព ទឹកអូរនិងស្ទឹងទាំងនោះ ។ | | | ✓ | - បានធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ខ្លាំងដោយ យកដីល្បាយដែលនៅក្បែរប្រភពទឹកចេញ និងកិនបង្ហាប់ ដាំស្មៅ នៅលើដីនៅកន្លែង ដែលបានសាងសង់បង្ហោលរួចហើយឱ្យបានមុនពេលរដូវភ្លៀងធ្លាក់ ។<br>- ត្រូវសាងសង់នៅរដូវប្រាំងដើម្បីកាត់បន្ថយការហូរច្រោះពីការដ្ឋានដីផ្សេងៗដែលអាចហូរចូលស្ទឹង ។<br>- បានអប់រំដល់បុគ្គលិកកម្មករអំពីការបោះបង់កាកសំណល់រឹង-រាវជាពិសេសការកំពប់ប្រេងឥន្ទនៈ ប្រេងរំអិល នៅលើដីដែលបណ្ដាលឱ្យខូចគុណភាពដី និងទឹកនៅក្នុងតំបន់គំរោង ។<br>- បានគ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទមិនឱ្យបោះចោល និងបង្ហូរចូលទៅក្នុង ឬក្បែរទឹកស្ទឹង ឬអូរឡើយដូចជាសង់បន្ទប់ទឹក និងបង្គន់អនាម័យឆ្ងាយពីស្ទឹងមានអាងសិបទិកត្រឹមត្រូវមានកន្លែងទុកដាក់សំណល់រឹង | |

Draft

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការសាកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ល្អតាមបច្ចេកទេស ។ | |
| **ការហូរច្រោះ និងគុណភាពដី** | -ប៉ះពាល់ជាមធ្យមដែលបណ្តាលមកពីការហូរច្រោះដី ដោយសារការឈូសឆាយដីស្រទាប់លើដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់តំរោង (បង្គោលភ្លើងនិងអនុស្ថានីយ៍ ដោយសារការធ្វេសប្រហែសមិនគោរពតាមបទដ្ឋានការងារដីដែលធ្វើឱ្យមានការហូរច្រោះដីពិសេសនៅរដូវវស្សា) ។<br>-បានបង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើនៅជុំវិញតំបន់បង្គោលភ្លើង ដោយចោលដីស្អុយ (ដីដែលជីកពីស្រទាប់ក្រោមគ្មានជីវជាតិ) ដែលធ្វើឱ្យបាត់បង់ជីវជាតិរបស់ដីស្រទាប់លើនៅតំបន់នោះ ហើយអាចបណ្តាលឱ្យមានការហូរច្រោះដីស្អុយនេះទៅគ្របពីលើសណ្ឋានដីតំបន់ជុំវិញនោះ ឬហូរចូលប្រភពទឹកប្រើប្រាស់ទៀតផង ។ | | ✓ | | -បានធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារបច្ចេកទេស ។<br>-បានពង្រាបដីឬថ្មដែលចាក់ចោល ដោយយកដីមានជីវជាតិលប់ពីលើ និងធ្វើការសហការណ៍ជាមួយរដ្ឋអំណាចមូលដ្ឋាន និងប្រជាពលរដ្ឋឱ្យបានល្អដែលពួកគាត់អាចទទួលយកបាន ។ | |
| **ការរញ្ជួយដី (seismology)** | -នៅការសាងសង់ខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥គ.វ នេះ មិនមានការបំផ្ទុះថ្ម ដែលបង្កឱ្យមានការរញ្ជួយ និងគ្រោះដល់ ប្រជាពលរដ្ឋនៅជុំវិញតំបន់តំរោងនោះទេ ។ | | | | | |
| **ការបំពុលទឹក (ទឹកលើដី /ទឹកក្រោមដី)** | -ប៉ះពាល់ជាមធ្យមដល់គុណភាពទឹកអូរ ស្ទឹងដោយសារការសាងសង់បង្គោលខ្សែនិងការងារសាងសង់ដទៃទៀតបណ្តាលមកពីការខួងឬការងារដី ការងារបេតុង និងការងារគ្រឹះ ដោយសារការដ្ឋានសាងសង់នេះស្ថិតនៅជិតប្រភពទឹកទាំងនោះ ។<br>-ប៉ះពាល់ដល់គុណភាពទឹកស្ទឹងដោយសារកាកសំណល់រឹង-រាវ មកពីការបោះចោលកាកសំណល់ផ្ទះបាយ បង្គន់ ដែលសង់គ្មានបច្ចេកទេស និងការខ្វះខាតបង្គន់អនាម័យគ្រប់គ្រាន់ សំរាប់បុគ្គលិកកម្មករតំរោង និងការបោះកាកសំណល់ សម្ភារ សំណង់ ដោយបុគ្គលិក-កម្មករក្រុមហ៊ុន (ការហៀរឬលេចជាតិប្រេងពីគ្រឿងចក្រ រថយន្ត បារ៉ែស៊ីម៉ងត៍ បារ ឬស្បោងច្រក សារធាតុ គីមីផ្សេងទៀត ។ល។) ។<br>-ប៉ះពាល់តិចតួចទេ តាមរយៈទឹកភ្លៀងនាំយកនូវសារធាតុគីមីនៅក្នុងបេតុង និងប្រេង ម៉ាស៊ីន ដែលកំពប់នៅលើដី ទៅដល់ស្រទាប់ទឹកក្រោមដី ។ | | ✓ | | -ការឈូសឆាយទ្រង់ទ្រាយធំក្រុមហ៊ុនមិនធ្វើនៅរដូវវស្សាទេ ។<br>-បានធ្វើការអប់រំបុគ្គលិក-កម្មករតំរោងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សំរាមដែលក្រុមហ៊ុនបានរៀបចំកសាងក្នុងទីតាំងស្នាក់នៅរបស់តំរោង ។<br>-បានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវដោយសាងសង់បង្គន់អនាម័យបន្ទប់ទឹកឱ្យបានឆ្ងាយពីមាត់អូរ ស្ទឹងព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពល្អមិនឱ្យប៉ះពាល់បរិស្ថានជុំវិញ ។<br>-បានបោះផ្លាកសញ្ញាតំបន់តំរោង ដោយមានអក្សរខ្មែរ និងចិនអំពីការបំពុលទឹក ។<br>-បានសាងសង់អាងសិបទឹកតាមបច្ចេកទេសសំរាប់ទឹកកខ្វក់ចេញពីការិយាល័យ បន្ទប់ទឹក បង្គន់ ផ្ទះបុគ្គលិកដែលស្នាក់នៅបណ្តោះអាសន្នក្នុងពេលសាងសង់តំរោង ។<br>-បានសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់ | |

Draft

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | - មានការហូរច្រោះដី ដោយសារការកាប់ឆ្ការនូវគំរបរុក្ខជាតិ ដូចជាការកាប់ព្រៃ ៣០ម. តាមគន្លងខ្សែ ការងារដីដែលមិនបានពង្រាបដីស្អុយ និងមិនបានគ្រប់គ្រងការងារដីទាំងនេះ ឱ្យបានល្អទៅតាមបទដ្ឋានបច្ចេកទេស ដែលហេតុនាំឱ្យ មានការហូរច្រោះដីដោយសារទឹកភ្លៀង ហូរអូរ ឬស្ទឹង ដែលនៅក្បែរៗនោះ ។ | | | | បរិស្ថាន និងសង្គម ។<br>- បានប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានគុណភាពល្អមិនលេចហូរជាតិប្រេង ឬខ្លាញ់មក លើដី និងប្រភពទឹកក្នុងតំបន់គំរោង ។<br>- ត្រូវដាំស្មៅតាមកន្លែងដែលសាងសង់បង្គោលរួចហើយ និងដាំស្មៅ នៅកន្លែងដែលកាប់សំអាតគន្លងដែលគ្មានស្មៅឬ ឈើដុះដើម្បីការពារការហូរច្រោះ និងគុណភាពទឹក ។<br>- មិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាតឬបង្អាក់ការលូតលាស់របស់ឈើនោះទេ ។ | |
| **ការបំពុលខ្យល់** | - បានបំពុលខ្យល់ដោយសារការដុតព្រៃឈើ ដើមឈើ កំទេចឈើ ដើម្បីសំអាតការដ្ឋាន និងនៅតាមគន្លងខ្សែ ហើយផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសម្ភារសំរាប់ ការងារសាងសង់ និង ការហុយធូលីដីពីមធ្យោបាយដឹកជញ្ជូនទាំងនេះរបស់គំរោង ។<br>- អាចបំពុលខ្យល់ដោយសារភ្លើងឆេះព្រៃបណ្តាលមកពីការធ្វេសប្រហែសពីបុគ្គលិកកម្មករគំរោង ។<br>- អាចនឹងបំពុលខ្យល់ដោយសារការប្រើប្រាស់សារធាតុគីមីដើម្បីសំលាប់ព្រៃឈើ ឬបង្អាក់ការលូត លាស់របស់ដើមឈើ ។ | | ✓ | | - មិនដុតព្រៃឈើទាំងអស់នៃតំបន់ដែលសំអាតតាមគន្លងខ្សែ ៣០ម. នេះទេ គឺក្រុមហ៊ុនធ្វើការសហការណ៍ជាមួយរដ្ឋបាលព្រៃឈើ និងម្ចាស់សហគមន៍ព្រៃឈើដើម្បីធ្វើការដោះស្រាយដោយប្រើឱ្យអស់លទ្ធភាពក្នុងការកែច្នៃ ឈើ ទាំងនេះដែលអាចធ្វើទៅបាន ហើយអាចបានថវិការចូលរដ្ឋថែមទៀតផង ។<br>- បានប្រើប្រាស់ម៉ាស៊ីន គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានការបញ្ចេញផ្សែងតិចដើម្បីកាត់បន្ថយការ បំពុលខ្យល់ក្នុងតំបន់នោះ ។<br>- បានត្រៀមឧបករណ៍ពន្លត់អគ្គិភ័យ និងមានកន្លែងបូមទឹកគ្រប់គ្រាន់នៅពេលមានអគ្គិភ័យ ។<br>- មិនប្រើប្រាស់សារធាតុគីមីផ្សេងៗក្នុងការសំអាតព្រៃឈើ ដើមឈើ នៅតាមគន្លងខ្សែនោះទេ ។ | |
| **ការបំពុលដី** | - មានការបំពុលដី ដោយសារការកំពប់នៃប្រេងឥន្ធនៈ ការកំពប់នៃសារធាតុគីមី និងសំណល់រឹង-រាវគ្រប់ប្រភេទទៅលើដី ដូចជា: កាកសំណល់ចេញពី ឬលេចធ្លាយពីគ្រឿងចក្រ និង រថយន្តគ្រប់ប្រភេទក្នុងដំណើរការគំរោងនេះ ព្រមទាំងកាកសំណល់ចេញពីផ្ទះបាយផងដែរ ។<br>- មានផលប៉ះពាល់ដល់ស្រទាប់ដីខាងលើផងដែរដោយសារការចាក់ដីស្អុយដែលមិនបានដឹកចេញពីតំបន់សាងសង់បង្គោលភ្លើងនាំឱ្យដីនេះហូរទៅលើ | | | | - បានសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវមិនឱ្យកំពប់ឬជ្រាបចូលដីទេ<br>- ត្រូវពង្រាបដីឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើ រួចដាំស្មៅឡើងវិញក្នុងតំបន់សាងសង់បង្គោលភ្លើងនេះ(15mX15m) ដោយធ្វើការសហការណ៍ជាមួយរដ្ឋអំណាច និងប្រជាពលរដ្ឋមូលដ្ឋាន និងស្ថាប័នជំនាញពាក់ព័ន្ធឱ្យបានល្អ ។<br>- បានគ្រប់គ្រងកាកសំណល់រឹងរាវគ្រប់ប្រភេទឱ្យបានត្រឹមត្រូវដូចជា: ចាត់វិធាន | |

| មជ្ឈដ្ឋានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ដីប្រជាពលរដ្ឋរស់នៅក្បែរកន្លែងនោះដែលធ្វើឱ្យដីនោះគ្មានជីជាតិ ។<br>- បង្កឱ្យមានការបំពុលដីដោយសារការប្រើប្រាស់សារធាតុគីមីផ្សេងៗក្នុងការសំអាត ឬបង្អាក់ការលូតលាស់របស់ឈើធ្វើឱ្យធ្លាក់ទៅលើដី ។<br>- ការឈូសកាប់ព្រៃស្រទាប់លើនៅតាមតំបន់ទីជំរាលជាដើមធ្វើឱ្យមានការហូរច្រោះដីនៅរដូវវស្សា និងមានសំណឹកដោយសារខ្យល់នៅរដូវប្រាំងដែលជាហេតុបណ្តាលឱ្យមានការបាត់បង់គុណភាពដីផងដែរ ។ | | | ✓ | ការយ៉ាងតឹងរឹង មិនឱ្យចាក់ ប្រេងម៉ាស៊ីនចាស់ៗ (ប្រេងបាត) ចោលទៅលើដី ។<br>- ត្រូវធ្វើការដាក់ទណ្ឌកម្មដល់អ្នកដែលប្រព្រឹត្តខុសដូចជា ស្តីបន្ទោសពិន័យ ឬការបណ្តេញពីការងារជាដើម ។<br>- មិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាតឬ បង្អាក់ការលូតលាស់របស់ឈើនោះទេ ។<br>- ត្រូវដាំស្មៅនៅតាមគន្លងខ្សែដែលមិនមានស្មៅ ឬឈើដុះក្នុងតំបន់ដីសារធារណៈឯកជនរបស់រដ្ឋ ដោយសហការ យ៉ាងជិតស្និទ្ធជាមួយរដ្ឋបាល ព្រៃឈើក្នុងតំបន់ ។ | |
| **សំលេង និង រំញ័រ** | - មានការរំខានដោយសំលេង និងរំញ័រខ្លាំងដោយសារសកម្មភាព សិក្សាត់រោងដូចជា ការខួងដីសម្រាប់ធ្វើគ្រឹះបង្គោលភ្លើង ដែលប្រើម៉ាស៊ីនខួង. ការដឹកជញ្ជូនបុគ្គលិក-កម្មករ និងសម្ភារដោយរថយន្តនិងសំលេងអ៊ូរអរនៃបុគ្គលិក-កម្មករសាងសង់ទាំងនោះ ។ | | | ✓ | - បានប្រើម៉ាស៊ីនខួងដីដែលមានកិរិតញ័រតិចនិងសំឡេងតិចដើម្បីកាត់បន្ថយសំឡេង និងរំញ័រដែលរំខានដល់សត្វព្រៃ ។ ក្រុមហ៊ុនបានអប់រំកម្មកររបស់គរោងមិនឱ្យមានការស្រែក ឬ ជជែកគ្នាខ្លាំងៗរំខានដល់សត្វព្រៃ ។ | |
| **ខ. ធនធានជីវសាស្ត្រ** | | | | | | |
| **ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ** | - ប៉ះពាល់ជាមធ្យមដល់គុណភាពទឹក អូរ ស្ទឹង នៅក្បែរការដ្ឋានសាងសង់ បង្គោលភ្លើង របស់គំរោង ដោយសារការ ងារដី ការងារបេតុងដែលមានជីស្អុយ (ដីដែលជីកពីស្រទាប់ ក្រោមគ្មាន ជីវជាតិ) ហូរច្រោះដោយសារភ្លៀង និងការកំពប់នូវសម្ភារសំណង់ ធ្វើឱ្យល្អក់ទឹកបណ្តាលឱ្យពុលដល់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹកនៃអូរស្ទឹងទាំងនេះ ។<br>- ប៉ះពាល់ដល់ជីវសាស្ត្ររស់នៅក្នុងទឹកដែលបណ្តាលមកពីសកម្មភាពសាងសង់គំរោង និងការបំពុលទឹក ដោយសារ កាកសំណល់រឹង-រាវចេញពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង ។ | | | ✓ | - ត្រូវដាំស្មៅតាមកន្លែងដែលសាងសង់បង្គោល និងដាំស្មៅនៅកន្លែងដែលកាប់សំអាតគន្លងដែលគ្មានស្មៅ ឬឈើដុះដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក ។<br>- បានអប់រំដល់បុគ្គលិក-កម្មករអំពីការបោះបង់កាកសំណល់រឹងរាវ ជាពិសេសការកំពប់ប្រេងឥន្ធនៈ ប្រេងរំអិល នៅលើដី និងក្នុងទឹកនៅក្នុងតំបន់គំរោង ។<br>- បានគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទទៅទីតាំងដែលមានសុវត្ថិភាព ។ | |
| **ព្រៃឈើការពារ /តំបន់ការពារ /ឧទ្យានជាតិ** | - អាចរំខានដល់ជំរកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ដែលស្ថិតនៅក្នុង តំបន់ព្រៃការពារភ្នំក្រវាញ និងព្រៃការពារជងទង់បន្តិចបន្តួចដែរដោយសារសកម្មភាពសាងសង់ដូចជាមានសំឡេងអ៊ូរអរក្នុងការកាប់ឈើតាមគន្លងខ្សែ ។ | | | ✓ | - បានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃដើម្បីមិនឱ្យរំខានសត្វព្រៃតែ ។ ម្យ៉ាងទៀតក្រុមសិក្សាបានបោះទីតាំងតែមួយកន្លែងដើម្បីបន្ថយការកាប់ព្រៃនិងរំខានសត្វព្រៃ<br>- បានធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងជនបញ្ញាពាក់ព័ន្ធដើម្បី ធ្វើការសិក្សាដោយមិនឱ្យរំខានជំរក និងការរស់នៅរបស់សត្វព្រៃ ក្នុងតំបន់ការពារ- | |

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | អភិរក្សភ្នំក្រវាញ និងព្រៃការពារដងទង់ឡើយ ។<br>-បានត្រាយតែមែកឈើតូចៗដើម្បីធ្វើដំណើរចូលកន្លែងសាងសង់ និងកាប់ឈើណាដែលនៅតាមគន្លងតែ ៣០មប៉ុណ្ណោះដើម្បីទុកឱ្យព្រៃនោះអាចដុះលូតលាស់ឡើងវិញ ។ | |
| ធនធានព្រៃឈើ /ជីវកសត្វព្រៃ | -ប៉ះពាល់ខ្លាំងទៅលើផ្ទៃដីសរុប ៤៨.៤៤ ហ.ត ក្នុងនោះ ប៉ះពាល់ដីព្រៃសរុប ៤.១៨៧.៨១ ហ.ត ដែលមានព្រៃស្រោងចំនួន ៣.៨៨៤.១២ ហ.ត និងព្រៃ ល្បាយឫស្សីចំនួន ៧០.៤៤ ហ.ត ដោយសារការសាងសង់បង្គោលភ្លើង និងខ្សែបញ្ជូនតង់ស្យុងខ្ពស់១១៥ គ.វ ពីអគារ ផាមពលទី១ និងទី២ មកអនុស្ឋានីយ៍អូរសោម ។ ហើយក៏បានប៉ះពាល់ព្រៃឈើនិងជីវកសត្វព្រៃដោយសារការសាងសង់អនុស្ថានីយអគ្គិសនីអូរសោម ដែលមានទំហំ០.៥ ហ.តផងដែរ ។<br>-មានការប៉ះពាល់ដល់ព្រៃឈើ ក៏ដូចជាជីវកសត្វព្រៃ ដោយសារការប្រើប្រាស់ថ្នាំគីមីដើម្បីសំអាត ឬបង្អាក់ការលូតលាស់របស់ឈើក្នុងការសាងសង់គំរោងនេះ ។<br>-បានធ្វើឱ្យរំខានដល់ការរស់នៅរបស់ពពួកសត្វព្រៃ ដែលមាននៅក្នុងនិងជុំវិញទីតាំងគំរោងដោយសារ មានសំលេង និងរំញ័រចេញពីគ្រឿងចក្រ រថយន្តម៉ាស៊ីនគ្រប់ប្រភេទពេលកំពុងធ្វើការងារការសាងសង់គំរោង ។ល។<br>-ប៉ះពាល់ដោយសាររំញ័រដោយសារការដឹកជញ្ជូន សម្ភារគំរោងធ្ងន់ៗ ដូចជាដឹកត្រង់ស្វូរជាដើម ។ល។ | | | ✓ | -បានធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានបង្ហាញនៅក្នុងប្លង់រចនាគំរោង លំអិតឡើយ ។<br>-បានធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើនិងក្រសួងបរិស្ថានដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលនឹងកើតមានឡើងជាយថាហេតុលើព្រៃឈើដែលនៅជាប់នឹងតំបន់គំរោងក្នុងដំណាក់កាលនៃការសាងសង់ប្រព័ន្ធខ្សែចម្លងនេះ ។<br>-បានធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថានដើម្បីធ្វើការសំអាតព្រៃក្នុងតំបន់តាមគន្លងខ្សែ ១១៥គ.វ ទទឹង៣០ម ។<br>-បានសហការជាមួយស្ថាប័នជំនាញ ឬអង្គភាពជំនាញមូលដ្ឋាន ក្នុងការថែ រក្សាការពារព្រៃឈើ និងជីវកសត្វព្រៃនៅជុំវិញអនុស្ថានីយ៍អគ្គិសនីអូរសោម និងនៅក្នុង និងក្បែរតំបន់គំរោងទៅតាមផែនការគ្រប់គ្រងធនធានបរិស្ថានដោយបង្កើតក្រុមល្បាតដើម្បីត្រួតពិនិត្យ និងការពារធនធានបរិស្ថានទាំងនោះឱ្យមានប្រសិទ្ធភាព ។<br>-មិនប្រើសារធាតុគីមីផ្សេងៗក្នុងការសំអាតឬ បង្អាក់ការលូតលាស់របស់ឈើនោះទេ ។<br>-បានប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនដែលមានសំលេងតិច ។<br>-បានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះ ដើម្បីកាត់បន្ថយការរំខានដល់សត្វព្រៃក្នុងតំបន់គំរោងនេះ ។<br>-បានធ្វើការអប់រំដល់បុគ្គលិកកម្មករគំរោងឱ្យចេះស្ងៀមស្ងាត់នៅពេលម៉ោងសំរាក និងនៅពេលយប់ ។ | |

Draft

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | - បានធ្វើការសហការជាមួយស្ថាប័នពាក់ពន្ធ័ ក្នុងការដឹកជញ្ជូនគ្រឿងសូរ និងប្រើរថយន្តពិសេសដែលមានកង់ច្រើន ក្នុងការបន្ថយទំងន់ និងរញ្ជួរ ។ | |
| ជីវសាស្ត្រ សត្វព្រៃ | - មានថនិកសត្វចំនួន ៥០ ហើយក្នុងពេលសិក្សា ព្រៃ នេះ មិនឃើញមាន ដំរី, ខ្លាធំ, ខ្លាឃ្មុំមាស, ក្ដាន់, គោព្រៃ, ក្របី, គោរមាំងស្លាប់ បាក់ពោះ... ក្បាលសប៉ែត និងកេះពីព្រោះព្រៃឈើក្នុងតំបន់ទាំងបី ត្រូវបានកាប់សំអាតបាតអស់ និងកំពុងសាងសង់វចនាសម្ព័ន្ធគំរោង ជាពិសេសមានមនុស្សចូលព្រៃក្បែរតំបន់គំរោងច្រើន ធ្វើឱ្យពួកវាភ័យខ្លាច មានហ៊ានចូលមកតំបន់នេះទេ ។<br>- បក្សីមាន ១៣០ប្រភេទ ឧរង្គសត្វ ៣៦ប្រភេទ ក្នុងពេលសិក្សា ព្រៃមានល្មូន២ប្រភេទមិន ឃើញមានដូចជា អណ្ដើកមាស និងអណ្ដើកក្របីក្បាលលឿង . ហើយនិងមច្ឆជាតិមាន ៣០ប្រភេទ ដូចមានចែងក្នុងជំពូក៥ ចំណុច ៥.១.២.២ ។<br>- បានធ្វើឱ្យមានការភ័យខ្លាចដល់សត្វព្រៃទាំងនោះដោយសារមានសំលេងរំខានខ្លាំងៗចេញពីម៉ាស៊ីនគ្រឿងយន្ត និងសំឡេងរបស់បុគ្គលិក-កម្មករគំរោង ។<br>- មានសកម្មភាពបរបាញ់ឬចាប់សត្វ ឬចូលព្រៃពីសំណាក់បុគ្គលិក-កម្មករគំរោងទាំងនោះធ្វើឱ្យផ្អើលនិងបាត់បង់ សត្វព្រៃ ការជួញដូរសត្វព្រៃនៅតំបន់គំរោងអាចមានការកើនឡើង ដូចជាការយកធ្វើម្ហូប ការធ្វើថ្នាំបុរាណបាយ [illegible] ។ | | | ✓ | - បានកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរញ្ជួរដើម្បីកុំឱ្យមានការ រំខាន ឬផ្អើលសត្វព្រៃក្នុងតំបន់គំរោងនិងតំបន់ជិតគំរោង ។<br>- បានកំណត់កំរិតល្បឿនក្នុងការដឹកជញ្ជូនសម្ភារសំណង់ឱ្យតិច និងប្រើប្រាស់ម៉ាស៊ីនដែលមានសំលេងនិងរញ្ជួរតិចដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃទាំងនេះ ។<br>- បានអប់រំ និងដាក់វិន័យដល់បុគ្គលិកកម្មករគំរោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វព្រៃនិងធ្វើជាចរលក់ដូរសត្វ ព្រៃនៅក្នុងតំបន់នេះឡើយ ។<br>- ត្រូវដាក់ផ្លាកសញ្ញាព្រៃការពារ និងហាមបរបាញ់ជាអក្សរខ្មែរ និងចិនឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋ និងចិនងាយមើលឃើញនៅតំបន់ព្រៃសហគមន៍ ។<br>- បានចូលរួមសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថានដើម្បីទប់ស្កាត់បទល្មើសសត្វព្រៃ និងព្រៃឈើ ។ | |
| **គ. ធនធានសេដ្ឋកិច្ចសង្គម** | | | | | | |
| ការប្រើប្រាស់ដី និង ការតាំងលំនៅដ្ឋាន ឡើងវិញ | - ការសាងសង់បង្គោលភ្លើងតង់ស្យុងខ្ពស់ ១១៥ គ.វ មានពីរខ្សែ គឺខ្សែទី១ពីអគារថាមពលទី១ មកអនុស្ថានីយ៍អូរសោមមានចំនួន១១បង្គោល និងខ្សែទី២ពីអគារថាមពលទី២ មកអនុស្ថានីយ៍អូរសោមចំនួន៣៣បង្គោលដែលក្នុងនោះ ប៉ះពាល់ចំនួន៦បង្គោលលើដីៈប្រើប្រាស់ទំហំ ១៣៥០ម២ ជាកម្មសិទ្ធរបស់ប្រជាពលរដ្ឋ២គ្រួសារ :ដោយសារមិន | | | ✓ | - បានរៀបចំផែនការការតាំងទីលំនៅឡើង វិញរបស់ប្រជាពលរដ្ឋដែលប៉ះពាល់ដោយសារគំរោង រួមទាំងមាន សំណងត្រឹមត្រូវ និងយុត្តិធម៌ ។<br>- មិនទន្ទ្រានយកដីរបស់ប្រជាពលរដ្ឋដែលបានកាន់កាប់ដោយសន្តិវិធី( យោងតាមច្បាប់ភូមិបាលមាត្រាលេខ ៣, ៥, ៨, ២៣, ២៥ និង ៣០) ឡើយដូចជាៈ ដីភូមិ ដីស្រែចំការ និងដីសហគមន៍ ។ | |

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | អនុញ្ញាតឱ្យមានការរស់នៅនិងមានដើមឈើកំពស់មិនលើសពី០៣ម និងនៅពីក្រោមគន្លងខ្សែចម្លងម្ខាង ១៥ម ពីអក្ស បង្គោលភ្លើង ដែលជាដីចំណីខ្សែចម្លង សរុប ៣០ម ។ | | | | - បានសហការជាមួយអាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធក្នុងការផ្សព្វផ្សាយជាសាធារណៈនូវការអនុវត្តន៍គំរោងនេះ ដោយមានការដោះស្រាយផលប៉ះពាល់សំណងជាសាច់ប្រាក់ (សំណូមពរអ្នកប៉ះពាល់ភាគច្រើនចង់បានជាសាច់ប្រាក់) លើដីស្រែ ចំការបុស្ស ដំណាំ និងការរុះរើលំនៅដ្ឋាន។<br>- បានសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ និងអាជ្ញាធរមូលដ្ឋានដើម្បីអនុវត្តទៅតាមការសំរេចចិត្តរបស់រាជរដ្ឋាភិបាល និងសម្របសម្រួលនូវ ទំនាស់ដីធ្លីទាំងឡាយណាដែលកើតមាន ដោយសារសកម្មភាពសាងសង់គំរោងនេះ។<br>- បានឱ្យអាទិភាពក្នុងការជ្រើសយកកំលាំងពលកម្មពីប្រជាពលរដ្ឋ ដែលប៉ះពាល់ដោយសារគំរោងដើម្បីធ្វើជាបុគ្គលិក-កម្មករគំរោង។ | |
| **ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន** | -ប៉ះពាល់តិចតួចដល់មុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ចំនួន ២គ្រួសារ ដោយសារប្រជាពលរដ្ឋទាំងនោះមានជិស្ថិតនៅក្រោម បញ្ជូនចរន្តតង់ ស្យុងខ្ពស់ ១១៥គ.វ នៃគំរោងវារីអគ្គិសនីអាតៃ នេះ។<br>- ប្រជាពលរដ្ឋនៅតាមគន្លងខ្សែចម្លងមានការភយ័ខ្លាចពីសុវត្ថិភាព ដោយខ្លាចឆក់ និងមានគ្រោះថ្នាក់ដោយសារចរន្តអគ្គិសនី និងរលំបង្គោលភ្លើង ។<br>-ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ មានការភ័យខ្លាចអំពីសុវត្ថិភាពរបស់ខ្លួននៅពេលមានការតវ៉ាអំពីសិទ្ធិរស់នៅ និងកិច្ចសន្យា ដែលបានចែងក្នុងផែនការនៃការតាំងលំនៅដ្ឋានឡើងវិញ។ | | ✓ | | - បានសហការជាមួយអង្គការពាក់ព័ន្ធនានា អាជ្ញាធរមូលដ្ឋាន ស្ថាប័នក្រសួងពាក់ព័ន្ធ ដែលតំណាងឱ្យរាជរដ្ឋាភិបាល ធ្វើការដោះស្រាយតាមការធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋាន ដោយមានសំណងដី ផ្ទះ ដំណាំ ការបាត់បង់ជីវភាពប្រចាំថ្ងៃ ហើយនិងគោរពតាមផែនការតាំងទីលំនៅដ្ឋានថ្មីឡើងវិញនេះឱ្យបានត្រឹមត្រូវបំផុត។<br>- បានជ្រើសរើសបុគ្គលិក-កម្មករសរុប៥២នាក់ ក្នុងនោះប្រជាពលរដ្ឋមូលដ្ឋានជាពិសេសអ្នកដែលប៉ះពាល់ដោយសារគំរោង ចំនួន៤០នាក់និងបុគ្គលិក-កម្មករចិន ១២នាក់។<br>- បានតំឡើងបង្គោលភ្លើងឱ្យមាំតាមបច្ចេកទេស ដោយធានាមិនឱ្យរលំនៅពេលមានព្យុះភ្លៀងធម្មតា។ ម្យ៉ាងទៀត កំពស់កន្លែងដក់របស់ខ្សែតង់ស្យុងខ្ពស់ពីដីមិនតិចជាង ៨ម (បទដ្ឋានរបស់អាជ្ញាធរអគ្គិសនីកម្ពុជាមិន តិចជាង ៧ម) ។<br>- បានសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដីផ្សព្វផ្សាយអំពីគោលបំណង និងគោលការណ៍ផ្តល់ សំណងនៃការប៉ះពាល់ដោយសារគំ រោងនេះ។ | |
| **ប្រពៃណី វប្បធម៌ និង សាសនា** | -ប៉ះពាល់ដល់ជំនឿ ប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ ដោយសារក្រុមហ៊ុនយកបុគ្គលិក-កម្មកររបស់ខ្លួនដែលមកពីតំបន់ឆ្ងាយខុសៗគ្នានិង | | ✓ | | - បានសិក្សាស្វែងយល់អំពីទំនៀមទំលាប់ ប្រពៃណី និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោងហើយផ្សព្វផ្សាយ និងគោរពទៅតាមប្រពៃណី ទំនៀម | |

| មធ្យមបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ពេលប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | មានសញ្ជាតិខុសៗគ្នា ។<br>- ប៉ះពាល់ដល់កន្លែងសក្ការៈបូជាទាំងឡាយដូចជា ព្រៃអ្នកតាឬទីទួល ព្រៃកប់ខ្មោចសំណាក់ម្ចាស់ទឹកដីក្នុងតំបន់ ។ល ។ | | | | ទំលាប់នេះដោយមិនធ្វើការបំពាន និងល្មើសឡើយ ។<br>- បានធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មកររបស់ខ្លួនអំពី ទំនៀមទំលាប់ប្រពៃណីប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ ។<br>- បានសហការជាមួយរដ្ឋអំណាចមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីបង្កើត និងអភិរក្សកន្លែងសក្ការៈបូជាទាំងឡាយដែលបាត់បង់នោះឡើងវិញដូចដែលមានកន្លងមកនៅភូមិរបស់គាត់ ។ | |
| **ការផ្គត់ផ្គង់ទឹកស្អាត** | - ប៉ះពាល់ដល់ការប្រើប្រាស់ទឹកអូរ ស្ទឹង ដោយសារសកម្មភាពសាងសង់ហេដ្ឋារចនា សម្ព័ន្ធរបស់តំរោង និងការគ្រប់គ្រងកាកសំណល់រឹង-រាវមិនបានល្អធ្វើឱ្យបំពុលដល់ប្រភពទឹកលើដី និងក្រោមដីដែលជាប្រភពដ៏សំខាន់ក្នុងការផ្គត់ផ្គង់ទឹកប្រជាពលរដ្ឋក្នុងតំបន់ ។<br>- បង្កឱ្យទឹកអូរ ស្ទឹងបាត់បង់គុណភាព ផងដែរដោយសារ កាកសំណល់រឹង-រាវចេញពីកន្លែងរស់នៅផ្ទះបាយ និងបង្គន់អនាម័យរបស់បុគ្គលិក-កម្មករនៃតំរោងការលេចធ្លាយប្រេងឥន្ធនៈនិងប្រេងរំអិលពីឧបករណ៍ឬគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ ។ | | | ✓ | - ការឈូសឆាយទ្រង់ទ្រាយធំ ក្រុមហ៊ុនបានធ្វើនៅរដូវវស្សាទេ ។<br>- ត្រូវធ្វើរបាំងការពារកករដីកុំឱ្យសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ហើយសាងសង់បង្គន់អនាម័យ និងបន្ទប់ទឹកឱ្យបានគ្រប់គ្រាន់ទៅតាមចំនួនបុគ្គលិក -កម្មករតំរោង ។<br>- បានធ្វើការអប់រំណែនាំបុគ្គលិក-កម្មករតំរោងឱ្យយល់ដឹងអំពីអនាម័យស្គាល់នូវកន្លែងទុកដាក់សំរាម ដែលក្រុមហ៊ុនបានរៀបចំកសាង ក្នុងទីតាំងស្នាក់នៅហើយដាក់ពិន័យដល់បុគ្គលិក-កម្មករណាដែលមិនព្រមធ្វើតាមការណែនាំ ។<br>- បានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវដោយសាងសង់បង្គន់អនាម័យ ព្រមទាំងរៀបចំប្រមូលសំណល់រឹងនិងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព ។<br>- បានសាងសង់អាងសិបទិកទំនើបដែលអាចសំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិកដែលស្នាក់នៅ នៅពេល ដំណើរការ និងថែទាំតំរោង ។<br>- បានសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។<br>- បានប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិប្រេងឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់តំរោង ។<br>- ត្រូវពង្រាបដី និងដាំស្មៅតាមកន្លែងដែលសង់គ្រឹះបង្គោលភ្លើង (ព្រោះមានដីស្មួយគ្មានជីវជាតិស្មៅមិនដុះនាំឱ្យមានការហូរច្រោះបំពុលគុណភាពទឹក) | |

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំរោតទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ដើម្បីការពារការហូរច្រោះដែលអាចធ្វើឱ្យមានការបំពុលទឹក ។ | |
| **តំបន់ទេសចរណ៍ /រមណីយដ្ឋាន /ទីកន្លែងកំសាន្ត** | - នៅតំបន់គំរោងជាតំបន់ដាច់ស្រយាល ពុំទាន់មានរមណីយដ្ឋាន និងទីកន្លែងកំសាន្តនៅឡើយទេ ។ | | | | | |
| **ផ្លូវគមនាគមន៍** | - ប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ក្នុងតំបន់ដោយសារសកម្មភាពសាងសង់គំរោង និងការដឹកជញ្ជូនសំភារៈបរិក្ខាអគ្គិសនី ជាពិសេសការដឹកជញ្ជូនត្រង់ស្វូនិងគ្រឿងចក្រចូលទៅទីតាំងគំរោងបណ្តាលឱ្យមានការស្រុត ឬខូចផ្លូវ ការបាក់ស្ពាន ការកកស្ទះចរាចរ ឬគ្រោះថ្នាក់ចរាចរលើខ្លែងផ្លូវដែលមានចំណោទឡើងចូល និងផ្លូវកោង ។ល ។<br>- អាចមានគ្រោះថ្នាក់ចរាចរនៅពេលដែលតំលើងខ្សែភ្លើង កាត់ផ្លូវ និងស្ទឹងដោយសារកំពស់ខ្សែមិនទាន់ទាញបានដល់ចំណុចកំពស់ដែលបានគ្រោង ។ | | ✓ | | - បានធ្វើការកែលំអផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវថ្មីនៅតំបន់ផ្លូវចូលមុខអនុស្ថានីយ៍ ដែលអាចធានាដល់ការប្រើប្រាស់របស់គំរោងហើយធ្វើការពិភាក្សាជាមួយស្ថាប័នជំនាញក្នុងការដឹកជញ្ជូនសម្ភារធ្ងន់ៗដូចជាត្រង់ស្វូដែលមានទំងន់ដល់ទៅ ៥០តោន ។<br>- បានសហការជាមួយមន្ទីរពាក់ព័ន្ធធ្វើការដោះស្រាយសំរួលចរាចរក្នុងតំបន់មានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន និងសំរួលចរាចរនៅពេលដឹកជញ្ជូនត្រង់ស្វូ ។<br>- បានធ្វើការជួសជុលផ្លូវក្នុងតំបន់គំរោងឱ្យបានល្អ និងធ្វើការថែរក្សាផ្លូវដែលខ្លួនបានប្រើប្រាស់ជាប្រចាំ ។<br>- បានគ្រោងតំលើងកំពស់ខ្សែទាបបំផុតពី១៩ម(ស្តង់ដាអគ្គិសនី១៤.២ម) ហើយនឹងអនុវត្តការតំឡើងខ្សែចម្លងនេះភ្លាមៗ គឺមិនបន្ទាយខ្សែឆ្លងកាត់ផ្លូវចោលនោះទេ ។<br>- បានធ្វើសេចក្តីជូនដំណឹងទៅអាជ្ញាធរ និងដាក់ស្លាកប្រកាសអំពីការដ្ឋាន កំពុងសាងសង់ចំងាយពីការដ្ឋាន១០០ម និងស្នើសុំឱ្យមានសមត្ថកិច្ចផ្នែកចរាចរមកជួយធ្វើអន្តរាគមន៍ នៅពេលតំឡើងខ្សែចម្លងនេះ ។ | |
| **សុខភាពសាធារណៈ** | - ប៉ះពាល់ជាមធ្យមដល់សុខភាពបុគ្គលិក-កម្មករ របស់ក្រុមហ៊ុន និងប្រជាពលរដ្ឋក្នុងតំបន់ ដោយសារធូលីដី ធូលីស៊ីម៉ងត៍ចំហាយចេញពីការប្រើប្រាស់ សារធាតុគីមីជាដើម ។<br>**- ប៉ះពាល់ដល់សុខភាពបុគ្គលិក-កម្មកររបស់គំរោង ដោយសារតំបន់ខ្លះនៃ** គំរោងនេះជាតំបន់ដែលកើត ជំងឺគ្រុនចាញ់ និងគ្រុនសន្ធំ ។<br>- ប្រជាពលរដ្ឋនៅតំបន់គំរោងអាចឆ្លងជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេងជំងឺឆ្លងផ្សេងៗពីបុគ្គលិក-កម្មករគំរោងដែលជ្រើសរើសមកពីឆ្ងាយ | | | | - បានប្រកាន់យកការរក្សាសុវត្ថិភាពការងារជាចំបងក្នុងសកម្មភាពការងារប្រចាំថ្ងៃ<br>- បានផ្តល់ម៉ាស់ការពារធូលីដីដល់បុគ្គលិកកម្មករគំរោង និងធ្វើការស្រោចទឹកលើផ្លូវថ្នល់ដែលខ្លួនប្រើប្រាស់ក្នុងការសាងសង់គំរោងនេះ ។<br>**- បានសាងសង់ជំរុំស្នាក់នៅរបស់បុគ្គលិក-កម្មករគំរោងឱ្យបានសមរម្យដោយមាន** ការផ្គត់ផ្គង់ទឹកស្អាតមានបង្គន់អនាម័យបន្ទប់ទឹកគ្រប់គ្រាន់និងមានកម្មវិធីអប់រំសុវត្ថិភាពការងារដល់បុគ្គលិក-កម្មកររបស់គំរោង ។<br>- មានគ្រូពេទ្យដែលមានសមត្ថភាពនៅប្រចាំការក្នុងការដ្ឋាន និងជំរុំស្នាក់នៅ | |

Draft

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | ដោយក្រុមហ៊ុនផងដែរ ។<br>-ប៉ះពាល់ដល់សុខភាពសាធារណៈ( ប្រជាជនក្នុងតំបន់ និងបុគ្គលិក-កម្មករតំរោង) ដោយសារការប្រើប្រាស់ ឬចរាចរគ្រឿងញៀន ។<br>-ប៉ះពាល់ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មករគំរោងដោយសារមិនចាប់អារម្មណ៍អំពីសុវត្ថិភាពការងារ ។<br>-បង្កឱ្យមានគ្រោះថ្នាក់ដល់កម្មករតំលើងខ្សែ និងបង្គោលដោយសារការឆក់( ទោះបីជាមិនទាន់ភ្ជាប់ចរន្តក៏ដោយ) ដោយសាររន្ទះបើមានអាកាសធាតុមិនល្អចរន្តអគ្គិសនីនឹងស្រូបចូលតាមខ្សែឬបង្គោលធ្វើឆក់អ្នកដែលប៉ះខ្សែផ្ទាល់ ឬបង្គោលដែកនេះ ។<br>-អាចមានប្រជាពលរដ្ឋ ឬជនហោម្នាក់ឡើងបង្គោលភ្លើងអាចបណ្តាលឱ្យមានគ្រោះថ្នាក់ធ្លាក់ឬមានការឆក់( ទោះបីជាមិនទាន់ភ្ជាប់ចរន្តក៏ដោយ<br>-អាចមានការផ្ទុះសេខ្សែភ្លើងនៅពេលខ្សែនៅគ្រប់ចំណុចដែលខ្សែតង់ស្យុងខ្ពស់ និងខ្សែតង់ស្យុងមធ្យមដទៃទៀត ឆ្លងកាត់ពីលើគ្នា ។ | | ✓ | | របស់កម្មករ និងត្រៀមថ្នាំពេទ្យ និងបរិក្ខាគ្រប់គ្រាន់ជាប្រចាំសំរាប់ការពិនិត្យ និងព្យាបាលជូនបុគ្គលិក-កម្មកររបស់គំរោង ហើយមានរថយន្តសង្គ្រោះបន្ទាន់ នៅពេលដែលមានករណីគ្រោះថ្នាក់កើតឡើងជាយថាហេតុ ។<br>-បានរៀបចំប្រព័ន្ធសុវត្ថិភាពខ្ពស់ ការពារមិនឱ្យមានគ្រោះថ្នាក់ដល់កម្មករតំលើងខ្សែ និងបង្គោលដោយសារការឆក់( ទោះបីជាមិនទាន់ភ្ជាប់ចរន្តក៏ដោយ) ដោយសាររន្ទះធ្វើឆក់អ្នកដែលប៉ះខ្សែផ្ទាល់ ឬបង្គោលដែកនេះ ។<br>-បានធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មកររបស់ខ្លួនក្នុងការទប់ស្កាត់ជំងឺទាំងនោះកុំឱ្យឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ ។<br>-បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ពិសេសទប់ស្កាត់ការជួញដូរចរាចរគ្រឿងញៀន និងមនុស្ស ។<br>-បានតំលើងខ្សែការពាររន្ទះ និងប្រព័ន្ធសុវត្ថិភាពការពារឆក់ នៅពេលដែលកើតមានចរន្ត អគ្គិសនី ដោយចៃដន្យដែលបណ្តាលមកពីអាកាសធាតុ ។<br>-បានសហការជាមួយស្ថាប័នសុខាភិបាលនៅក្នុងតំបន់នេះ ដើម្បីការពារទប់ស្កាត់ជំងឺឆ្លងផ្សេងៗដែលកើតមានឡើងជាយថាហេតុ ។<br>-បានសាងសង់ថាសដែកការពារសត្វ-មនុស្សភ្ជាប់នឹងបង្គោលអគ្គិសនីទាំងបួនកុំឱ្យសត្វ-មនុស្សឡើងបាន និងមានដាក់ស្លាកសញ្ញាហាមឃាត់ទៀតផង ។<br>-ត្រូវតំលើងខ្សែនៅគ្រប់ចំណុចដែលខ្សែតង់ស្យុងខ្ពស់ និងខ្សែតង់ស្យុងមធ្យមដទៃទៀត ឆ្លងកាត់ពីលើគ្នាដោយធានាសុវត្ថិភាពកុំឱ្យមានការឆ្លងចរន្តធ្វើឱ្យផ្ទុះដាច់ខ្សែ ដោយឱ្យចំណុចនេះមានគំលាតខ្សែពីគ្នាមិនតិចជាង ៣.៥មនោះទេ ។ | |
| **សោភ័ណ្ឌភាព /ទេសភាព** | -ប៉ះពាល់តិចតួចដល់សោភ័ណ្ឌភាពទេសភាពក្នុងតំបន់ ដោយសារការតំឡើងបង្គោលមិនមានការរត់ត្រង់គ្នា ឬកំពស់មិនស្មើ គ្នាជាដើម ។ល ។<br>-ប៉ះពាល់ដល់សោភ័ណ្ឌភាពដល់តំបន់ការពារ និងអភិរក្សទាំងនោះដែរ ដោយសារការរៀបចំបង្គោល ខ្សែបណ្តាញ ភ្លើងមិនរត់តាមផ្លូវល្អនិងកាប់ឆ្ការព្រៃឈើក្នុងតំបន់នេះ ។ | ✓ | | | -បានជ្រើសយកការតំរង់ទិស និងកំពស់ទៅតាមស្ថានភាពដី ( កំពស់ចាប់ពី ៣៥-៦៥ម) ឱ្យបានសមស្របដើម្បីបន្ថយការរំខានដល់ការមើលឃើញ ទេសភាពតាមដងផ្លូវពីសំណាក់អ្នកធ្វើដំណើរឆ្លងកាត់ តំបន់នេះ ។<br>-ត្រូវធ្វើគន្លងខ្សែនាំអគ្គិសនី ឱ្យបានត្រង់ល្អ ដើម្បីមើលទៅរត់ត្រង់ជួរគ្នា ។<br>-បានធ្វើការស្រោចទឹកជាប្រចាំទៅលើផ្លូវថ្នល់ដែលខ្លួនកំពុងប្រើប្រាស់សាងសង់ | |

Draft

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | - ការហុយធូលីដោយសារការដុតព្រៃសំរាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម ក៏ធ្វើឱ្យប៉ះពាល់ដល់សោភ័ណ្ឌភាព និងទេសភាពកន្លែងនោះដែរ ។ | | | | រោង ។ | |
| ហានិភ័យ (Risk) | - អាចមានហានិភ័យ ដោយសារគ្រោះធម្មជាតិ ការកើតមានការរញ្ជួយដី បន្ទុះភ្នំភ្លើង នៅក្នុងតំបន់គំរោង ការទទួលរងឥទ្ធិពលពីព្យុះទីហ្វុង ឬព្យុះផ្សេងទៀត ដែលជាហេតុបង្កឱ្យមានមហន្តរាយធំៗ រលំបាក់ ឬ ដាច់ខ្សែភ្លើង និងការខូចហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ដែលកំពុងសាងសង់ ការបាត់បង់ ឬខូចខាតសំភារៈ និងគ្រឿងចក្រ សាងសង់ ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិកកម្មករ ព្រមទាំងប្រជាពលរដ្ឋនៅក្នុង /ក្បែរខាងតំបន់ គំរោង ។<br>- កើតមានការផ្ទុះសំភារៈគ្រឿងផ្ទុះ ឆេះប្រេងឥន្ធនៈ នៅកន្លែង ឬឃ្លាំងស្តុករបស់គំរោង និងការឆេះព្រៃក្នុងតំបន់គំរោង ដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភាវកម្ម ។<br>- អាចកើតមានសង្គ្រាមឈ្លានពានលើបូរណៈភាពទឹកដីនៃប្រទេសកម្ពុជា ក៏ជាឧបសគ្គដល់ការងារសាងសង់គំរោង ឬសង្គ្រាម អាចបំផ្លាញគំរោងទាំងស្រុងក៏សឹងមាន ។ | | | ✓ | - បានធ្វើការសិក្សារចនាឬវិស្វកម្ម និងគុណភាពការសាងសង់ដែលអាចធានាមិនឱ្យមានការបាក់រលំបង្គោល ឬ ដាច់ខ្សែ នៅពេលមានព្យុះភ្លៀង ធម្មតា ។<br>- បានប្រុងប្រយ័ត្នគ្រប់វិធានទី ក្នុងការការពារសុវត្ថិភាព ចំពោះគ្រឿងផ្ទុះ ការឆេះព្រៃ និងឆេះប្រេងឥន្ធនៈ ដោយធ្វើការសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់រាល់អំពើភេវរកម្មក្នុងតំបន់គំរោងឱ្យទាន់ពេលវេលា ។<br>- ត្រូវធ្វើការជូនដំណឹងរាល់ហេតុការណ៍ ដោយសារគ្រោះធម្មជាតិទាំងនោះជាបន្ទាន់ដល់អនុស្ថានីយអូរសោម ដើម្បីផ្តាច់ចរន្តឱ្យទាន់ពេលវេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិភ័យកើតឡើងដែលអាចបង្កដល់ ការបាក់រលំឬដាច់ខ្សែបណ្តាលឱ្យគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋក្នុងតំបន់ គំរោង ។<br>- បានរៀបចំបំរុងទុកនូវយានយន្តសង្គ្រោះសម្ភារ និងថវិកាដើម្បីធានាការសង្គ្រោះជាបន្ទាន់នូវហេតុការខាងលើ នេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាពខ្ពស់ ។ | |
| **២. ដំណាក់កាលប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance)** | | | | | | |
| **ក. ធនធានរូបសាស្ត្រ** | - នៅក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះ ធនធានរូបសាស្ត្រ គឺមានប៉ះពាល់ទៅលើការបំពុលទឹក (លើដី និងក្រោម ដី) តែប៉ុណ្ណោះ ។ | | | | | |
| **ការបំពុលទឹក (លើដី និង ក្រោម ដី)** | - ប៉ះពាល់តិចតួចទៅលើគុណភាពទឹកលើដី និងក្រោមដីដោយសារការប្រើប្រាស់សារធាតុគីមីដើម្បី បង្អាក់កាលូតរបស់ដើមឈើក្នុងពេលដំណើរការគំរោងនេះ ។<br>- **មានការបំពុលទឹកដោយសារការលេចធ្លាយ ឬកំពប់ប្រេងគ្រប់ប្រភេទដែលក្រុមហ៊ុនយកមកដំណើរការថែទាំគំរោងនេះរួចហូរចូលទៅក្នុងប្រភពទឹកទាំងនោះ ។** | ✓ | | | - មិនប្រើប្រាស់សារធាតុគីមីដើម្បីសំអាត ឬបង្អាក់ការលូតលាស់ របស់ដើមឈើនោះទេ ។<br>- បានសាងសង់សំណង់រណ្តៅបេតុងពីក្រោមត្រង់ស្វូ ការពារការលេចធ្លាយឬកំពប់ប្រេងដែលប្រើសំរាប់ត្រង់ស្វូទាំងនោះ ។ ចំពោះប្រេងចាស់ដែលដូររួចហើយ ឬប្រេងដែលមាននៅក្នុងរណ្តៅ និងយកទៅ ប្រើជាគ្រឿងចំហេះផ្សេងៗ ។<br>- បានធ្វើការគ្រប់គ្រងយានយន្ត គ្រប់ប្រភេទមិនឱ្យលេចធ្លាយប្រេងដែលជាហេតុនាំឱ្យមានការបំពុលទឹកនេះទេ ។ | |

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | ចំណាត់ថ្នាក់នៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការកាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| ៥. ធនធានជីវសាស្ត្រ | | | | | | |
| ជីវសាស្ត្រដែលរស់នៅក្នុងទឹក /មច្ឆជាតិ | -ប៉ះពាល់តិចតួច ដោយសារការបង្ហូរកាកសំណល់រាវចេញពីអនុស្ថានីយ៍អគ្គិសនី អូរសោមធ្វើឱ្យប៉ះពាល់ដល់កត្តាជីវសាស្ត្រដែលរស់នៅក្នុងទឹក ឬមច្ឆជាតិដែលរស់នៅក្នុងប្រភពទឹកក្បែរនោះ ។ | ✓ | | | -មិនបង្ហូរសំណល់រាវដែលចេញពីការិយាល័យ រោងជាង កន្លែងត្រង់សួរ ឃ្លាំង នៃអនុស្ថានីយ៍អគ្គិសនីអូរសោមដោយផ្ទាល់ចូលទៅក្នុងប្រព័ន្ធប្រឡាយទឹកធម្មជាតិនេះទេ ។<br>-បានសាងសង់អាងសិបទិកទំនើបសំរាប់កាកសំណល់រាវឬទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក កម្មករដែល ស្នាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំតំរោង ។ | |
| ព្រៃឈើការពារ /តំបន់ការពារ /ឧទ្យានជាតិ | -នៅក្នុងតំណាក់កាលប្រតិបត្តិ និងថែទាំនេះ មិនមានប៉ះពាល់ទៅលើដីតំបន់ការពារតទៅទៀតនោះទេ ព្រោះមានប៉ះពាល់ ខ្លាំងតែនៅក្នុងដំណាក់កាលសាងសង់ប៉ុណ្ណោះ ។ | | | | | |
| ធនធានព្រៃឈើ /ជំរកសត្វ ព្រៃ | -ប៉ះពាល់ជាមធ្យមដល់ធនធានព្រៃឈើ ដែលជាជំរកសត្វព្រៃ ច្រើនប្រភេទដូចមាន ចែងក្នុង ជំពូក ៥ ចំណុច ៥.១.២.១ ដោយសកម្មភាពកាប់សំអាតមែក ឬដើមឈើតាមគន្លងខ្សែនេះ ដោយមិនឱ្យខ្ពស់ជាង ៣ម ដែលជាការ រំខាន ផ្អើលសត្វផងដែរ ។<br>-អាចកើតមានឡើងភ្លើងឆេះព្រៃក្បែរតំបន់តំរោង ដោយសារការផ្ទុះសេខ្សែភ្លើង(មែកឈើដុះលូតទៅប៉ះដែនរបស់ខ្សែភ្លើងនេះនារដូវប្រាំងស្ងួតធ្វើឱ្យមានការឆេះព្រៃ ។ | | ✓ | | -ការថែទាំគន្លងខ្សែភ្លើងនេះធ្វើតែពេលថ្ងៃតែប៉ុណ្ណោះ ពីព្រោះនៅពេលយប់សត្វព្រៃភាគច្រើនរកស៊ី និងខ្លះទៀតដេកនៅក្នុងព្រៃក្បែរៗតំបន់ខ្លះនៃតំរោងនេះ ។<br>-បានធ្វើការអប់រំ និងហាមឃាត់ដល់បុគ្គលិក-កម្មកររបស់តំរោង មិនឱ្យទន្ទ្រានចូលព្រៃធ្វើការបរបាញ់ ឬដាក់ អន្ទាក់ ឬដូញដូរសត្វព្រៃ ។<br>-ត្រូវដាក់វិន័យដល់បុគ្គលិកកម្មករណាដែលប្រព្រឹត្តិល្មើស និងការហាមឃាត់ខាងលើ ។<br>-ត្រូវធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងរដ្ឋអំណាចមូលដ្ឋានដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលកើតឡើងដោយថាហេតុនៅក្នុងតំបន់តំរោង ។<br>-ត្រូវបំពាក់នូវឧបករណ៍សម្ភារសំរាប់ពន្លត់អគ្គីភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៍ស្វ័យប្រវត្តិនៅតំបន់ព្រៃការពារ និងអភិរក្សទាំងនេះសំរាប់ផ្តល់សញ្ញាដល់អនុស្ថានីយ៍អូរសោម នៅពេលមានអគ្គិភ័យកើតឡើង ។ | |
| ជីវសាស្ត្រ សត្វព្រៃ | -ការទន្ទ្រានចូលព្រៃធ្វើការបរបាញ់ ដាក់អន្ទាក់ និងចាប់សត្វពីសំណាក់បុគ្គលិក-កម្មករដែលធ្វើប្រតិបត្តិការ និងថែទាំតំរោងតំបណ្តាលឱ្យមានផលប៉ះពាល់ដល់សត្វព្រៃក្នុងតំបន់នេះផងដែរ ។ | | | ✓ | -ហាមឃាត់ដាច់ខាតដល់បុគ្គលិក-កម្មកររបស់ខ្លួនក្នុងការប្រមាញ់ ឬដូញដូរសត្វព្រៃ នៅក្នុងនិងក្បែរខាង តំបន់តំរោង ។<br>-អប់រំនិងដាក់វិន័យដល់បុគ្គលិក-កម្មករតំរោងមិនឱ្យធ្វើការចាប់ ឬបរបាញ់សត្វ | |

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | - អាចមានគ្រោះថ្នាក់ដល់សត្វស្វា ដោយសារសត្វនេះឡើងបង្គោលភ្លើង ហើយបញ្ឆេហូលឱ្យឆក់ ។ | | | | ព្រៃ និងធ្វើចរាចរលក់ដូរ សត្វព្រៃនៅក្នុងតំបន់នេះឡើយ ។<br>- ត្រូវសាងសង់ថាសសុវត្ថិដែកការពារជើងទាំង៤របស់បង្គោលកុំឱ្យមនុស្សសត្វឡើង ។ | |
| **គ. ធនធានសេដ្ឋកិច្ចសង្គម** | | | | | | |
| **ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋាន ឡើងវិញ** | - មិនមានផលប៉ះពាល់ទៅលើការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋឡើតទេ ព្រោះផលប៉ះពាល់បានកើតឡើង និងដោះស្រាយរួចទៅហើយនៅក្នុងដំណាក់កាលសាងសង់ ។<br>- ប៉ុន្តែអាចមានការចូលទន្រ្ទានកាន់កាប់ដីព្រៃចាប់យកដីធ្វើជាកម្មសិទ្ធិពីសំណាក់ជនឱកាសនិយម ឬការប្រមូលទិញដីដើម្បីធ្វើកសិកម្មពីប្រជាពលរដ្ឋដែលធ្វើឱ្យពួកគាត់ខ្វះដីបង្កបង្កើនផល រួចគេក៏កាប់រានដីព្រៃធ្វើកសិកម្មនាំឱ្យវិនាសហិនហោចដីព្រៃការពារទាំងនោះទៀតផង ។ | | | | - ត្រូវធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីទប់ស្កាត់បទល្មើសព្រៃ ឈើ និងសត្វព្រៃនិងត្រូវដាក់ផ្លាកបាំងលួច១ដូចនៅតាមផ្លូវទៅខេត្តកោះកុងជាដើម ។ ជាងនេះទៅទៀតក្រុមហ៊ុនមានថវិកាសំរាប់អ្នកល្បាត ៩ នាក់ សំរាប់រយៈពេល ៦ឆ្នាំ ចំនួន១២៤.២០០ ដុល្លារអាមេរិក និង ថវិកាចំនួន ៥០.០០០ដុល្លារអាមេរិក ការអប់រំបរិស្ថាន និងលើកបាំងលួចក្នុងតំបន់ទាំងនេះ ។ | |
| **ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន** | - នៅដំណាក់កាលនេះ មិនមានប៉ះពាល់ទៅដល់មុខរបររស់នៅរបស់ប្រជាពលរដ្ឋនោះទេ ផ្ទុយទៅវិញ បានបង្កើតការងារធ្វើ ទៅដល់ប្រជាពលរដ្ឋនៅមូលដ្ឋាននោះវិញ ។ | | | | | |
| **ប្រពៃណី វប្បធម៌ និង សាសនា** | - ប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ក្រុមហ៊ុននាំយកបុគ្គលិក-កម្មករតំរោងមកពីតំបន់ផ្សេងទៀត ឬ ជនបរទេស ។ | ✓ | | | - ត្រូវធ្វើការណែនាំអប់រំដល់បុគ្គលិក-កម្មកររបស់តំរោងឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋរស់នៅជុំវិញក្នុងតំបន់ទីតាំងតំរោង ។<br>- ត្រូវដាក់វិន័យដល់បុគ្គលិក-កម្មករតំរោងដែលបំពានលើទំនៀមទំលាប់ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់ ។ | |
| **ការផ្គត់ផ្គង់ទឹកស្អាត** | - អាចមានការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់បុគ្គលិក-កម្មករ តំរោង ដោយ សារបំរើការងារនេះ ពុំទាន់មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទេ ។<br>- ការគ្រប់គ្រងកាកសំណល់រឹង-រាវដែលចេញពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករ ឃ្លាំងស្តុកសំភារៈ រោងជាងជាដើមដែលធ្វើឱ្យខូចដល់ប្រភពទឹកសំរាប់ផ្គត់ផ្គង់ក្នុងតំបន់ ។ | | ✓ | | - បានសាងសង់អាងសិបទិកទំនើបសំរាប់កាកសំណល់រាវឬ ទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក-កម្មករដែលស្នាក់ នៅនិងធ្វើប្រតិបត្តិការ និងថែទាំតំរោង ។<br>- **ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងកាកសំណល់រឹង-រាវ** ដោយសាងសង់បង្គន់អនាម័យព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាព ។ | |

Draft

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ចំពាំងហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | - ត្រូវធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធដើម្បីកែប្រែតំបន់នោះឱ្យមានអនាម័យ និង បរិស្ថានល្អ ។ | |
| តំបន់ទេសចរណ៍ /រមណីយដ្ឋាន /ទីកន្លែងកំសាន្ត | - នៅតំបន់តំរោងជាតំបន់ដាច់ស្រយាល ពុំទាន់មានរមណីយដ្ឋាន និងទីកន្លែងកំសាន្តនៅឡើយទេ ។ | | | | | |
| ផ្លូវគមនាគមន៍ | - ការកកចង្អៀតលើដងផ្លូវ និងបង្កឱ្យមានគ្រោះថ្នាក់ដោយសារសកម្មភាពថែទាំតំរោងការធ្វេសប្រហែសក្នុងការបើកបររបស់បុគ្គលិក-កម្មករតំរោង ។<br>- មានការខូចខាតផ្លូវ ដោយសារការថែទាំគន្លងខ្សែភ្លើងនេះ ។ | ✓ | | | - ត្រូវធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បី សំរួលចរាចរនៅពេលដែលមានការថែទាំគន្លងខ្សែម្តងៗ ។<br>- ត្រូវធ្វើការថែទាំជួសជុលផ្លូវឬពង្រីកផ្លូវដើម្បីធានាសុវត្ថិភាព និងសំរួលចរាចរក្នុងតំបន់តំរោងឱ្យបានល្អប្រសើរ ។<br>- បានជ្រើសរើសអ្នកបើកបរដែលមានបទពិសោធន៍ និងមានស្មារតីល្អ ។ | |
| សុខភាពសាធារណៈ | - អាចបង្កឱ្យមានការប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះដោយសារបុគ្គលិក-កម្មកររបស់ក្រុមហ៊ុនអាចចម្លងជំងឺផ្សេងៗដល់អ្នកភូមិ ដូចជាជំងឺអេដស៍ ជំងឺកាមរោគ។ល។<br>- មានការប៉ះពាល់ដល់សុខភាពសាធារណៈដោយសារការគ្រប់គ្រងសំណល់រឹង-រាវមិនបានល្អ ។<br>- អាចមានគ្រោះថ្នាក់ដល់អាយុជីវិតប្រជាពលរដ្ឋរស់នៅពីក្រោម ពីព្រោះមានប្រជាពលរដ្ឋចំនួន២គ្រួសារដែលមានដីនៅតាមគន្លងនេះឬធ្វើដំណើរកាត់តាមគន្លងខ្សែបញ្ជូនចរន្ត ១១៥គ.វ៉ុល នេះ ដោយសារការរងនូវឥទ្ធិពលដែនអគ្គិសនីភ្លាមអាំងឌុចស្យុងអេឡិកត្រូស្តាទិកនិងអេឡិកត្រូម៉ាញ៉េទិក | | | ✓ | - ត្រូវធ្វើការពិនិត្យតាមដានគុណភាពទឹកដែលបញ្ចេញពីកន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករឱ្យបានទៀងទាត់ជាប្រចាំ ប្រសិនបើគុណភាពទឹកដែលបញ្ចេញទៅក្រៅនេះមានការបំពុល ក្រុមហ៊ុននឹងវិនិយោគមធ្យោបាយដើម្បីធ្វើការកាត់បន្ថយដោយសហការជាមួយស្ថាប័នពាក់ពន្ធ័ ។<br>- ត្រូវធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក-កម្មករ ដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំឱ្យកើតមាន និងឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ ។<br>- ត្រូវធ្វើការសហការជាមួយស្ថាប័នសុខាភិបាលដើម្បីទប់ស្កាត់ជំងឺឆ្លងដែលកើតឡើងជាយថាហេតុ ។<br>- ត្រូវគ្រប់គ្រងកាកសំណល់រឹង-រាវឱ្យបានល្អ តាមបទដ្ឋានបច្ចេកទេស ។<br>- ត្រូវធ្វើផែនការបំលាស់ប្តូរទីតាំងផ្ទះអ្នកដែលប៉ះពាល់ ទាំងនោះឱ្យចេញផុតពីតំបន់គ្រោះថ្នាក់ដោយសារដែនអគ្គិសនីនេះឱ្យបានយុត្តិធម៌ដែលអាចប្រជាពលរដ្ឋទាំងនោះទទួលយកបាន ដោយធ្វើការសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាបន័ពាក់ពន្ធ័មុននឹងភ្ជាប់ចរន្ត ។<br>- ត្រូវធ្វើការផ្សព្វផ្សាយជាប្រចាំអំពីគ្រោះថ្នាក់ក្នុងន័យអប់រំមិនឱ្យពួកគាត់មករស់នៅក្រោមឬលើកបង្គោលលោហៈក្នុងចំណីខ្សែឬឡើងបង្គោលភ្លើងឬឡើងដើម | |

Draft

| មធ្យោបាយបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| | | | | | ឈើដែលដុះក្នុងតំបន់ដែនអគ្គិសនីនេះ ។ ជាងនេះទៅទៀតត្រូវដាក់ផ្លាកសេចក្តីជូនដំណឹងអំពីដីចំណីតន្លងខ្សែភ្លើងនេះ ។<br>- បានធ្វើការផ្សព្វផ្សាយជាប្រចាំអំពីគ្រោះថ្នាក់ក្នុងន័យអប់រំមិនឱ្យពួកគាត់មករស់នៅក្រោមឬលើកបង្គោលលោហៈក្នុងចំណីខ្សែ ឬឡើងបង្គោលភ្លើង ឬឡើងដើមឈើដែលដុះក្នុងតំបន់ដែនអគ្គិសនីនេះ ។ | |
| សោភ័ណ្ឌភាព /ទេសភាព | - សោភ័ណ្ឌភាព /ទេសភាពនៅក្នុងតំបន់គំរោងក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំនេះមិនមានផលប៉ះពាល់ទេ ប៉ុន្តែរងផលប៉ះពាល់ខ្លាំងនៅក្នុងដំណាក់កាលសាងសង់ ហើយក៏ត្រូវបានក្រុមហ៊ុនសំអាត និងរៀបចំឡើងវិញរួចរាល់ដែរ ។ | | | | | |
| ហានិភ័យ (Risk) | - អាចមានហានិភ័យដោយសារគ្រោះធម្មជាតិ ការធ្វេសប្រហែសផ្នែកសន្តិសុខ និងអំពើភាវវកម្ម ឬសង្គ្រាម ។<br>- ការកើតមានការរញ្ជួយដី ឬបន្ទុះភ្នំភ្លើងនៅក្នុងតំបន់គំរោងការទទួលរងឥទ្ធិពលពីព្យុះភ្លៀងទីហ្វុង ឬព្យុះផ្សេងទៀត អាចបង្កឱ្យមានមហន្តរាយធំៗ ដូចជាការបាក់ រលំបង្គោល ដាច់ខ្សែ និងការខូចហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ជាពិសេសការធ្វើឱ្យរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិក-កម្មករ និងប្រជាពលរដ្ឋនៅក្នុង និងក្បែរខាងតំបន់គំរោង ។<br>- ការឆេះព្រៃក្នុងតំបន់គំរោងដែលបណ្តាលមកពីការធ្វេសប្រហែសបច្ចេកទេស ឬឆ្លុះសេខ្សែភ្លើង ឬអំពើភាវវកម្ម ក៏អាចបង្កឱ្យមានមហន្តរាយ /គ្រោះថ្នាក់ធំដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្ស ទៀតផង ។<br>- ការកើតមានសង្គ្រាមឈ្លានពានលើបូរណភាពទឹកដីនៃប្រទេសកម្ពុជា និងសង្គ្រាមផ្ទៃក្នុងក៏ជាឧបសគ្គដល់កិច្ចដំណើរការ និងថែទាំគំរោងជូនកាលសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងទៀតផង ។ | | | ✓ | - បានបំពាក់ប្រព័ន្ធផ្តាច់ភ្លើងដោយស្វ័យប្រវត្តិ ដើម្បីផ្តាច់ចរន្តអគ្គិសនីឱ្យទាន់ពេលវេលាការពារអាយុជីវិតមនុស្ស សត្វ ។<br>- បានប្រុងប្រយ័ត្នគ្រប់វិធានទីក្នុងការការពារសន្តិសុខចំពោះគ្រឿងអាចឆេះនានា អគ្គីភ័យនានា និងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បីទប់ស្កាត់រាល់អំពើភេរវកម្មក្នុងតំបន់គំរោង ។<br>- ត្រូវធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ ដែលអាចបង្កដល់ការបាក់រលំបង្គោលភ្លើង ការដាច់ខ្សែ ដោយសារគ្រោះធម្មជាតិដល់ប្រជាពលរដ្ឋដែលរស់ក្នុង និងក្បែរខាងគំរោងនេះទាំងអស់ឱ្យបានជ្រាបហេតុការណ៍ខាងលើបានទាន់ពេលវេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិភ័យបែបនេះកើតឡើង ។<br>- បានរៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះសម្ភារ និងថវិកាដើម្បីធានាការដោះស្រាយផលប៉ះពាល់ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាព ។ | |



Draft

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន | កំណត់ចំណាំនៃហេតុប៉ះពាល់បរិស្ថាន | | | វិធានការណ៍កាត់បន្ថយ | សម្គាល់ |
|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | |
| ៣. ដំណាក់កាលបិទគំរោង (Project Closure) | | | | | | |
| ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុនរបស់ប្រទេសចិន នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជា នឹងទទួលបន្ទុកធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគំរោង អាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាអ្នកសំរេចខ្លួនឯង ហើយសង្ឃឹមថាក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុនចិននេះ ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ដែលគួរឱ្យកត់សំគាល់ឡើយ ។ (ចំពោះបទដ្ឋានបច្ចេកទេស និងគុណភាពរបស់ហេដ្ឋារចនាសម្ព័ន្ធគំរោងនេះដែលនឹងត្រូវប្រគល់ជូនរាជរដ្ឋាភិបាលវិញមានចែងលំអិតក្នុងកិច្ចសន្យារួចអស់ហើយ) ។ | | | | | | |

## ៨.៤ ហេតុប៉ះពាល់បរិស្ថានវិជ្ជមានសំខាន់ៗ (Positive Environmental Impacts)

### ៨.៤.១ ធនធានរូបសាស្ត្រ (Physical and Ecological Resources)

- **ការកាត់បន្ថយឧស្ម័នកាបូនិកដែលធ្វើឱ្យផែនដីកើនកំដៅ និងការបំពុលខ្យល់**

ទោះបីជាខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់នេះប៉ះពាល់ដល់ព្រៃឈើ សត្វព្រៃ និងប្រជាជនមួយចំនួនក៏ដោយក្រុមហ៊ុនគ្រោងនឹងផ្តល់មូលនិធិសំរាប់ការពារបរិស្ថានសំរាប់កាត់បន្ថយការប៉ះពាល់ទាំងនេះ និងសំរាប់បំលាស់ប្តូរលំនៅដ្ឋានផងដែរ។ ជាការពិតនៅតាមបណ្តាលខេត្ត ស្រុក និងឃុំមួយចំនួនធំក៏ដូចជានៅតាមតំបន់គំរោងឆ្លងកាត់ដែរ ភាគច្រើនគឺប្រើចរន្តអគ្គិសនីចេញពីកំលាំងម៉ាស៊ីនដើរដោយឥន្ធនៈ (Fuel) និងធ្យូងថ្ម (Coal) ដែលបានបញ្ចេញឧស្ម័នកាបូនមូណូអុកស៊ីត (CO) និងកាបូនឌីអុកស៊ីត ឬកាបូនិច ($CO_2$) ជាប្រភពបង្កឱ្យមានឧស្ម័នផ្ទះកញ្ចក់ដែលធ្វើឱ្យផែនដីឡើងកំដៅ ហើយក៏បានបំពុលខ្យល់ផងដែរ ដែលពិភពលោកកំពុងព្រួយបារម្ភណ៍។ ដូច្នេះនៅពេលដែលគំរោងបានសាងសង់រួចហើយចាប់ផ្តើមប្រតិបត្តិ និងថែទាំនោះ វានឹងជួយកាត់បន្ថយបញ្ហានេះបានមួយផ្នែកធំផងដែរ។

### ៨.៤.២ ធនធានសេដ្ឋកិច្ច និងសង្គម

- **ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងការអភិវឌ្ឍន៍សេដ្ឋកិច្ច**

គំរោងខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥ គ.វ ពីអគារថាមពលទី១ នៃទំនប់ទី១ មកអនុស្ថានីយ៍អូរសោម និងពីអគារថាមពលទី២ខាងក្រោមទំនប់ទី២មកអនុស្ថានីយ៍អូរសោម ហើយភ្ជាប់ពីអនុស្ថានីយ៍អូរសោមមកអនុស្ថានីយ៍ពោធិសាត់តាមខ្សែបញ្ជូនចរន្ត ២៣០គ.វ៉ (អនុស្ថានីយ៍អូរសោម អនុស្ថានីយ៍ពោធិសាត់ និងខ្សែបញ្ជូនចរន្ត ២៣០ គ.វ៉ជាបន្ទុករបស់ក្រុមហ៊ុន C.P.G និង EDC) នឹងផ្គត់ផ្គង់ចរន្តអគ្គិសនីជូនប្រជាពលរដ្ឋដែលរស់នៅក្នុង ខេត្តកំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង រួមទាំងរាជធានីភ្នំពេញស្ថិតែទាំងស្រុងតាមរយៈគំរោងខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥គ.វ៉- ២៣០គ.វ៉ ភ្នំពេញ-បាត់ដំបង។ ខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់នេះជាប្រភពដែលផ្តល់នូវថាមពលមួយយ៉ាងសំខាន់ដើម្បីឆ្លើយតបទៅនឹងតំរូវការដ៏មានប្រសិទ្ធិភាពចំពោះដំណោះស្រាយក្នុងការតភ្ជាប់តំបន់ប្រភពអគ្គិសនីទៅតំបន់និរតី និងពាយ័ព្យមកផ្គត់ផ្គង់តំបន់នៃបណ្តាលខេត្តនានា និងទីក្រុងដែលកំពុងមានតំរូវការភ្លើងយ៉ាងខ្លាំងសំរាប់ការអភិវឌ្ឍន៍នោះគំរោងខ្សែចម្លងតង់ស្យុងខ្ពស់នេះពិតជាដើរតួរយ៉ាងសំខាន់ក្នុងការងារ នេះ។

ស្របទៅនឹងនយោបាយកាត់បន្ថយភាពក្រីក្រនៅកម្ពុជារបស់រាជរដ្ឋាភិបាលផងដែរ ព្រោះប្រជាពលរដ្ឋអាចនឹងប្រើប្រាស់ចរន្តអគ្គិសនីនេះដើម្បីជាថាមពលក្នុងការស្រោចស្រពជំនួសម៉ាស៊ីន។ ជាងនេះទៅទៀតប្រជាពលរដ្ឋក៏អាចមានជីវភាពល្អប្រសើរថែមទៀតនៅពេលពួកគាត់មានថាមពលនេះដើម្បីការងារសិប្បកម្មនានាដូចជា ចំលាក់ តម្បាញ។ល។ ហើយក៏ជាការទាក់ទាញឱ្យមានរោងចក្រ ឧស្សាហកម្មខ្នាតធំ និងតូចកើតមាននៅតាមតំបន់ដែលបណ្តាញនេះឆ្លងកាត់ដែលអាចបង្កើនការងារបន្ថែមជូនប្រជាពលរដ្ឋផងដែរ។

ម្យ៉ាងវិញទៀត គំរោងមានការបង់ផ្ទាល់ចូលចំណូលថវិកាជាតិ ដោយសារក្រុមហ៊ុននឹងត្រូវបង់ពន្ធអាករលើការនាំចូលប្រេងឥន្ធនៈសំរាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀតក្នុងរយៈពេលប្រតិបត្តិ និងថែទាំគំរោងទៅតាមកិច្ចសន្យារវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា។

Draft

ប្រសិនបើមានតែកន្លែងផលិតថាមពលហើយគ្មានខ្សែបញ្ជូនចរន្តនោះ គំរោងវារីអគ្គិសនី និងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មនឹងមិនមានដំណើរការបានឡើយ ។ ដូច្នេះហើយគំរោងខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់នេះដើរតួយ៉ាងសំខាន់ក្នុងការសំរួលដល់ការផ្គត់ផ្គង់ និងតភ្ជាប់ចរន្តពីតំបន់មួយទៅតំបន់មួយទៀត ។

- **<u>ការប្រើប្រាស់ដី/តំលៃដី និងទេសចរណ៍</u>**

ដោយសារឥទ្ធិពលនៃការអភិវឌ្ឍន៍គំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វាអាចនឹងធ្វើឱ្យដីក្បែតំបន់គំរោងអាចមានតំលៃខ្ពស់ជាពិសេសការប្រើប្រាស់ដីសំរាបវិស័យឧស្សាហកម្ម កសិកម្មទំនើប និងទេសចរណ៍ ។ នៅតាមតំបន់មួយចំនួនដែលមានខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ១១៥ គ.វ៉ នេះឆ្លងកាត់ ។ ដូច្នេះប្រជាពលរដ្ឋអាចកែប្រែតំបន់មួយចំនួនឱ្យទៅជាតំបន់ទេសចរណ៍ប្រចាំភូមិ ឃុំរបស់ពួកគេទៅតាមលទ្ធភាពដែលគេអាចធ្វើបាន ។

- **<u>ផ្តល់ការងារ និងលើកស្ទួយជីវភាព</u>** (Employment and increase living standard)

តាមរយៈគំរោងនេះនឹងផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាផងដែរ ដូចជាក្នុងដំណាក់កាលសាងសង់ គំរោងត្រូវជ្រើសរើសបុគ្គលិក-កម្មករគំរោង ៥២នាក់ ក្នុងនោះប្រជាពលរដ្ឋក្នុងមូលដ្ឋានចំនួន៤០នាក់ និងបុគ្គលិក-កម្មករចិន ចំនួន១២នាក់ រីឯបុគ្គលិកសំរាប់គ្រប់គ្រងប្រព័ន្ធខ្សែចម្លងក្នុងកំឡុងពេលប្រតិបត្តិ និងថែទាំរយៈពេល៣០ឆ្នាំ មានដូចជាពីអគារថាមពលនៃទំនប់ទី១ មកអនុស្ថានីយ៍អូរសោមៈ ក្រុមហ៊ុនមានផែនការជ្រើសរើសបុគ្គលិកសរុបចំនួន១១នាក់ ក្នុងនោះបុគ្គលិកខ្មែរចំនួន ០២នាក់ និងបុគ្គលិកចិនចំនួន ០៩នាក់ និងពីអគារថាមពលនៃទំនប់ទី២មកអនុស្ថានីយ៍អូរសោមៈ ក្រុមហ៊ុនមានផែនការជ្រើសរើសបុគ្គលិកចំនួន១១នាក់ ក្នុងនោះបុគ្គលិកខ្មែរចំនួន ០២នាក់ និងបុគ្គលិកចិនចំនួន ០៩នាក់ ។

គំរោងនេះនឹងមានការបណ្តុះបណ្តាលមន្ត្រីជំនាញកម្ពុជាសំរាប់បន្តដំណើរការបន្តក្រោយពីក្រុមហ៊ុនបញ្ចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាល ។

គំរោងនឹងបង្កើតប្រាក់ចំណូលដល់ប្រជាពលរដ្ឋកម្ពុជាជាពិសេសប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានតាមរយៈផ្តល់ការងារជាបុគ្គលិកកម្មករទាំងពេលសាងសង់ និងពេលប្រតិបត្តិការថែទាំ ។

Draft